ប្រស្នាព្រៃគុណា

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ១៩៩៩

ប្រស្នាព្រៃគុណ

គឺ

លោកអាចារ្យ **ឈឹម - ឌួច** ឥន្ទប្បញ្ញោ

វត្តលង្កា

ប្រែនិងរៀបរៀង

បោះពុម្ពលើកទី ២ ចំនួន ២.៥០០ ច្បាប់

(ចម្លងចេញពីច្បាប់ដើមដែលបោះពុម្ពក្នុងឆ្នាំ ១៩៤០)

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស. ១៩៩៩

ការកុំព្យូទ័រ : ឱម ចិរៈ, សោម ចន្ទ, ស៊ិន សុវណ្ណ

ត្រួតពិនិត្យផ្ទាត់ផ្ទៀងសំណៅឯកសារ និងបោះពុម្ពស្បៀវភៅនេះ

ឱម ខែម

នាយកពុទ្ធសាសនបណ្ឌិត្យ

សេចក្តីប្រារព្ធ
ចំពោះការបោះពុម្ពលើកទី ២
នៃសៀវភៅប្រស្នាត្រៃគុណ

ក្នុងឆ្នាំកន្លងទៅនេះ ពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា បានស្រាវជ្រាវរើសរកក្បួនខ្នាតទាក់ទងនឹងអក្សរសាស្ត្រសាសនាមកបោះពុម្ពឡើងវិញ ដើម្បីរក្សាស្នាដៃរបស់បុព្វបុរសខ្មែរយើង ។ ក្នុងបណ្តាសៀវភៅដែលបានបោះពុម្ពយូរមកហើយ សៀវភៅ **ប្រស្នាត្រៃគុណ** គឺជាស្នាដៃមួយដែលមានធម៌អាថ៌សំរាប់ពុទ្ធបរិស័ទសិក្សា ហើយមានប្រយោជន៍ច្រើនដល់អ្នកប្រតិបត្តិ ។

ការបោះពុម្ពលើកទី២នេះ ធ្វើឡើងដោយការចម្លងរៀបរៀងឃ្លា និងចំព័រជាថ្មី តាមកម្មវិធីកុំព្យូទ័ររក្សរខ្មែរ ដោយយកសៀវភៅប្រស្នាត្រៃគុណ ដែលជាច្បាប់បោះពុម្ពឆ្នាំ ១៩៤០ របស់លោក ឈឹម ទូច ធ្វើជាគំរូសំរាប់ចម្លង និងបោះពុម្ពផ្សាយ ដោយបានរក្សាទុកខ្លឹមសារដើមទាំងស្រុង លើកលែងតែអក្ខរាវិរុទ្ធត្រង់អន្លើខ្លះ ត្រូវបានកែតម្រូវ ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុនចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមានដោយអចេតនា ក្នុងការចម្លង និងបោះពុម្ពឡើងវិញនេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសូត្រស៊ូជប៉ុន (JSRC = SVA) និងក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ដែលបានផ្តល់ការឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែឧសភា ឆ្នាំ ១៩៩៩

ពុទ្ធសាសនបណ្ឌិត្យ

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなりカンボジアの宗教と文化の発展に貢献できれば幸いです。

និវេទនកថា

ស្បៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC = SVA) និងដោយបានទទួលការឧបត្ថម្ភបោះពុម្ពពីគណៈកម្មាធិការជប៉ុន នៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ។

យើងខ្ញុំអធិដ្ឋាន សូមអោយស្បៀវភៅនេះបានជាវិភាគទានដល់ការពង្រឹងមិត្តភាពរវាងប្រជាជនកម្ពុជា ជាមួយប្រជាជនជប៉ុនដែលកាន់សាសនាផ្សេងៗ និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

Acknowledgement

This book has been printed by Japan Sotoshu Relief Committee (JSRC = SVA) with the contribution from the Japanese Committee of the World Conference on Religion and Peace (WCRP/Japan).

We pray that this book would contribute to promote the friendship between Cambodian people and Japanese religious people and to preserve Cambodian cultural and religious heritage.

បញ្ជីមាតិកា

ប្រស្នាត្រៃគុណ	លេខទំព័រ
• ពាហិរកថា	ឆ
• បរិយាយដើម	១
• កែពាក្យ រតនត្រ័យ	១
• **ពណ៌នាអំពី ពុទ្ធរតន**	២
កែបទ អរហំ	៦
កែបទ សម្មាសម្ពុទ្ធោ	១២
កែបទ វិជ្ជាចរណសម្បន្នោ	១៩
កែបទ សុគតោ	២៥
កែបទ លោកវិទូ	៣០
កែបទ អនុត្តរោ	៤០
កែបទ បុរិសទម្មសារថិ	៤៩
កែបទ សត្ថា ទេវមនុស្សានំ	៥៦
កែបទ ពុទ្ធោ	៦២
កែបទ ភគវា	៧០
• អវសានកថា	៧៤
• **ពណ៌នាអំពី ធម្មរតន**	៧៦
កែបទ ស្វាក្ខាតោ ភគវតា ធម្មោ	៧៧
កែបទ សន្ទិដ្ឋិកោ	១០៨

ប្រស្នាវិត្រគុណ	លេខទំព័រ
កែបទ អកាលិកោ	១១០
កែបទ ឯហិ បស្សិកោ	១១០
កែបទ ឱបនយិកោ	១១១
កែបទ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ	១១២
• **ពណិនារំពី សច្ឆរកន**	១១៣
កែបទ សុបដិបន្នោ ភគវតោ សាវកសង្ឃោ	១១៤
កែបទ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ	១១៦
កែបទ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ	១១៧
កែបទ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ	១១៨
កែបទ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា	១១៨
ប្រែបទ ឯស ភគវតោ សាវកសង្ឃោ	១២៦
កែបទ អាហុណេយ្យោ	១២៦
កែបទ បាហុណេយ្យោ	១២៧
កែបទ ទក្ខិណេយ្យោ	១២៧
កែបទ អញ្ជលីករណីយោ	១២៨
កែបទ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស	១២៨

ពាលិរកថា

សៀវភៅ « ប្រស្នាត្រៃគុណ » នេះ គឺខ្ញុំបានដកស្រង់ព្រះពុទ្ធវចនៈក្នុងគម្ពីរជាច្រើន មានគម្ពីរវិសុទ្ធិមគ្គជាដើម មករៀបរៀងជាសេចក្តីបុច្ឆា-វិសជ្ជនា ដើម្បីមានប្រទីបបំភ្លឺអ្នកកាន់ព្រះពុទ្ធសាសនា ដែលមានបញ្ហានៅទន់ខ្លី ច្រើនដោយសេចក្តីល្ងង់ខ្លៅ ឱ្យមានបញ្ហាស្វាងរុងរឿង មោះមុតឈ្វេងយល់នូវគុណព្រះរតន-ត្រ័យមិនឱ្យភាន់ច្រឡំ ព្រោះថា អ្នកកាន់ព្រះពុទ្ធសាសនាដែលរក្សាព្រះត្រៃសរណ-គមន៍ លុះត្រាតែដឹងច្បាស់នូវគុណទាំងនោះដោយជាក់ច្បាស់ឥតភាន់ច្រឡំ ទើបមិនងាកចិត្តទៅកាន់សាសនាដទៃ ។ ហេតុនេះទើបយើញថា « ប្រស្នាត្រៃគុណ » នេះជាសៀវភៅមួយ ដូចជាប្រទីបសម្រាប់បំភ្លឺអ្នកដែលមានបញ្ហាទន់ខ្លីនៅឡើយ ។

ឯបុព្វហេតុដែលជាលំអានដើម នាំឱ្យខ្ញុំមានសេចក្តីព្យាយាមប្រឹងប្រែងរៀបរៀងសៀវភៅនេះ ដោយគុណូបការៈនៃមាតាបិតារបស់ខ្ញុំទាំងទ្វេហារដែលលោកមានគុណដ៏ធំក្រៃលែង ហៅថា «អនន្តគុណ» ឬ «អប្បមាណគុណ» ព្រោះលោកទាំងពីរនោះមានព្រហ្មវិហារធម៌ផ្សាយគ្របដណ្តប់លើខ្ញុំជាកូនឥតមានល្អៀ ។

កាលបើខ្ញុំចាប់ភ្លឺកនឹកភ្ញកដល់គុណលោកទាំងពីរនេះហើយ ខ្ញុំរំឭងគិតថា « ឱ ! មាតារបស់អញ លោកលាកលះលោកនេះ ធ្វើដំណើរទៅកាន់បរលោកបាត់បង់ឃ្លាតឆ្ងាយណាស់ទៅហើយ ឯបិតាដែលរស់នៅសោត ក៏កាន់តែចាស់ជរាទោរទន់ណាស់ទៅហើយដែរ បើដូច្នេះ គួរតែអញរៀបរៀងសៀវភៅមួយ ធ្វើជាធម្មទាន

ដើម្បីបានចំណែកបុណ្យជូនទៅមាតា ដែលធ្វើមរណកាលទៅយូរហើយផង ដើម្បីនឹងជ្រោមជ្រែងដំណើរបិតា ដែលបម្រុងនឹងលះបង់លោកនេះចេញទៅដែរ ឱ្យប្រព្រឹត្តទៅបានស្រួលផង » ។

ក៏នៅវេលាដែលខ្ញុំរៀបរៀងសៀវភៅនេះ មានពុទ្ធបរិស័ទច្រើនរូបមកសូមចុះឈ្មោះទទួលយកសៀវភៅនេះ ទៅធ្វើជាធម្មទាន ដូចមានរាយឈ្មោះតទៅនេះ គឺ : លោកគ្រូចៅអធិការវត្តកំពង់គរ ស្រុកលើកដែក ខែត្រកណ្តាល, លោក ដេរិកម័រ គាម គុម, ថី ពុត-អ៊ុំ ផែនទីខែត្រព្រៃវែង, ឧបាសក ទុយ ដង្ហៅ អូន នៅភូមិបត់រការ ស្រុកសំរោង ខែត្រតាកែវ, ឧបាសក ឃុន នៅភូមិខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខែត្រកំពង់ចាម, ឧបាសក សៀង ស៊ុយ នៅខែត្រកំពង់ឆ្នាំង, អ្នកអាចារ្យ ឈីន, អ្នកជំទប់ ឈីន ខែត្របាត់ដំបង, ជាង ហាង់ នៅភូមិរកាកោង ស្រុកខ្សាច់កណ្តាល ខែត្រកណ្តាល, ឧបាសក ហ៊ឹម ឃុំថាញ់ឈ្វេង ខ័ណ្ឌង៉ាយវ៉ាធឿង ខេត្តត្រាវិញ ។

លុះខ្ញុំរៀបរៀងស្រេចហើយ ខ្ញុំបានយកសៀវភៅនេះទៅប្រគេនលោកអ្នកប្រាជ្ញ ដែលជាប្រចីបរបស់ខ្ញុំ ដូចមានរាយនាម និងឋានន្តរតទៅនេះគឺ ព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស (អែម) សិរីលីយេ ដីឡាឡេស្យុងដូណើរ ចាងហ្វាង សាលាបាលីជាន់ខ្ពស់ អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។

ព្រះតេជព្រះគុណព្រះមហា (ឡុច) ក្រមជំនុំប្រែព្រះត្រៃបិដក ។ ព្រះគ្រូវិរិយមុនី វិសុទ្ធិញាណ (រស់) គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់, ឱ្យលោកពិនិត្យផ្ទៀងផ្ទាត់ឱ្យ ។ លុះលោកពិនិត្យផ្ទៀងផ្ទាត់រួចហើយ ទើបខ្ញុំចាត់ការបោះពុម្ព ។

ដោយកំឡាំងព្យាយាមរបស់ខ្ញុំនេះ សូមតាំងប្រតិសួរអធិដ្ឋានប្រណិធាន សូមឱ្យព្រះពុទ្ធសាសនារបស់ព្រះសម្មាសម្ពុទ្ធរុងរឿងគ្រប់ ៥០០០ ព្រះវស្សា សូមឱ្យកុសលរាសីនេះ អណ្តែតត្រសែតទៅជួយទំនុកបម្រុងមាតាខ្ញុំ ដែលធ្វើដំណើរទៅកាន់បរលោកយូរហើយនេះផង សូមឱ្យជួយឧបត្ថម្ភបិតាខ្ញុំ ដែលបម្រុងនឹងចែកស្ថានទៅផង ។ ទាំងពួកសត្វទាំងឡាយដែលស្ថិតនៅក្នុងចតុឱឃាជលាលោកទាំងអស់ ក៏សូមឱ្យបានទទួលឥដ្ឋមនុញ្ញផលគ្រប់ៗគ្នា កុំបីឃ្លាតឃ្លាឡើយ ។

ថ្ងៃទី ៣០ ខែអ្វីត ឆ្នាំ ១៩៣៧

លោកអាចារ្យ ឈិម-ទូច វត្តលង្កា ក្រុងភ្នំពេញ

ប្រស្នាត្រៃគុណ

នមត្ថុ រតនក្តយស្ស

បរិយាយដើម

ស្ងមពណិនាសរសើរគុណព្រះរតនត្រ័យជាពាក្យបុច្ឆា-វិសជ្ជនា ដើម្បីញ្ជាំងទីកចិត្តពួកជនដែលមិនទាន់ជ្រះថ្ឋាឱ្យជ្រះថ្ឋាឡើង និងបានបែរមុខឈមទៅរកព្រះរតនត្រ័យទាំងនោះ និងដើម្បីជម្រុលចិត្តពួកជនដែលធ្ឋាប់ជ្រះថ្ឋាស្រាប់ហើយឱ្យរីងរីតតែជ្រះថ្ឋាក្រៃលែងឡើងទៀត ដោយហេតុដែលបានមើល បានស្តាប់ ឬបានគិតរំពឹងពិចារណាតាមដំណើរសេចក្តីនេះ ។

កែពាក្យ « រតនត្រ័យ »

បុ. ពាក្យថា « រតនត្រ័យ » មានសេចក្តីអធិប្បាយយ៉ាងណា ?

វិ. មានសេចក្តីអធិប្បាយថា វត្ថុ ៣ ប្រការគឺ *ព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឆ ១* ឈ្មោះថា រតនៈ ព្រោះជារបស់ប្រសើរវិសេសជាងសវិញ្ញាណករតនៈ និងអវិញ្ញាណករតនៈ ដែលមាននៅក្នុងលោកទាំងបី [(១)] និងជារបស់អាចធ្វើសេចក្តីត្រេកអរសោមនស្សឱ្យកើតឡើងដល់សត្តនិករក្នុងត្រៃភព [(២)] ។

---

(១) កាមលោក ១ រូបលោក ១ អរូបលោក ១ ។ (២) កាមភព ១ រូបភព ១ អរូបភព ១ ។

ពណ៌នាអំពី ពុទ្ធរតនៈ

បុ. ព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គទ្រង់កើតក្នុងតំបន់ណា ? ជាជាតិអ្វី ? គោត្រអ្វី ? ទ្រង់ព្រះនាមដូចម្តេច ? ជាបុត្ររបស់លោកណា ? មានភរិយាដែរឬទេ ?

វិ. ព្រះអង្គទ្រង់កើតក្នុងមជ្ឈិមប្រទេស, ដែនសក្កៈ ក្រុងកបិលពស្តុ ក្នុងសក្យត្រកូល ឬពួកអរិយជន, ជាខត្តិយជាតិ ជាគោតមគោត្រ, ទ្រង់ព្រះនាមថាព្រះសិទ្ធត្ត ជាបុត្ររបស់ព្រះចៅសីរីសុទ្ធោទនៈ និងព្រះនាងមហាមាយាទេវី ទ្រង់បានទទួលរាជ្យតំណវង្សអំពីព្រះបិតា មានព្រះនាងពិម្ពាយសោធរា ជាងកអគ្គមហេសី, រាហុលរាជកុមារ ជាព្រះរាជឱរស ។

បុ. ព្រះអង្គទ្រង់បានសោយរាជសម្បត្តិ មានទាំងព្រះអគ្គមហេសី និងព្រះរាជឱរស គ្ងរណាស់តែសព្វព្រះទ័យនឹងនៅសំងំសោយសុខក្នុងកាមឱ្យស្កប់ស្កល់ទាល់តែអស់ព្រះជន្ម ចុះហេតុអ្វី ក៏ព្រះអង្គទៅទ្រង់ព្រះផ្នួស ? ព្រះអង្គមិនទ្រង់អាឡោះអាល័យសោះទេឬ ?

វិ. បានជាព្រះអង្គចេញទៅទ្រង់ព្រះផ្នួស ញ្ញោះព្រះអង្គមានព្រះទ័យតក់ស្លុតនឹងខន្ធទាំង ៥ ដោយបានទតឃើញទេវទូតទាំង ៤ គឺ មនុស្សជរា, ព្យាធិ, មរណៈ, និងភេទបព្វជិត, ទ្រង់ឈ្វេងយល់ថា ជរា ព្យាធិ និងមរណៈនេះ ដូចជាភ្លើងដ៏សន្ធោសន្ធៅរន្ទាលច្រាលឆ្អៅ ឆេះរោលរាលមកលើពួកសត្ត និងអត្តភាពរបស់ព្រះអង្គ ។ ព្រះអង្គនឹងតាំងព្រះទ័យតោះតើយទៅមិនកើត ញ្ញោះទ្រង់ព្រះយោបល់ថា ធមិទាំងនេះជាភ័យធំពន្លឹកគ្ងរឱ្យស្ងើបរំភើបពេកណាស់ បើអាត្មាអញសំងំនៅក្នុងទីនេះ

ច្រឡូកច្រឡំដោយបុត្រភរិយា មុខជានឹងគេចចេញពីកណ្តាប់ដៃជរា ព្យាធិ មរណៈ នេះមិនរួចឡើយ បើដូច្នេះ គួរអាត្មាអញភៀសខ្លួនចេញទៅបួសស្វះស្វែងរកធម៌ ជាគ្រឿងរំលត់ទុក្ខចុះ កាលបើធ្វើយ៉ាងនេះ សមអាត្មាអញនឹងបានពើបពះប្រទះនឹង សេចក្តីសុខមិនខាន ព្រោះបព្វជ្ជា ជាភេទឧត្តមថ្លៃថ្លា ឥតមានជំពាក់ចាក់ទាមដោយ ទ្រព្យសម្បត្តិ បុត្រ ភរិយាអ្វីឡើយ មើលទៅឃើញតែភេទនេះហើយ ទើបបាន សេចក្តីសុខ ។ លុះព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងនេះហើយ ទើបទ្រង់ចេញទៅសាង ព្រះផ្នួស ។ ទ្រង់មានព្រះទ័យអាល័យរាជសម្បត្តិ និងបុត្រ ភរិយាដែរ តែទ្រង់ខំប្រឹង លាកលះដោយកាត់ព្រះទ័យជំនះចេញទៅ, ពេលទៀបទ្រង់ព្រះរាជដំណើរទៅនោះ ទ្រង់មានព្រះទ័យជាប់ជំពាក់នឹងរាហុលកុមារយ៉ាងមាំ អត់ទ្រាំពុំបាន ទើបទ្រង់ស្តេច ចូលទៅកាន់បន្ទប់ព្រះនាងទេវី ប្រាថ្នានឹងចាប់ចីព្រះឱរស ទទួលពេលនោះ ព្រះនាង ទេវីកំពុងផ្ទំលក់ដាក់ព្រះហស្តគងលើព្រះឱរស ទ្រង់ក៏ស្តេចថយចេញមកវិញ ក្រែង ព្រះនាងតើនឡើងទាន់ នាំអុកឡុកស្កុនព្រះរាជដំណើរ ម្ល៉ោះហើយស៊ូកាត់ព្រះទ័យថា ណ្លើយចុះ ចាំគ្រាក្រោយសឹមអាត្មាអញមកឃើញមុខកូននិងៗ ។

នៅមានន័យមួយកន្លែងទៀតថា កាលដែលព្រះអង្គទ្រង់បានត្រាស់រួច ហើយ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន ទ្រង់បានដំណាលរឿងនេះចំពោះព្រះអានន្ទថា អានន្ទអើយ, កាលតថាគតកំពុងធ្វើទុក្ករកិរិយានៅក្នុងព្រៃជាទីរហោស្ថាន (ស្ថាន ស្ងាត់) តែម្នាក់ឯង រមែងនឹកមមៃដល់កាមគុណទាំង ៥ ប្រការ ដល់រាជសម្បត្តិ បុត្រ ភរិយា ទីទៃនសយនា ក្រឡាព្រះបន្ទំ ដែលតថាគតធ្លាប់អភិរមអាស្រ័យនៅជា រឿយៗមក ។ ហេតុនេះឃើញថា ព្រះអង្គគង់មានព្រះទ័យអាល័យដែរ តែបើទុកជា ដូច្នោះ ក៏ទ្រង់ចេះតែខំលះកាត់ព្រះទ័យប្រឹងពាយាមបន្ទំព្រះបារមីចាល់តែបាន

សម្រេចសម្មាសម្ពោធិញាណជាព្រះសព្វញ្ញុពុទ្ធឡើងក្នុងលោក ។

បុ. ចុះព្រះពុទ្ធនោះ តើទ្រង់មានគុណដូចម្តេចខ្លះ ?

វិ. ទ្រង់មានគុណច្រើនលើសលប់នឹងរាប់មិនបាន សូម្បីតួអង្គព្រះពុទ្ធផងគ្មា បើទុកជាតាំងពីបានត្រាស់ឡើងកាលណា មិនសំដែងធមិអ្វីសោះ សំដែងតែអំពីគុណព្រះពុទ្ធផងគ្មា ដរាបអស់មួយកប្ប ក៏មិនអស់គុណនោះដែរ ។ ឯគុណទាំងនោះ បើពោលរួបរួមកាត់ឱ្យខ្លីចុះមក នៅតែត្រឹម ៣ យ៉ាងគឺ បញ្ញាគុណ ១ វិសុទ្ធិគុណ ១ ករុណាគុណ ១ ព្រោះគុណទាំង ៣ នេះ ជាប្រធានលើគុណទាំងពួង ។ គុណទាំងពួងសុទ្ធតែប្រជុំចុះក្នុងគុណទាំង ៣ នេះ ឬសុទ្ធតែផ្សាយចេញទៅអំពីគុណទាំង ៣ នេះ ឯង ។

បុ. បណ្តាគុណទាំង ៣ ប្រការនេះ ដូចរាប់រួចមកហើយ ដែលហៅថា បញ្ញាគុណនោះ តើដូចម្តេច ។

វិ. ដែលហៅថា « បញ្ញាគុណ » នោះ សំដៅយកការត្រាស់ដឹងនូវមគ្គ-ញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និងញ្ញាណដ៏វិសេស មានចតុវេសារជ្ជញ្ញាណ ទសពលញ្ញាណ និងអណាវរណញ្ញាណ ជាដើម ដែលកើតអំពីមគ្គញ្ញាណដូចគ្មា ដែលជាហេតុឱ្យសម្រេចគុណដល់សព្វសត្ត ព្រោះជ្រាបច្បាស់ថា អំពើនេះជាប្រយោជន៍ដល់សត្ត, នេះមិនមែនជាប្រយោជន៍ដល់សត្ត អំពើណាជាប្រយោជន៍ ព្រះអង្គរកឧបាយឱ្យសត្វសន្សំ អំពើណាមិនជាប្រយោជន៍ ព្រះអង្គរកឧបាយឱ្យសត្វលះបង់ដោយអនុសាសនីទេសនា ; យ៉ាងនេះឯងហៅថា « បញ្ញ ាគុណ » ។

ប្. ចុះវិសុទ្ធិគុណ ដូចម្តេច ?

វិ. វិសុទ្ធិគុណ សំដៅយកត្រង់សេចក្តីបរិសុទ្ធរបស់ព្រះអង្គ បានដល់ការលះបង់កិលេស ព្រមទាំងវាសនាដាច់ស្រឡះ ទោះបីលោកធម៌ទាំង ៨ ប្រការ កើតឡើងចំពោះព្រះភក្ត្រ ក៏ចិត្តព្រះទ័យរបស់ព្រះអង្គមិនមានរំភើប ; យ៉ាងនេះហៅថា « វិសុទ្ធិគុណ » ។

ប្. ចុះករុណាគុណ ដូចម្តេច ?

វិ. ករុណាគុណ បានដល់សេចក្តីប្រណីអាណិតដល់ពួកសត្វដែលកំពុងក្តៅក្រហល់ក្រហាយ អន្ទះអន្ទែងដោយភ្លើងទុក្ខ ភ្លើងកិលេស និងជ្រមុជឈ្លក់នៅក្នុងសង្សារសមុទ្ទ រងទុក្ខវេទនារកទីបំផុតមិនបាន ទ្រង់ក៏មានព្រះទ័យប្រាថ្នានឹងស្រោចស្រង់ លើកស្ទួយពួកសត្វទាំងនោះឱ្យរួចផុតអំពីទុក្ខវេទនានោះឡើង យ៉ាងនេះហៅថា « ករុណាគុណ » ។

គុណទាំង ៣ នេះ ស្តេះទុកប៉ុណ្ណោះ តអំពីនេះនឹងសំដែងអំពីគុណដែលជាកិត្តិសព្ទ ឮល្បីសុះសាយទៅក្នុងលោកទាំង ១០ ប្រការ (ឬ ៩ ប្រការ) មាន « អរហំ » ជាដើម មាន « ភគវា » ជាបរិយោសាន ដើម្បីជាទីរឭក និងជាទីជ្រះថ្លាដល់អ្នកកាន់ព្រះពុទ្ធសាសនាទាំងពួងតទៅ ។

កែបទ « អរហំ »

បុ. ព្រោះហេតុអ្វីបានជា ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា « អរហំ » ?

វិ. ព្រោះព្រះអង្គជាអ្នកឆ្ងាយ, ជាអ្នកបំបាក់បង់, ជាអ្នកគួរ, ជាអ្នកមិនមានទីកំបាំង ។

ក) បុ. ពាក្យថា « ព្រះអង្គជាអ្នកឆ្ងាយ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះអង្គជាអ្នកឆ្ងាយស្រឡះអំពីកិលេស (គ្រឿងមន្ទិល) ៣ គឺ រាគៈ ១ ទោសៈ ១ មោហៈ ១ ; អាសវៈ ៣ គឺ កាមាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ; វិបល្លាស ៣ គឺ សញ្ញាវិបល្លាស ១ ចិត្តវិបល្លាស ១ ទិដ្ឋីវិបល្លាស ១ ; អនុសយៈ ៣ គឺ កាមរាគានុសយៈ ១ ទិដ្ឋានុសយៈ ១ អវិជ្ជានុសយៈ ១ ; អគតិ ៤ គឺ ឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១ ; គន្ថៈ ៤ គឺ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វត្តបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ; ឱឃៈ ៤ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ; ឧបាទាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វត្តុបាទាន ១ អត្តវាទុបាទាន ១ ; មច្ឆរិយៈ ៥ គឺ អាសវមច្ឆរិយៈ ១ កុសលមច្ឆរិយៈ ១ វណ្ណមច្ឆរិយៈ ១ លាភមច្ឆរិយៈ ១ ធម្មមច្ឆរិយៈ ១ ; អនុសយៈ ៧ គឺ កាមរាគានុសយៈ ១ ភវរាគានុសយៈ ១ បដិឃានុសយៈ ១ មានានុសយៈ ១ ទិដ្ឋានុសយៈ ១ វិចិកិច្ឆានុសយៈ ១ អវិជ្ជានុសយៈ ១ ; លោកធមិ ៨, មន្ទិល ៩, អកុសលកម្មបថ ១០, សំយោជនៈ ១០, កិលេស ១០, មិច្ឆត្តធមិ ១០, អកុសលចិត្តុប្បាទ ១២, តណ្ហា ១០៨, កិលេស ១៥០០ ។ កិលេសទាំងអម្បាលនេះ មិនបានដិតជាប់ ឬដក់នៅក្នុងខន្ធសន្តានរបស់ព្រះអង្គតិចតួចឡើយ ព្រះអង្គទ្រង់លះបង់បានជាសមុច្ឆេទប្បហាន គឺ ទ្រង់លះបង់ដោយអរិយមគ្គ, ជាបដិបស្សទ្ធិប្បហាន គឺទ្រង់លះបង់ដោយអរិយផល, ជានិស្សរណប្បហាន គឺទ្រង់

លះបង់ដោយនិរោធនិព្វាន ។ ដែលព្រះអង្គទ្រង់ឆ្ងាយចាកកិលេសទាំងនោះ នឹងថា
កិលេសទាំងនោះ រត់គេចចេញអំពីព្រះអង្គ ក៏មិនមែន ឬនឹងថាព្រះអង្គរត់គេចចេញ
អំពីកិលេសទាំងនោះ ក៏មិនមែន ព្រោះកិលេសជាអរូបធមិ មិនមានរូបសណ្ឋាន
ទ្រង់ទ្រាយឡើយ គឺព្រះអង្គគ្រាន់តែដុសខាត់ព្រះទ័យឱ្យស្អាតប៉ុណ្ណោះ កិលេសទាំង
នោះ ក៏សូន្យបាត់ទៅឯង។ ដូចជាទឹងងឹតត្រូវនឹងពន្លឺប្រទីប ។

កិរិយាដែលព្រះអង្គទ្រង់លះកិលេសជាសឹកសត្រូវនោះ មានន័យលោក
ប្រៀបថា ដូចអាការៈរបស់ជាងធ្វើព្រូញ, ធម្មតាជាងធ្វើព្រូញ មុនដំបូងគេនាំយក
ឈើមួយកំណាត់អំពីព្រៃមក ហើយសិតសំបកចេញ លាបប្រេងរោលកំដៅលើ
អម្បែងរងើកភ្លើង រូចសិកទៅក្នុងឈើឃ្នាបគាបឱ្យត្រង់គ្ងរដល់ការបាញ់ចុងរោម
ទ្រាយបាន, លុះធ្វើរូចហើយទើបចូលទៅសំដែងសិល្បសាស្ត្រថ្វាយស្តេច និងពួក
រាជមហាមាត្យ ក៏រមែងបានសក្ការៈ និងការនិយមរាប់អានជាច្រើន, អាការៈនេះ
យ៉ាងណាមិញ, កិរិយាដែលព្រះពុទ្ធជាម្ចាស់ទ្រង់លះកិលេស ក៏យ៉ាងនោះដែរ ទ្រង់
ដំបូង ព្រះអង្គទ្រង់សកព្រះទ័យដែលមានសភាពញាប់ញ័រជាដើម ឱ្យអស់សម្បក
ចេញ គឺឱ្យអស់កិលេសគ្រោតគ្រាតចេញ ដោយអំណាចនៃការរក្សាធុតង្គនៅក្នុង
ព្រៃ ទ្រង់លាបដោយជ័រគឺសទ្ធា ទ្រង់ដុតរោលដោយព្យាយាមផ្លូវកាយ និងព្យាយាម
ផ្លូវចិត្ត ទ្រង់ពត់ដោយឃ្នាបគឺ សមថៈ និងវិបស្សនា ហើយធ្វើព្រះទ័យនោះឱ្យត្រង់
ឱ្យអស់ពុតកំណាចចេញ លុះធ្វើបានយ៉ាងនេះហើយ ទ្រង់ក៏ពិចារណាឱ្យស្គាល់
កំណើតសង្ខារទំលាយបង់ន្ធូវគំនរអវិជ្ជាយ៉ាងធំ, ធ្វើវិជ្ជា ៣ អភិញ្ញា ៦ និងលោកុត្តរ-
ធមិ ៩ ឱ្យតាំងនៅក្នុងកណ្តាប់ព្រះហស្ត ទ្រង់បានជាទក្ខិណេយ្យបុគ្គលឡើងក្នុង
លោក ព្រោះទ្រង់លះកិលេសទាំងនោះបាន មិនឱ្យមានសេសសល់ក្នុងឱ្យសន្តាន ។

ក៏ឯពាក្យថា « កិលេស១ » នោះ បានដល់គ្រឿងធ្វើចិត្តឱ្យសៅហ្មង បើពោលដោយបរិយាយដូចបានរៀបរាប់ពីខាងដើមរួចមកហើយ, តែបើពោលសំដៅយកតែកិលេសដែលជាប្រធានមេគេ មានត្រឹមតែ ៣ គឺ លោភោ[(១)] សភាពញ៉ាំងចិត្តឱ្យជាប់ជំពាក់ក្នុងអារម្មណ៍ ១ ទោសោ[(២)] សភាពញ៉ាំងចិត្តឱ្យប្រទូស្តរអន់រាក់ក្នុងអារម្មណ៍ ១ មោហោ[(៣)] សភាពញ៉ាំងចិត្តឱ្យភាន់ក្នុងអារម្មណ៍ ១ កិលេសទាំង ៣ នេះ ជាឫសគល់កិលេសទាំងអស់ កិលេសក្រៅពីនេះទាំងប៉ុន្មាន កើតចេញទៅតែអំពីកិលេសទាំង ៣ នោះឯង, ឧបមាដូចដើមឈើធំ ៣ ដើម ជាប្រធាននៃមែកតូចនិងមែកធំទាំងពួង ។

ម៉្យាងទៀត ព្រះពុទ្ធជាម្ចាស់ព្រះអង្គមិនគ្រាន់តែឆ្ងាយចាកកិលេសទាំងនោះប៉ុណ្ណោះឡើយ ទ្រង់ឆ្ងាយចាកទាំងវាសនា គឺ ស្មាមគំនួសដែលធ្លាប់ប្រព្រឹត្តពីបុព្វជាតិមកទាំង ២ ប្រការផងទៀត គឺ : កាយបយោគ ទម្លាប់កាយ ឬក្រមាថ៌កាយ ១ វចីបយោគ ទម្លាប់វាចា ឬក្រមាថ៌វាចា ១ ។

ព្រោះហេតុនោះបានជាទ្រង់ព្រះនាមថា « អរហំ » ប្រែថា « ព្រះអង្គជាអ្នកឆ្ងាយ » គឺឆ្ងាយចាកកិលេស និងវាសនា ដូចបានអធិប្បាយមកហើយនេះឯង ។

(១.២.៣) កិលេសទាំង ៣ នេះ មានទោសខុសគ្នាដូច្នេះ លោភៈ មានទោសស្រាល តែកម្រលះបាន (នេះចំពោះតែលោភៈ ដែលមិនប្រកបដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ) ទោសៈ មានទោសធ្ងន់ តែងាយលះបាន មោហៈមានទោសធ្ងន់ផង កម្រលះបានផង ។ លោភៈ លះដោយសមាធិក្ខន្ធ, ទោសៈ លះដោយសីលក្ខន្ធ មោហៈ លះដោយបញ្ញាខន្ធ ។ លោភៈច្រើន នាំសត្វទៅកាន់បិត្តិវិស័យ ទោសៈច្រើននាំសត្វទៅនរក, មោហៈច្រើននាំសត្វទៅតិរិច្ឆាន ។ លោភៈ ចាំងអនិច្ច ទោសៈ ចាំងទុក្ខ មោហៈ ចាំងអនត្តា ។ លោភៈ ញ៉ាំងសត្វមិនឱ្យបានភោគសម្បត្តិ ទោសៈ ញ៉ាំងសត្វមិនឱ្យបានមិត្តសម្បត្តិ មោហៈ ញ៉ាំងសត្វមិនឱ្យតម្កល់ខ្លួនត្រូវ ។ លោភៈ ធ្វើសត្វមិនឱ្យបានសួគ៌, ទោសៈ ធ្វើសត្វមិនឱ្យបានព្រហ្ម, មោហៈ ធ្វើសត្វមិនឱ្យបាននិព្វាន ។

ខ) បុ. ពាក្យថា « ព្រះអង្គជាអ្នកបំបាក់បង់ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះអង្គជាអ្នកបំបាក់បង់ន្ទវសំសារចក្ក ដែលជាគ្រឿងនាំសត្វឱ្យវិលទៅក្នុងវដ្តៈ ។ សំសារចក្កនោះ លោកប្រកបដូច្នេះគឺ អាសវៈ ៤ ទុកជាភ្លៅ, អវិជ្ជា ទុកជាដុំ, សង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម ទុកជាកាំ, ជរា និងមរណៈ ទុកជាខ្នងកង់ ចេតនា ២៩ គឺ កុសលចេតនា ១២, មហាកុសល ៨, រូបាវចរកុសល ៥, អរូបាវចរកុសល ៤ ទុកជាបន្ទូញកាំដែលបញ្ចុះទៅក្នុងដុំ រូមបានជាកង់យកទៅប្រកបនឹងត្ទរថគឺ ភពទាំង ៣ សម្រាប់ផ្ទុកសត្វវិលចុះឡើង នៅតែក្នុងវដ្តសង្សារ បានជាហៅថា សំសារចក្ក ។

ភព ៣ លោកទុកជាត្ទរថ ព្រោះជាទីសម្រាប់សត្វកើត និងសត្វនៅ, អាសវៈ ៤ ទុកជាភ្លៅ ព្រោះជាមេនាំសត្វឱ្យកើត អវិជ្ជាទុកជាដុំ ព្រោះជាមូលហេតុដើម ជរា មរណៈ ទុកជាខ្នងកង់ ព្រោះជាបរិយោសាន, សង្ខារទាំង ៣ ទុកជាកាំ ព្រោះមានអវិជ្ជា និងជរា មរណៈ នៅព័ទ្ធជុំវិញ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ស្ថិតលើផែនប្រឹថពី គឺសីល ដោយព្រះបាទទាំងគូគឺ វីរិយៈ យកព្រះហស្តគឺសទ្ធា ចាប់ព្រះខាន់ថ្លាគឺបញ្ញា កាប់ក្របែលន្ទវសំសារចក្កឱ្យខ្ចាត់ខ្ចាយអស់រលីងទៅ, ទើបបានទ្រង់ព្រះនាមថា « អរហំ » ប្រែថា « អ្នកបំបាក់ » គឺបំបាក់ន្ទវសំសារចក្កនោះឯង ។

គ) បុ. ពាក្យថា « ព្រះអង្គអ្នកគ្ទរ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះអង្គមានគុណ គ្ទរទេវតា និងមនុស្សទាំងឡាយបូជាឬថាព្រះអង្គគ្ទរទទួលន្ទវគ្រឿងបូជារបស់មនុស្ស និងទេវតាទាំងឡាយ ព្រោះការបូជាដែលសត្វឱ្យប្រព្រឹត្តទៅក្នុងព្រះអង្គ ទោះបីបន្តិបន្តួច ក៏គង់មានផលវិសេសវិសាល, ដូចកាលនាយសុមនមាលាការ បានបូជាផ្កាម្លិះ និងចូឡេកសាដកព្រាហ្មណ៍ បានបូជាសំពត់សាដកចំពោះព្រះអង្គ ជាដើម, មានសេចក្តីសរសើរថា គ្រឿងសក្ការ.

ប្ញជា ដែលសត្វនាំយកទៅប្ញជាព្រះអង្គ ហើយមានផលច្រើននោះ មិនចំពោះតែក្នុងកាលដែលព្រះអង្គគង់ធរមាននៅឡើយនោះទេ, ទោះបីក្នុងកាលដែលព្រះអង្គចូលកាន់ព្រះបរមនិព្វានទៅហើយ ឱ្យតែបុគ្គលមានចិត្តជ្រះថ្លា ក៏គង់មានផលច្រើនដូចគ្នា, ដូចន័យដែលមានមកក្នុងមង្គលត្ថទីបនីថា « *តិដ្ឋន្តេ និព្ពុតេ ចាបិ សមេ ចិត្តេ សមំ ផលំ* » កាលដែលព្រះពុទ្ធជាម្ចាស់ទ្រង់ធរមាននៅក្តី កាលដែលព្រះអង្គទ្រង់ចូលព្រះបរមនិព្វានទៅហើយក្តី បើចិត្តរបស់ទាយកអ្នកប្ញជាជ្រះថ្លាស្មើគ្នា ក៏គង់មានផលស្មើគ្នា ។

ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ ព្រះអង្គគួរដើម្បីសំដែង និងបញ្ញត្តធម៌វិន័យដល់ពួកបរិស័ទ ព្រោះព្រះអង្គជាអ្នកឆ្ងាយចាកកិលេសហើយ ធម៌វិន័យដែលព្រះអង្គទ្រង់សំដែង និងបញ្ញត្តនោះ ជាការពិតឥតមានល្អៀង ព្រោះព្រះអង្គទ្រង់សំដែង និងបញ្ញត្តមិនមានលំអៀងដោយអគតិ[1] ទាំង ៤ ណាមួយឡើយ ។

ម្យ៉ាងទៀត បុគ្គលដែលគួរទទួលគ្រឿងសក្ការប្ញជារបស់មនុស្ស និងទេវតានោះ មិនចំពោះតែគួរអង្គព្រះពុទ្ធទេ, ទោះបីព្រះខីណាស្រពងទៀតដែលអស់កិលេសហើយ ក៏គួរទាំងអស់ ទាំងលោកដែលនៅជាសេក្ខបុគ្គលមិនទាន់អស់កិលេសនៅឡើយ ក៏គង់គួរដែរ, ដោយហោចទៅ សូម្បីតែបុថុជ្ជនអ្នកមានសីល ក៏គង់រាប់បញ្ចូលថាគួរផងបាន, តែទុកណាជាដូច្នោះ ក៏មិនមែនគួរយ៉ាងវិសេសដូចជាព្រះពុទ្ធឡើយ ព្រោះហេតុនោះទើបទ្រង់ព្រះនាមថា « អរហំ » ប្រែថា « ព្រះអង្គជាអ្នកគួរ » គឺគួរទទួលនូវគ្រឿងសក្ការប្ញជារបស់មនុស្ស និងទេវតាជាដើម វិសេសជាងបុគ្គលឯទៀតទាំងអស់ ។

---

(១) គឺមិនមែនបញ្ញត្តដោយលំអៀងព្រោះស្រឡាញ់, ព្រោះស្អប់, ព្រោះល្ងង់, ព្រោះខ្លាចឡើយ ។

ឃ) បុ. ពាក្យថា «ព្រះអង្គជាអ្នកមិនមានទីកំបាំង» អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះអង្គមិនមានឱកាសស្ថាត់កំបាំងនឹងធ្វើបាប គឺថា ព្រះអង្គមិនពូនសំងំធ្វើបាបក្នុងទីកំបាំង ។

បុ. បើក្នុងទីកំបាំងព្រះអង្គមិនធ្វើបាប, ចុះដល់មកចំពោះមុខគេ ព្រះអង្គធ្វើបាបឬអ្វី ?

វិ. ក្នុងទីស្ថាត់កំបាំងព្រះអង្គមិនធ្វើទៅហើយ ចាំនិយាយថ្វីដល់ទីចំពោះមុខគេ ។ ព្រះអង្គមិនដូចជាមនុស្សសាមញ្ញ ទេ, ធម្មតាមនុស្សសាមញ្ញ ពួកខ្លះ ក្នុងទីចំពោះមុខគេមិនហ៊ានធ្វើបាប តែដល់កំបាំងពីមុខគេលបសំងំធ្វើបាប ឥតមានញញើត ។ ហេតុនេះ ព្រះអង្គទើបទ្រង់ព្រះនាមថា « អរហំ » ប្រែថា « ព្រះអង្គមិនជាអ្នកមានទីស្ថាត់កំបាំង » គឺព្រះអង្គមិនដែលលបធ្វើបាបក្នុងទីកំបាំងឡើយ ។

ចប់ព្រះនាម « អរហំ » ដោយសង្ខេប

កែបទ « **សម្មាសម្ពុទ្ធោ** »

បុ. សម្តេចព្រះសរពេជ្ជជាម្ចាស់ ហេតុអ្វីបានជាទ្រង់ព្រះនាមថា « សម្មា-សម្ពុទ្ធោ » ?

វិ. បានជាទ្រង់ព្រះនាមថា « សម្មាសម្ពុទ្ធោ » ព្រោះព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ។

សូមស្រង់សំដីដែលវិសជ្ជនាមកនុ៎ះ ធ្វើជាពាក្យ ៣ ម៉ាត់ គឺត្រាស់ដឹង ១ ម៉ាត់, ដោយប្រពៃ ១ ម៉ាត់, ចំពោះព្រះអង្គឯង ១ ម៉ាត់ ដើម្បីធ្វើជាខបុច្ឆា តទៅ ។

ក) បុ. ពាក្យថា «ព្រះអង្គត្រាស់ដឹង» នោះ តើត្រាស់ដឹងនូវធម៌អ្វីខ្លះ ?

វិ. « *ចត្តារិ សច្চានិ សម្មាសម្ពុទ្ធោ* » ព្រះអង្គត្រាស់ដឹងនូវធម៌ពិត ៤ ប្រការគឺ : ទុក្ខ ១ សមុទយ ១ និរោធ ១ មគ្គ ១ ដែលហៅថា « អរិយសច្ច » ប្រែថា « ធម៌ពិតរបស់ព្រះអរិយៈ ធម៌ពិតនាំឱ្យឆ្ងាយចាកសឹកសត្រូវ, ធម៌ពិតញ៉ាំងភាពជាព្រះអរិយៈឱ្យសម្រេច, ធម៌ពិតដ៏ប្រសើរ » ។

ដែលប្រែថា « ធម៌ពិតនាំឱ្យឆ្ងាយចាកសឹកសត្រូវ » អធិប្បាយថា កិលេសធម៌ដ៏លាមកទាំងពួង ឈ្មោះថាសឹកសត្រូវ, លោកដែលត្រាស់ដឹងនូវអរិយ-សច្ចទាំង ៤ នេះហើយ, សឹកសត្រូវទាំងនោះ មិនមានក្នុងសន្តានរបស់លោកឡើយ លោកក៏បានឃ្លាតឆ្ងាយចាកសឹកសត្រូវទាំងនោះ ។

ដែលប្រែថា « ធម៌ពិតញ៉ាំងភាពជាព្រះអរិយៈឱ្យសម្រេច » អធិប្បាយថា ធម៌ពិតទាំង ៤ ប្រការនេះ បើលោកណាដឹងច្បាស់ដោយបញ្ញាថា « នេះទុក្ខ, នេះហេតុនាំឱ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះផ្លូវប្រតិបត្តិដើម្បីរលត់ទុក្ខ » ដូច្នេះ ព្រមដោយបរិវដ្តៈ ៣, អាការៈ ១២ ហើយ ក៏អាចធ្វើលោកនេះឱ្យសម្រេចជាព្រះអរិយៈបាន ។

ដែលប្រៃថា « ធម៌ពិតដ៏ប្រសើរ » អធិប្បាយថា ធម៌ទាំង ៤ នេះ ជាធម៌ពិតមែន គឺទុក្ខៈ ពិតជាទុក្ខមែន សមុទយៈ ហេតុនាំឱ្យកើតទុក្ខ ពិតជាហេតុនាំឱ្យកើតទុក្ខមែន, និរោធៈ សេចក្តីរំលត់ទុក្ខ ពិតជារំលត់ទុក្ខមែន, មគ្គៈ សេចក្តីប្រតិបត្តិដើម្បីរំលត់ទុក្ខ ពិតជារំលត់ទុក្ខបានមែន, ដូច្នេះបានជាហៅថា « ធម៌ពិតដ៏ប្រសើរ » ។

ក៏ពាក្យថា « ទុក្ខ » នេះ បើពោលរួបរួមមក ប្រជុំនៅតែត្រឹមខន្ធ ៥ តាមបាលីថា *សង្ខិត្តេន បញ្চុបាទានក្ខន្ធា ទុក្ខា* ខន្ធ ៥ ដែលជាកំណួចរបស់ឧបាទាន ហៅថា « ទុក្ខ » ដោយបំប្រួញ ។

ពាក្យថា « សមុទយៈ » សំដៅយកតណ្ហា ។ តណ្ហាចែកចេញជា ៣ យ៉ាងគឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ តណ្ហាទាំង ៣ ប្រការនេះ ជាហេតុនាំឱ្យកើតទុក្ខ កាលបើតណ្ហាដែលជាមេបណ្តាលឱ្យកើតទុក្ខរលត់ហើយ, ទុក្ខក៏រលត់បាត់ទៅផង ។

ពាក្យថា « និរោធៈ » សំដៅយកព្រះនិព្វាន ។ ព្រះនិព្វាននេះជាទីរលត់ទៅនៃទុក្ខទាំងអស់, ទុក្ខទាំងប៉ុន្មានរលត់ទៅសូន្យត្រឹមព្រះនិព្វាននោះឯង ។

ពាក្យថា « មគ្គៈ » សំដៅយកអដ្ឋង្គិកមគ្គ គឺផ្លូវប្រតិបត្តិដែលប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិ ជាដើម ដែលជាផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វាន ជាគ្រឿងសម្លាប់តណ្ហាបាន ។ មគ្គ៌នេះ បើពោលដោយការសង្គ្រោះនៅត្រឹមតែ ៣ ប្រការ គឺសង្គ្រោះដោយសីល[1] ១ សមាធិ ១ បញ្ញា ១ ។

---

(១) សម្មាទិដ្ឋិ សម្មាសង្កប្បោ ពីរនេះលោកសង្គ្រោះដោយបញ្ញា ។ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ បីនេះលោកសង្គ្រោះដោយសីល ។ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ បីនេះលោកសង្គ្រោះដោយសមាធិ ។

« និព្វានំ សម្មាសម្ពុទ្ធោ » សម្តេចព្រះលោកនាថជាម្ចាស់ព្រះអង្គត្រាស់ដឹងនូវព្រះនិព្វាន ៣ ប្រការគឺ កិលេសនិព្វាន ១ ខន្ធនិព្វាន ១ ធាតុនិព្វាន ១ ។

កិលេសនិព្វាន បានដល់កិរិយារឹងស្ងួតកិលេស តួយ៉ាងដូចកាលព្រះអង្គទ្រង់គង់លើរតនបល្ល័ង្ក ក្បែរពោធិព្រឹក្ស ទ្រង់ផ្ចាញ់មារាធិរាជ ព្រមទាំងពួកពលឱ្យបរាជ័យ ជាក់បបខ្ជបខ្ជាច ចុះចាញ់ព្រះអង្គ ហើយទ្រង់រំពឹងដល់ពុទ្ធប្បវេណីដោយឈានសមាបត្តិ លះបង់នូវរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ព្រមទាំងកិលេស ១៥០០ តណ្ហា ១០៨ ឱ្យឃ្លាតពីសន្តានព្រះអង្គ ដូចដំណក់ទឹកដែលជ្រុះចុះចាកស្លឹកឈូក, យ៉ាងនេះហៅថា « កិលេសនិព្វាន » ។

ពេលដែលព្រះអង្គទ្រង់បានកិលេសនិព្វាននោះ ព្រះអង្គទ្រង់បន្លឺនូវឧទាន. វាចាថា :

អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្ពិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ (១)

អធិប្បាយតាមលំអានព្រះពុទ្ធដីកានេះថា

កាលដែលតថាគតកំពុងស្វែងរកជាងឈើគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្ត. ភាពរបស់តថាគត កាលដែលមិនទាន់បានជួបប្រទះនៅឡើយ តថាគតតែងតែអន្ទោលទៅកាន់សំសារវដ្តរាប់ជាតិជាអនេក (ម្ល៉ោះហើយ) ជាតិក៏តែងនាំសេចក្តី

(១) ព្រះពុទ្ធដីកានេះ ហៅថា « បឋមពុទ្ធវចនៈ » ។

ទុក្ខមកឱ្យតថាគតរឿយៗ ឥតស្រាកស្រាន្តឡើយ, នៃជាងផ្ទះ ឥឡូវតថាគតរកអ្នកយើញហើយណ៎ា : ពីនេះទៅ អ្នកឯងអស់ធ្វើផ្ទះគឺអត្តភាពឱ្យតថាគតបានទៀតហើយ បង្កង់គឺកិលេសដ៏សេសទាំងឡាយរបស់អ្នកឯង តថាគតកាច់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជាដែលអ្នកឯងធ្វើរួចហើយ (នោះ) តថាគត ក៏បានកំចាត់បង់ហើយ ឥឡូវនេះ ចិត្តរបស់តថាគតបានដល់ព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគតបានត្រាស់ដឹងនូវព្រះអរហត្តដែលជាធម៌ក្សីណាសវាទាំងឡាយហើយ ។

ឯខន្ធនិព្វាននោះ ត្តយ៉ាងដូចសម្តេចព្រះសរពេជ្ជពុទ្ធអង្គ ទ្រង់បានដល់នូវព្រះសព្វញ្ញុតញ្ញាណ ហើយទ្រង់គង់នៅប្រាសសត្វបានចំនួន ៤៥ ព្រះវស្សា ហើយស្តេចយាងទៅផ្ទំលើទែនសិលាសនៈក្រោមលង្វែកមែកវាំងទាំងគូរ ក្បែរនគរកុសិនារា ស្តេចចូលកាន់ឈានសមាបត្តិហើយ លះបង់ព្រះជន្មាយុសង្ខារ ទ្រង់ព្រះដំណើរចូលទៅកាន់ព្រះនិព្វានរំលត់រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ឥតមានវិបាកក្ខន្ធ និងកម្មរួបសេសសល់តិចតួចឡើយ, យ៉ាងនេះហៅថា ខន្ធនិព្វាន គឺរលត់សូន្យទៅនៃបញ្ចក្ខន្ធ ។

ឯធាតុនិព្វាននោះ កំណត់ត្រឹមព្រះពុទ្ធសាសនាគ្រប់ ៥000 ព្រះវស្សា ហើយ ព្រះបរមធាតុសម្តេចព្រះមុនីនាថជាម្ចាស់ទាំងប៉ុន្មាន ដែលទៅប្រតិស្ឋាននៅក្នុងតំបន់ផ្សេងៗ ក៏អណ្តែតត្រសែតមកប្រជុំសមោធានជាអង្គព្រះសម្មាសម្ពុទ្ធ ដូចជាមានព្រះជន្មាយុទ្រង់នៅដូចដើម ហើយទ្រង់គង់ផ្គត់ព្រះភ្នែនលើរតនបល្ល័ង្ក ត្រង់កន្លែងមហាពោធិព្រឹក្ស ទ្រង់ព្រះមហាបុរិសលក្ខណៈ ៣២, អនុព្យញ្ជនៈ ៨0, ព្រះឆព្វណ្ណរង្សី ៦ ប្រការ, ទ្រង់សំដែងព្រះបាដិហារ្យអស់ ៧ ទិវា ពួកទេវតា ឥន្ទ ព្រហ្ម ទាំងឡាយសឹងមានដៃកាន់នីទៅនូវភួងបុប្ផា កម្រងមាលា សក្ការៈគ្រប់ប្រការ ចុះ

ចាកចេញពីស្ថានវិមានរបស់ខ្លួន នាំគ្នាគីកកងមកថ្វាយបង្គំប្រណម្យ នមស្សការបូជា ជានសម្រេចធមិវិសេសជាន់ខ្ពស់ តាំងពីសោតារហូតដល់ព្រះអរហត្ត រាប់ចំនួនជាន ២៤ អសង្ខេយ្យ ៦ លាន ៦ សែន ៧ ពាន់ ៨០ កោដិ ។ ដល់គ្រប់កំណត់ ៧ ថ្ងៃ ហើយ តេជោធាតុ ក៏តាំងឡើងប្រល័យអង្គព្រះពុទ្ធរូបព្រះបរមធាតុឱ្យសុះសូន្យអស់ ទៅ, យ៉ាងនេះហៅថា ធាតុនិញ្ចាន គឺសូន្យទៅនៃព្រះធាតុ ។

« *អភិញ្ញេយ្យេ ធម្មេ សម្មាសម្ពុទ្ធោ* » ព្រះលោកនាថសាស្តាចារ្យ ទ្រង់ជ្រាបនូវញេយ្យធមិគឺទុក្ខសច្ច ដែលមានលក្ខណៈ ១២ គឺ *ជាតិទុក្ខ* សេចក្តីទុក្ខ មានជាតិជាបច្ច័យ រាប់ចាប់ដើមតាំងតែអំពីចូលមកចាប់បដិសន្ធិក្នុងផ្ទៃមាតា ជាន សេចក្តីក្តៅក្រហាយជានិរន្តរ៍ឥតស្រាកស្រាន្ត ១, *ជរាទុក្ខ* ទុក្ខមានការចាស់គ្រាំគ្រា ជាបច្ច័យ រាប់តាំងពីប្រសូតចេញចាកគភិមាតារៀងមក ដោយសារូបរាងកាយនេះ ចេះតែទ្រុឌទ្រោម គ្រាំគ្រាទៅ ១, *ព្យាធិទុក្ខ* ទុក្ខមានរោគដែលយាយីប្យៀតប្យៀន ឱ្យឈឺចាប់ជាបច្ច័យ ១, *មរណទុក្ខ* ទុក្ខមានសេចក្តីស្លាប់ជាបច្ច័យ ព្រោះថា កាល បើព្យាធិចូលមកលុកលុយរូបកាយហើយ មរណៈក៏ទន្ទ្រានចូលមកជិត, ម្ល៉ោះហើយ សត្វក៏កើតទុក្ខព្រួយជាពន្លឹក ព្រោះឃើញមរណៈនៅស្ទាក់រាំងពីមុខ ១, *សោកទុក្ខ* ទុក្ខបណ្តាលឱ្យស្តាយស្រណោះចំពោះសត្វ និងសង្ខារជាទីស្រឡាញ់ ដែលព្រាត់ ប្រាសទៅ ១, *បរិទេវទុក្ខ* ទុក្ខបណ្តាលឱ្យតំអូញរៀបរាប់ពីការកំសត់កម្រផ្សេងៗ ចំពោះសត្វ និងសង្ខារដែលព្រាត់ទៅ ១, *ទុក្ខទុក្ខ* ទុក្ខលំបាកតែចំណែកផ្លូវកាយ ដោយការនឿយហត់ផ្សេងៗ ១, *ទោមនស្សទុក្ខ* ទុក្ខព្រោះសេចក្តីអាក់អន់ត្រូចចិត្ត ចំពោះអារម្មណ៍ ដែលឃ្នើសឃ្នងដល់ចិត្ត ១, *ឧបាយាសទុក្ខ* ទុក្ខបណ្តាលឱ្យអូល អាក់ក្នុងចិត្ត ព្រោះនឹកឃើញដល់សត្វ និងសង្ខារ ជាទីស្រឡាញ់ ដែលព្រាត់ប្រាសទៅ យូរហើយ ១, *អប្បិយេហិសម្បយោគទុក្ខ* ទុក្ខព្រោះជួបប្រសព្វសត្វ និងសង្ខារ

ដែលមិនត្រូវចិត្ត ១, *បិយេហិវិប្បយោគទុក្ខ* ទុក្ខព្រោះព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារ ដែលខ្លួនពេញចិត្ត ១, *យម្បិច្ឆំ ន លភតិ តម្បិទុក្ខ* ទុក្ខកើតមកអំពីប្រាថ្នាមិនបានដូចបំណង ចង់បានរបស់ណាមិនបានរបស់នោះ ១, *សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា* ទុក្ខទាំងអស់ប្រមូលមកមានតែឧបាទានក្ខន្ធទាំង ៥ ជាមេទុក្ខ ។ ទុក្ខទាំង ១២ ប្រការនេះ ឈ្មោះថា អភិញ្ញេយ្យធម៌ ។

« *បរិញ្ញេយ្យេ ធម្មេ សម្មាសម្ពុទ្ធោ* » សម្តេចព្រះជនន្ទ្រីសាស្តាទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរកំណត់ដឹង គឺទុក្ខសច្ចមានអង្គ ១២ ដូចបានអធិប្បាយរួចមកហើយ ។

« *បហាតព្វេ ធម្មេ សម្មាសម្ពុទ្ធោ* » សម្តេចព្រះសរពេជ្ញទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរលះចង់ គឺសមុទយសច្ច បានដល់តណ្ហាទាំង ៣ ដោយសង្ខេប ឬតណ្ហាទាំង ១០៨ ដោយពិស្តារ ។

« *សច្ឆិកាតព្វេ ធម្មេ សម្មាសម្ពុទ្ធោ* » សម្តេចព្រះសរពេជ្ញទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ គឺនិរោធសច្ច បានដល់ព្រះនិព្វានដែលអ្នកប្រាជ្ញទាំងឡាយគួរធ្វើឱ្យជាក់ច្បាស់ដោយមគ្គញ្ញាណទាំង ៤ ។

« *ភាវេតព្វេ ធម្មេ សម្មាសម្ពុទ្ធោ* » សម្តេចព្រះសរពេជ្ញទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរចំរើន គឺមគ្គសច្ច បានដល់អរិយមគ្គដែលប្រដាប់ដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិ ជាដើម ។

អធិប្បាយកៃប្រស្នាថា « ព្រះអង្គត្រាស់ដឹងនូវធម៌អ្វី » អស់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះ ។ តែសូមជ្រាបថា ធម៌ដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះមិនត្រឹមតែប៉ុណ្ណោះឡើយ, ច្រើនពេកណាស់, តែបើនិយាយឱ្យឆាប់ចប់វិញថា

ព្រះអង្គត្រាស់ដឹងសព្ធ គ្មានចន្លោះ ។

ខ) បុ. ពាក្យថា « ព្រះអង្គត្រាស់ដឹង » នោះ គ្ធរសន្ទិដ្ឋានបានហើយ, ចុះពាក្យថា « ដោយប្រពៃ » នោះ អធិប្បាយដ្ធចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងន្ធវធមិងណា ឬធមិងណាដែលព្រះអង្គត្រាស់ដឹងហើយ ធមិនោះ។ មិនវិបរិតប្រែប្រួល គឺមិនមានល្អៀងឃ្លាតចាកការដឹងរបស់ព្រះអង្គ ព្រោះព្រះអង្គជ្រាបដោយការជាក់លាក់ មិនបានស្មាន ឬមិនបានត្រិះរិះប្រកបយកឡើយ ។

គ) បុ. ចុះពាក្យថា « ចំពោះព្រះអង្គ » តើបានសេចក្តីយ៉ាងណា ?

វិ. បានសេចក្តីថា ព្រះបរមសាស្តាទ្រង់ត្រាស់ដឹងធមិទាំងព្ធងគ្មានចន្លោះចំពោះព្រះអង្គយ៉ាងនេះ មិនមែនត្រាស់ដឹងដោយសារបុគ្គលណាប្រៀនប្រដៅ ឬណែនាំពន្យល់ឱ្យព្រះអង្គត្រាស់ដឹងឡើយ គឺទ្រង់ត្រាស់ដឹងតែដោយកំឡាំងប្រាជ្ញាញាណរបស់ព្រះអង្គឯង ហេតុនោះទើបទ្រង់ព្រះនាមថា « សម្មាសម្ពុទ្ធោ » ប្រែថា « ព្រះអង្គទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ » ។

ចប់បទ « សម្មាសម្ពុទ្ធោ » ដោយសង្ខេប

កែបទ « វិជ្ជាចរណសម្បន្នោ »

បុ. ចុះហេតុអ្វីបានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា « វិជ្ជាចរណ-សម្បន្នោ » ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គបរិបូណិដោយវិជ្ជានិងចរណៈ។

បុ. អ្វីហៅថា « វិជ្ជា » ? មានប៉ុន្មានយ៉ាង ?

វិ. ចំណេះ ការចេះដឹង ហៅថា « វិជ្ជា » មាន ៣ ក៏មាន ៨ ក៏មាន ។

បុ. វិជ្ជា ៣ តើអ្វីខ្លះ ? អធិប្បាយដូចម្តេច ?

វិ. បុព្វេនិវាសានុស្សតិវិជ្ជា ១ ចុតូបបាតវិជ្ជា ១ អាសវក្ខយវិជ្ជា ១ ។

• *បុព្វេនិវាសានុស្សតិវិជ្ជា* អធិប្បាយថា ព្រះសាស្តាទ្រង់រឲកខន្ធរបស់ព្រះអង្គ និងខន្ធរបស់សត្វដទៃ ដែលធ្លាប់អាស្រ័យនៅពីក្នុងកាលមុនជាអនេកជាតិ រាប់តាំងពី ១ ជាតិ ២ ជាតិឡើងទៅ រហូតដល់អស់សំវដ្តកប្ប វិវដ្តកប្ប សំវដ្តវិវដ្ត-កប្ប ជាអនេក គឺទ្រង់រឲកឃើញថា កាលពីជាតិនោះ កើតក្នុងភពឯណោះ មាននាមយ៉ាងនេះ គោត្រយ៉ាងនេះ ពណិសម្បុរយ៉ាងនេះ អាហារចិញ្ចឹមជីវិតយ៉ាងនេះ អាយុប៉ុណ្ណេះ លុះច្យុតចាកអត្តភាពនោះមក ក៏បានទៅកើតក្នុងភពឯណោះ១ទៀត ជាលំដាប់ ។ យ៉ាងនេះហៅថា បុព្វេនិវាសានុស្សតិវិជ្ជា ជាវិជ្ជាទី ១ ដែលព្រះតថាគតបានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី ។

• *ចុតូបបាតវិជ្ជា* អធិប្បាយថា ព្រះភគវន្ត កាលប្បើព្រះអង្គទ្រង់ពិចារណាមើលពួកសត្វដែលទៀបច្យុត និងទើបចាប់បដិសន្ធិ ដោយចក្ខុទិព្វដ៏បរិសុទ្ធក្រៃលែងចក្ខុរបស់មនុស្សជាសាមញ្ញក៏ទ្រង់ទតឃើញច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា : អើហ្ម៉ ! សត្វពួកណាប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវអំពើជាមិច្ឆាទិដ្ឋិ ពោលតិះដៀលព្រះអរិយៈ សត្វពួកនោះ លុះដល់រំលាង

ខន្ធខាងមុខអំពីមរណៈទៅ ក៏ចូលទៅកើតក្នុងអបាយ[1], ទុគ្គតិ[2], វិនិបាត[3], នរក[4] អើហ្ន៎ ! សត្វពួកណាប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវអំពើជាសម្មាទិដ្ឋិ មិនពិះដៀលព្រះអរិយៈ សត្វពួកនោះ លុះអំលាងខន្ធខាងមុខអំពីមរណៈទៅ ក៏ចូលទៅកាន់ស្ថានសុគតិ[5] សុគតិ[6] ។ យ៉ាងនេះហៅថា ចុតូបបាតៈ-ញាណ ជាវិជ្ជាទី ២ ដែលព្រះតថាគតបានត្រាស់ដឹងក្នុងមជ្ឈិមយាមនៃរាត្រី ។

• *អាសវក្ខយវិជ្ជា* អធិប្បាយថា ព្រះលោកនាថទ្រង់ត្រាស់ដឹងតាមពិតថា នេះទុក្ខ, នេះហេតុបណ្តាលឱ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះឧបាយនាំឱ្យបានរំលត់ទុក្ខ, ធម៌ប៉ុណ្ណេះហៅថា អាសវៈ ធម៌នេះជាហេតុនាំឱ្យកើតអាសវៈ នេះជាសេចក្តីរំលត់នៃអាសវៈ, នេះជាឧបាយនាំឱ្យរលត់អាសវៈ ។ យ៉ាងនេះហៅថា អាសវក្ខយវិជ្ជា ជាវិជ្ជាទី ៣ ដែលព្រះតថាគតទ្រង់បានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី ។

បុ. ចុះវិជ្ជា ៨ អ្វីខ្លះ ?

ឆ. *វិបស្សនាវិជ្ជា ១ មនោមយិទ្ធិវិជ្ជា ១ ឥទ្ធិវិធិវិជ្ជា ១ ទិព្វសោតវិជ្ជា ១ ចេតោបរិយវិជ្ជា ១* រួមនឹងវិជ្ជា ៣ ខាងដើមត្រូវជា ៨ ប្រការ ។

បុ. ដូចម្តេចហៅថា វិបស្សនាវិជ្ជា ?

ឆ. *អនិច្ចាទីវសេន នាមរូបំ វិបស្សតិ ឧបបរិក្ខតីតិ វិបស្សនា* បញ្ញាដែលពិចារណាឃើញជាក់ច្បាស់នូវនាម[7]និងរូប[8] ដែលលុះដោយអំណាចនៃព្រះត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ហៅថា « វិបស្សនា » ។

---

(១) កំណើតសត្វតិរច្ឆាន ។ (២) ប្រេតវិស័យ ។ (៣) អសុរកាយដែលមានមហិទ្ធិវិទ្ធិ ដូចជារាហុអសុរិន្ទជាដើម ។ (៤) លោកដែលគ្មានសេចក្តីចំរើន មានប្រការច្រើន មានអវិចីនរក ជាដើម ។ (៥) សង្រ្គោះយកគតិរបស់មនុស្ស ។ (៦) ចំពោះយកគតិរបស់ទេវតា ។ (៧) បានដល់អរូបក្ខន្ធ ៤ គឺ វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ។ (៨) បានដល់រូប ២៨ ។

• *វិបស្សនា*(*) នេះឯង ចាត់ជាវិជ្ជា ១ ដែលព្រះសាស្តាទ្រង់បានមុនវិជ្ជាទាំង ៧ ព្រោះវិជ្ជានេះ ជាគ្រឿងឈ្វេងយល់នូវត្រៃលក្ខណ៍ថា នាមនិងរូបមិនទៀងទាត់ មិនឋិតថេរចិរកាលយូរលង់ តែងដឹកជញ្ជូនបង្អូរមកនូវកងទុក្ខ និងមិនមែនជាខ្លួនប្រាណ មិនលុះតាមបង្គាប់ ជាធម្មជាតឃាត់មិនបាន ។ លុះឈ្វេងយល់យ៉ាងនេះហើយ ទើបឃើញអរិយសច្ចទាំង ៤ ។ ព្រះជាគ្រូទ្រង់ផ្តាញ់មារាធិរាជ ព្រមទាំងសេនាឱ្យបរាជ័យដោយបារមីទាំង ១០ ហើយស្តេចចូលកាន់សមាបត្តិ, ដល់ចេញចាក

(*) មាន ១០ យ៉ាងគឺ :

១. សម្មសនញ្ញាណ បញ្ញាពិចារណាឃើញសង្ខារដោយអនិច្ចាទិលក្ខណៈ ។

២. ឧទយព្វយញ្ញាណ បញ្ញាពិចារណានូវសភាពកើតឡើង និងរលត់ស្ងួតទៅនៃសង្ខារ ។

៣. ភង្គញ្ញាណ បញ្ញាពិចារណានូវកិរិយាបែកធ្លាយនៃសង្ខារ គឺឃើញថាជាឧប្បាទ ឋិតិ ភង្គ, ឧប្បាទ ជាជាតិទុក្ខ, ឋិតិ ជាជរាទុក្ខ, ភង្គៈ ជាមរណទុក្ខ ។

៤. ភយញ្ញាណ បញ្ញាពិចារណាឃើញសង្ខារថាជាធម្មជាតិគួរខ្លាច ដូចគេខ្លាចសត្វសាហាវមានរាជសីហ៍ជាដើម ។

៥. អាទីនវញ្ញាណ បញ្ញាពិចារណាឃើញទោសរបស់សង្ខារ មិនគួរឱ្យស្មគ្រចិត្ត ដូចគេឃើញផ្ទះដែលភ្លើងឆេះ ហើយភៀសខ្លួនចេញពីផ្ទះនោះ ។

៦. និព្វិទាញ្ញាណ បញ្ញាពិចារណាឃើញទោសក្នុងសង្ខារ ហើយធុញទ្រាន់នឿយណាយ ។

៧. មុញ្ចិតុកាម្យតាញ្ញាណ បញ្ញាប្រាថ្នាចង់ដោះខ្លួនឱ្យរួចពីខន្ធ ៥ ប្រៀបដូចជាត្រីរួចចាកទីគោក ឬដូចជាមនុស្សទោសចង់រួចពីគុកច្រវាក់ខ្នោះឃ្នាង ។

៨. បដិសង្ខារញ្ញាណ បញ្ញាពិចារណារកឧបាយដែលនឹងឱ្យដោះខ្លួនរួចពីខន្ធ ៥ ។

៩. សង្ខារុបេក្ខាញ្ញាណ បញ្ញាតាំងឧបេក្ខាគឺតោះតើយមិនសោមនស្ស មិនទាស់ចិត្ត ដូចបុរសដែលព្រងើយកន្តើយនឹងប្រពន្ធដែលលែងលះគ្នាស្រឡះហើយ ។

១០. អនុលោមញ្ញាណ បញ្ញាដែលអនុលោមតាមព្រះអរិយមគ្គទាំងខាងក្នុងខាងក្រៅ ។

សមាបត្តិមកវិញ ទើបស្តេចកាន់យកវិបស្សនា ឆ្លុះបញ្ចាំងមើលសង្ខារ តាមប្រពៃណីព្រះពុទ្ធអំពីបុរាណថាជា *អនិច្ចំ ទុក្ខំ អនត្តា* ហើយទើបចាក់ឆ្លុះអរិយសច្ចទាំង ៤ ប្រការថា ទុក្ខសច្ច មានខន្ធ ៥ ជាមេទុក្ខគួរឱ្យខ្លាច ប្រៀបដូចជាមេខ្មាំង ៥ នាក់ តាមពាធាយាយីជាធម្មតា, សមុទយសច្ច តណ្ហាទាំង ៣ ប្រការ ដូចជាអ្នកបង្គាញផ្លូវខ្មាំងឱ្យចូលមក និរោធសច្ច ព្រះនិព្វានជាគ្រឿងបិទស្ទះដំណើរខ្មាំង, មគ្គសច្ច អដ្ឋង្គិកមគ្គទាំង ៨ ជាឧបាយនឹងសម្លាប់ពួកខ្មាំង ។

លុះរកកំណើតសេចក្តីទុក្ខឃើញ ដោយវិបស្សនាបញ្ញា យ៉ាងនេះហើយ ទើបទ្រង់លះសំយោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ដោយកម្លាំងសោតាបត្តិមគ្គញ្ញាណ, លះកាមរាគៈ, ព្យាបាទ យ៉ាងគ្រោតគ្រាតដោយសកទាគាមិមគ្គញ្ញាណ, លះកាមរាគៈ ព្យាបាទ យ៉ាងល្អិត ដោយអនាគាមិមគ្គញ្ញាណ, លះសំយោជនៈ ៥ គឺរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ **អវិជ្ជា ដោយអរហត្តមគ្គញ្ញាណ** ។ គ្រានោះ សន្តានរបស់ព្រះអង្គបរិសុទ្ធក្រៃលែង, **អរហត្តផលក៏កើតឡើង** វិជ្ជាទាំង ៧ ក្រៅពីនេះទើបកើតមកជាខាងក្រោយ ។ ហេតុនោះទើបចាត់ថាវិបស្សនាវិជ្ជា កើតមុនវិជ្ជាទាំងពួង ឬនិងជាព្រះសាស្តាទ្រង់បាននូវវិជ្ជានេះតាំងពីកាលនៅគ្រប់គ្រងរាជសម្បត្តិនៅឡើយក៏សឹងបាន ក្នុងគ្រាដែលទ្រង់ទតឃើញទេវទូតទាំង ៣ ខាងដើមគឺ មនុស្សជរា មនុស្សឈឺ មនុស្សស្លាប់ ព្រោះដោយសារតែរឿងនេះហើយ ទើបទ្រង់ព្រះសង្វេគជាខ្លាំង ទ្រាំនៅពុំបានដល់ថ្នាក់ចេញចោលរាជសម្បត្តិទៅទ្រង់ព្រះផ្នួស ។

• *មនោមយិទ្ធិវិជ្ជា* គឺវិជ្ជាដែលចេះផ្លែងរឹទ្ធិធ្វើចិត្តឱ្យទៅជារូបបាន ;

អធិប្បាយថា ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គមានវិជ្ជាអាចនឹងនិម្មិតចិត្តខាងក្នុងឱ្យទៅជារូបកាយផ្សេងចេញពីកាយនេះមកបានប្រាកដ ដូចជាមាឡូហូតបណ្តូលស្បែយាប្តូងចេញពីដើម ។

• *ឥទ្ធិវិធិវិជ្ជា* គឺវិជ្ជាដែលចេះសំដែងរឺទ្ធិបាន ដោយប្លែង ឬអធិដ្ឋាន ;

អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវិជ្ជាអាចនឹងប្លែង ឬអធិដ្ឋានមនុស្សម្នាក់ឱ្យទៅជាច្រើននាក់បាន, ច្រើននាក់ឱ្យរួមមកនៅតែម្នាក់បាន ឬប្លែងរបស់នេះឱ្យទៅជារបស់នោះ។ ឱ្យមកជារបស់នេះក៏បាន ឥតមើសមាក់ ។

• *ទិព្វសោតវិជ្ជា* គឺវិជ្ជាដែលអាចស្តាប់ស្ងរសព្ទសំឡេងបាន ដូចជាទិព្វ-សោត ;

អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់មានវិជ្ជាអាចស្តាប់ស្ងរស័ព្ទសំឡេងមនុស្ស និងទេវតា ដែលស្ថិតនៅក្នុងទីជិតឆ្ងាយយ៉ាងណា ក៏បានទាំងអស់ ។

• *ចេតោបរិយវិជ្ជា* គឺវិជ្ជាអាចកំណត់ដឹងចិត្តអ្នកដទៃបាន ;

អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបទឹកចិត្តសត្វដទៃបានប្រាកដថា ចិត្តសត្វនេះជាបុណ្យ នេះជាបាប នេះអស់រាគៈ ហើយនេះមានរាគៈ នៅឡើយ ជាដើម ។ រួបរួមវិជ្ជាទាំង ៥ នេះ ផ្សំនឹងវិជ្ជា ៣ ខាងដើម ត្រូវជាវិជ្ជា[1] ៨ ។

ប្. អ្វីហៅថា « ចរណៈ » មានប៉ុន្មានយ៉ាង ?

វិ. ក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ឬសេចក្តីប្រព្រឹត្ត ដែលជាដំណើរទៅកាន់អមតមហានិព្វាន ហៅថា « ចរណៈ » មាន ១៥ យ៉ាងគឺ *សីលសំវរៈ* សង្រួមរក្សាបាតិមោក្ខសំវរសីលម៉ត់ចត់ ១, *ឥន្ទ្រិយសំវរៈ* សង្រួមឥន្ទ្រិយទាំង ៦ គឺ

---

(១) ន័យខ្លះរាប់យកវិបស្សនាវិជ្ជា ១ មនោមយិទ្ធិវិជ្ជា ១ ឥទ្ធិវិធិវិជ្ជា ១ ជាវិជ្ជា ៣ ។ វិជ្ជា ៨ រាប់យកអភិញ្ញា ៥ គឺទិព្វចក្ខុវិជ្ជា ១ ទិព្វសោតវិជ្ជា ១ បរចិត្តវិជ្ជា ១ បុព្វេនិវាសវិជ្ជា ១ អាសវក្ខយវិជ្ជា ១ ជា ៥ ផ្សំនឹងវិជ្ជា ៣ ខាងដើម ជាវិជ្ជា ៨ ។

ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជីវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ បិទផ្លូវមិនឱ្យបាប-ធមិគឺ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ចូលមកក្នុងសន្តានបាន ១, *ភោជនេ មត្តញ្ញុតា* ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១, *ជាគរិយានុយោគ* ប្រកបកិរិយាភ្ញាក់រឲកជានិច្ច គឺប្រាសចាកថីនមិទ្ធ ១, *សទ្ធា* ចិត្តថ្លាស្អាតបរិសុទ្ធប្រាសចាកបាបធមិទាំងពួង ១, *សតិ* សេចក្តីរឲកដឹងខ្លួនជានិច្ច ១, *ហិរិ* សេចក្តីខ្មាសបាប ១, *ឱតប្ប:* សេចក្តីក្តៅក្រហាយ ឬស្ងើបនឹងបាប ១, *ពាហុសច្ច:* សេចក្តីចេះចាំច្រើន ១, *ឧបក្កម:* សេចក្តីប្រឹងប្រែងប្រកបដោយសម្មប្បធានវីរិយៈ ១, *មតិ* សេចក្តីយល់ប្រកបដោយបញ្ញាធិប្បាយដ៏ច្រើន ១, *អបរិហីនរូបាវចរជ្ឈានំ* រូបាវចរជ្ឈាន ៤ ដែលមិនបានសាបសូន្យ រាប់ជា ៤ ផ្សំគ្នាជាចរណៈ ១៥ ។

សម្តេចព្រះមហាករុណា បរិបូណិដោយវិជ្ជា ៣ វិជ្ជា ៨ ចរណៈ ១៥ ដូចពណិនាមកនេះ ទើបទ្រង់ព្រះនាមថា « វិជ្ជាចរណសម្បន្នោ » ។

ចប់បទ « វិជ្ជាចរណសម្បន្នោ » ដោយសង្ខេប

កែបទ « សុគតោ »

បុ. ព្រះជាគ្រូ ហេតុដូចម្តេចបានជាទ្រង់ព្រះនាមថា « សុគតោ » ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គមានព្រះដំណើរល្អផង ព្រោះព្រះអង្គមានព្រះបន្ទូលពិរោះផង ។

បុ. ដែលថា « ព្រះអង្គមានព្រះដំណើរល្អ » នោះ តើល្អដូចម្តេច ?

វិ. ព្រះអង្គមានដំណើរល្អគួរឱ្យសត្វលោកភ្លូកភ្លឹក, មានព្រះដំណើរល្អទៅកាន់ទីស្អាត, មានព្រះដំណើរល្អគួរឱ្យកើតសេចក្តីជ្រះថ្លាដល់មហាជន, មានព្រះដំណើរល្អយាងទៅកាន់អមតមហានិព្វាន ។

ក) ដែលថា « មានព្រះដំណើរល្អគួរឱ្យសត្វលោកភ្លូកភ្លឹក » អធិប្បាយថា ព្រះអង្គទ្រង់មានព្រះដំណើរយាងយាសសមសោភាឥតឆ្គង មុខគួរឱ្យសត្វផងពិតពិលរមិលមើល ដូចគ្រាដែលទ្រង់ទើបបានត្រាស់ជាដំបូង ស្តេចចេញចាកពោធិ-មណ្ឌល យាងតាមមាគិដោយព្រះបាទាដ៏ប្រកបដោយលាយលក្ខណ៍កង់ចក្រ មានឆព្វណ្ណរង្សីឆ្ពុះព្រោងព្រាយ ឆ្ពោះព្រះភក្ត្រទៅកាន់ឥសិបតនមិគទាយវ័ន ។ គ្រានោះកើតរំជួលដល់ពួកទេពនិករ នាំគ្នាហោះចាកទីស្ថានមកហែហមអមដំណើរព្រះអង្គ, មិនត្រឹមតែពួកទេពនិកាយប៉ុណ្ណោះ, សូម្បីពួកម្រឹគីម្រឹគាក៏នាំគ្នាមកឈររហង់ក្បែរអង្គព្រះជិនស្រី ទាំងពួកបក្សាបក្សី ក៏នាំគ្នាបោះពួយឆ្វៀលឆ្វាត់មកសំកាំងស្លាបនៅនាទីដែលព្រះអង្គស្តេចយាងទៅ, ទាំងនេះក៏មកតែពីព្រះអង្គមានព្រះខន្ធសន្តានស្អាតបរិសុទ្ធ ទើបមានព្រះដំណើរឥតឆ្គងគួរឱ្យសត្វផងពិតពិលរមិលមើល ។ មិនតែមួយគ្រានេះទេ តមក វេលាដែលព្រះអង្គទ្រង់យាងចូលទៅកាន់ទីសមាគមណា១ ក៏តែងមានពួកទេវនិករ និងមនុស្សនិករ ភ្លូកភ្លឹកគឹកកងមកគយគន់មើលព្រះដំណើរយាង

យាសរបស់ព្រះអង្គ ។ ហេតុនេះ ទើបបានវិសជ្ជនាថា « ព្រះអង្គមានព្រះដំណើរល្អគួរឱ្យសត្វលោកភ្លក្លភ្លឹក » ។

ខ) ដែលថា « ព្រះអង្គមានព្រះដំណើរទៅកាន់ទីស្អាត » អធិប្បាយថា ព្រះពិជិតមារ កាលបើទ្រង់យាងទៅកាន់ទីណា ទីនោះទោះជាទីស្មោកគ្រោកយ៉ាងណាក្តី ក៏គង់នឹងប្រែក្លែរទៅជាទីស្អាតបរិសុទ្ធវិញ ដូចគ្រាដែលក្រុងពៃសាលីកើតមានភ័យអំពីអហិវាតរោគ និងមានពួកអមនុស្សប្លែតប្លែនជាច្រើន និងទុរភីក្ស អំណត់អត់ឃ្លាន អ្នកស្រុកស្លាប់ដេរដាសសព្វអន្លើ ម្ល៉ោះហើយព្រះនគរទាំងមូលទៅជាមិនស្អាត ពាសពេញទៅដោយសាកអសុភ ។ ពួកស្តេចលិច្ឆវីជាម្ចាស់ព្រះនគរ មកអារាធនាព្រះសម្ពុទ្ធឱ្យស្តេចទ្រង់យាងទៅ : ព្រះអង្គស្តេចមិនមានយាងទៅដល់ផង ក៏ពួកទេវតាបណ្តាលភ្លៀងយ៉ាងធំធ្លាក់ចុះមកបន្សាត់សាកអសុភទាំងនោះតាមស្ទឹងឱ្យចូលទៅកាន់មហាសមុទ្ទទាំងអស់ មិនឱ្យមានសេសសល់ នគរនោះទៅជាស្អាតបរិសុទ្ធគួរដល់ព្រះពុទ្ធដំណើរស្តេចយាងមក ។ ហេតុនេះបានជាវិសជ្ជនាថា « ព្រះអង្គមានព្រះដំណើរល្អយាងទៅកាន់ទីស្អាត » ។

គ) ដែលថា « ព្រះអង្គមានព្រះដំណើរល្អគួរឱ្យកើតសេចក្តីជ្រះថ្លាដល់មហាជន » អធិប្បាយថា ព្រះលោកនាថជាម្ចាស់ ទ្រង់មានព្រះគុណគួរឱ្យជ្រះថ្លា ៤ ប្រការ ដែលហៅថា « បមាណ » គឺ :

១. *រូបប្បមាណ* ទ្រង់មានព្រះរូបសក្តិសមល្អ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ និងអនុព្យញ្ជនៈ ៨០ ល្អរកមនុស្សទេព្តាណាផ្ទឹមស្មើគ្មាន ។

២. *ឃោសប្បមាណ* ទ្រង់មានព្រះសូរសៀងដ៏ពិរោះក្រៃលែង ប្រៀបដោយសំឡេងព្រហ្ម ឬសំឡេងសត្វករវិក ។

៣. *ធម្មប្បមាណ* ទ្រង់ជ្រាបធម៌ជ្រៅជ្រះលើសលប់អ្នកប្រាជ្ញទាំងពួង ។

៤. *លូខប្បមាណ* ទ្រង់មានអធ្យាស្រ័យល្អ មិនចេះរើសថា របស់នេះសៅហ្មង នេះថោកទាប នេះអន់ណាស់ ដូច្នេះឡើយ ។ បើសត្វពួកណាត្រូវការខាងរូប, សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយរូប ព្រោះព្រះអង្គទ្រង់មានរូបល្អ, បើសត្វពួកណាត្រូវការខាងសំឡេង, សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយសំឡេង, ព្រោះព្រះអង្គមានព្រះសូរសៀងពិរោះ រកសំឡេងរបស់មនុស្សពួកណាមួយ នឹងយកមកប្រៀបផ្ទឹមពុំបាន, បើសត្វពួកណាត្រូវការតែខាងធម៌ សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយធម៌ ព្រោះព្រះអង្គឈ្លាសវៃក្នុងវិធីសំដែងធម៌លើសលែងអ្នកប្រាជ្ញទាំងពួងក្នុងត្រៃលោក, បើសត្វពួកណាជាអ្នកកំសត់ទុរគត ប្រាថ្នានឹងថ្វាយបច្ច័យណាមួយដល់ព្រះអង្គ ទោះរបស់នោះថោកទាបយ៉ាងណាក្តី ទ្រង់ក៏អាចទទួលប្រើប្រាស់បានដោយយ៉ាងស្និទ្ធឥតមានច្បិចច្បើម ។ ចំនងនេះហើយដែលនាំឱ្យព្រះអង្គបានជាទីជ្រះថ្លាដល់មហាជន ។ កាលបើយ៉ាងនេះ ទោះបីព្រះអង្គទ្រង់ពុទ្ធដំណើរទៅកាន់ទីណាក្តី ក៏ឥតមានរលកអង្គុំ, សត្វពួកណាដែលមិនទាន់ជ្រះថ្លានៅឡើយ ក៏កើតជ្រះថ្លាឡើង សត្វពួកណាដែលជ្រះថ្លាស្រាប់ ក៏រឹតតែជ្រះថ្លាជាភិយ្យោភាពឡើង ។ ហេតុនេះបានជាវិសជ្ជនាថា « ព្រះអង្គទ្រង់មានពុទ្ធដំណើរល្អគួរឱ្យកើតសេចក្តីជ្រះថ្លាដល់មហាជន » ។

ឃ) ដែលថា « ព្រះអង្គមានដំណើរល្អយាងទៅកាន់អមតមហានិព្វាន » អធិប្បាយថា ព្រះអង្គស្តេចទ្រង់មានពុទ្ធដំណើរទៅកាន់ទីដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន មិនមានញាញើតរុញរា ពីព្រោះទ្រង់មានខន្ធសន្តានស្អាតបរិសុទ្ធ ឥតមានជិតដាមដោយកិលេស ។ កិលេសណាដែលទ្រង់លះបានហើយ កិលេសនោះលែងត្រឡប់មករកព្រះអង្គវិញ, ព្រះអង្គក៏លែងត្រឡប់ទៅរកកិលេសទាំងនោះវិញដែរ ។

ទំនងដែលព្រះអង្គលះកិលេសនោះដូច្នេះគឺ ទ្រង់លះសក្កាយទិដ្ឋិ, វិចិកិច្ឆាសីលព្វត្តបរាមាសៈ, ទិដ្ឋានុសយៈ និងវិចិកិច្ឆានុសយៈ ដោយអំណាចសោតាបត្តិមគ្ត, លះកាមរាគសំយោជនៈ បដិឃសំយោជនៈ, កាមរាគានុសយៈ បដិឃានុសយៈ យ៉ាងគ្រោតគ្រាតដោយអំណាចសកទាគាមិមគ្ត, លះកាមរាគសំយោជនៈ, បដិឃសំ-យោជនៈ កាមរាគានុសយៈ បដិឃានុសយៈ យ៉ាងល្អិត ដោយអំណាចអនាគាមិមគ្ត, លះរូបរាគៈ, អរូបរាគៈ, មានៈ, ឧទ្ធច្ចៈ, អវិជ្ជា, មានានុសយៈ, អវិជ្ជានុសយៈ ដោយអំណាចអរហន្តមគ្ត ។ កិលេសទាំងឡាយដែលព្រះអង្គទ្រង់លះបានដោយអរិយ-មគ្តនោះ១ហើយ មិនដែលត្រឡប់មកកើតក្នុងសន្តានព្រះអង្គវិញឡើយ ។ ហេតុនេះហើយ ទើបវិសជ្ជនាថា « ព្រះអង្គមានព្រះដំណើរល្អយាងទៅកាន់អមតមហា-និព្វាន » ។

បុ. ចុះត្រង់ដែលវិសជ្ជនាថា « ព្រះអង្គមានព្រះបន្ទូលពិរោះនោះតើអធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ជ្រាបច្បាស់នូវពាក្យពិត និងមិនពិត, មានប្រយោជន៍ និងឥតប្រយោជន៍, ត្រូវចិត្តសត្ធ និងមិនត្រូវចិត្តសត្ធ ។ បើពាក្យណាមិនពិត, ឥតប្រយោជន៍ និងមិនត្រូវចិត្តសត្ធនោះ ព្រះអង្គនឹងមិនមានព្រះបន្ទូលឡើយ, ពាក្យឯណាដែលពិត មានប្រយោជន៍ ត្រូវចិត្តសត្ធ ទើបព្រះអង្គទ្រង់មានព្រះបន្ទូល ដើម្បីនឹងធ្វើពាក្យនោះឱ្យសម្រេចប្រយោជន៍ដល់អ្នកស្តាប់, បើពាក្យណាមិនពិត ឥតប្រយោជន៍ ទុកណាជាត្រូវចិត្តសត្ធ ក៏ព្រះអង្គមិនទ្រង់មានព្រះបន្ទូលដែរ, លុះតែពាក្យពិតផង មានប្រយោជន៍ផង ត្រូវចិត្តសត្ធផង ទើបព្រះអង្គទ្រង់មានព្រះបន្ទូល ។ ដូចមានកាលមួយថ្ងៃ សម្តេចព្រះជិនស្រី ទ្រង់មានព្រះពុទ្ធដំណើរទៅក្បែរដើមឈើមួយ យកព្រះហស្តចាប់ស្លឹកឈើមួយក្តាប់ ហើយត្រាស់

សូរទៅអានន្ទថា : អានន្ទ, ស្លឹកឈើដែលនៅក្នុងក្តាប់ដៃតថាគតនេះ ហើយនិងស្លឹកឈើដែលនៅសល់លើផែនដី ណាច្រើនជាងណា ព្រះអានន្ទក្រាបទូលស្នងព្រះពុទ្ធដីកាថា : បពិត្រព្រះអង្គដ៏ចំរើន, សូមទ្រង់ព្រះមេត្តាប្រោស ស្លឹកឈើដែលស្ថិតនៅក្នុងព្រះហស្តព្រះអង្គតិចណាស់ ស្លឹកឈើក្រៅពីនោះច្រើនពន់ពេក ។ ព្រះអង្គទ្រង់ត្រាស់ផ្ទួនសេចក្តីនោះឱ្យប្រាកដឡើងថា : អើអានន្ទ ! ធម៌វិន័យដែលតថាគតបានត្រាស់ដឹងច្រើនពេកណាស់ តែធម៌ដែលតថាគតបានសំដែងទុកជាឱវាទដល់អ្នកវាល់គ្នានោះតិចតួចទេ ដូចជាស្លឹកឈើដែលនៅក្នុងកណ្តាប់ដៃតថាគត, ធម៌ដែលសល់នៅ តថាគតមិនបានសំដែងនោះច្រើនពេកណាស់ ដូចជាស្លឹកឈើដែលនៅលើផែនដីទាំងប៉ុន្មាន, ព្រោះហេតុអ្វី ? ព្រោះតថាគតសំដែងតែធម៌ណាពិត ហើយមានប្រយោជន៍ច្រើនដល់អ្នកប្រតិបត្តិ ។

ពិតមែន ធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ដែលព្រះអង្គទ្រង់បានត្រាស់សំដែងទុកតាំងអំពីទ្រង់បានត្រាស់ដឹងឡើង ដរាបដល់ចូលកាន់ព្រះបរមនិព្វាន ក៏សុទ្ធតែធម៌ពិត វិន័យពិត ប្រព្រឹត្តទៅមួយអន្លើដោយប្រយោជន៍ អាចឱ្យសម្រេចសេចក្តីសុខគ្រប់ប្រការដល់សត្វអ្នកប្រតិបត្តិតាម, ព្រោះហេតុនោះបានជាព្រះអង្គទ្រង់ព្រះនាមថា « សុគតោ » ប្រែថា « ព្រះអង្គទ្រង់មានព្រះបន្ទូលដ៏ពិរោះ » ។ ដូច្នេះ ។

ចប់បទ « សុគតោ » ដោយសង្ខេប

កែបទ « លោកវិទូ »

បុ. ព្រះមុនិន្ទសាស្តាចារ្យជាម្ចាស់ ហេតុអ្វីបានជាទ្រង់ព្រះមានថា « លោកវិទូ » ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គជ្រាបច្បាប់នូវលោក ។

បុ. សភាពដច្ចម្តេចដែលហៅថា « លោក » ? មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. សភាពដែលតែងតែវិនាសបាត់បង់សូន្យទៅ ហៅថា « លោក » ។ លោកនេះមាន ៣ យ៉ាងគឺ សង្ខារលោក[(១)] ១, សត្តលោក ១, ឱកាសលោក ១ ។

បុ. ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ដូចម្តេចខ្លះ ?

វិ. • « *អាហារសង្ខារលោកំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១ គឺ កវឡិង្ការាហារ បានដល់អាហារដែលជាពំនូត១ សម្រាប់ចិញ្ចឹមជីវិតសត្ត ។

• « *នាមរូបសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ២ គឺ នាម[(២)] និងរូប[(៣)] ។

• « *តីវិធវេទនាសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៣ គឺ វេទនា ៣ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។

• « *ចតុរាហារសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៤ គឺ អាហារ ៤ កវឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។

---

(១) ន័យខ្លះថា បានដល់ខន្ធទាំង ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ ។ (២) ចិត្ត ៨១ ដូង និងចេតសិក ៥២ ហៅថា « នាម » ។ (៣) រូប ២៨ គឺមហាភូតរូប ៤ ឧបាទាយរូប ២៤ ហៅថា « រូប » ។ ក៏ងនាម និងរូបនេះ លុះតែអាស្រ័យនូវគ្នានិងគ្នាទៅវិញទៅមក ទើបប្រព្រឹត្តទៅបាន ឧបមាដូចជា នាវា និងអ្នកកាន់ចង្កូត, មួយទៀត ឧបមាដូចជាមនុស្ស ២ នាក់ ១ ខ្វាក់ ១ ខ្វិន មនុស្សខ្វាក់បានជើង មនុស្សខ្វិនបានភ្នែក អាស្រ័យគ្នានិងគ្នាដើរទៅបាន ។

កវឡិង្ការាហារ នាំមកនូវរូប ៨ គឺ : *បថវី ១, អាបោ ១, តេជោ ១, វាយោ ១, វណ្ណោ ១, គន្ធោ ១, ឱជា ១* ។ ផស្សាហារនាំមកនូវវេទនា ៣ គឺ សុខវេទនា ១, ទុក្ខវេទនា ១, អទុក្ខមសុខវេទនា ១ ។ មនោសញ្ចេតនាហារ នាំមកនូវបដិសន្ធិក្នុងភព ទាំង ៣ គឺ : *កាមភព ១, រូបភព ១, អរូបភព ១* ។ វិញ្ញាណាហារ នាំមកនូវនាម និងរូបក្នុងបដិសន្ធិខណៈ ។

• « *បញ្ចុបាទានក្ខន្ធសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៥ គឺ ឧបាទានក្ខន្ធ ៥ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

• « *ឆអជ្ឈត្តិកាយតនសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៦ គឺ អាយតនៈខាងក្នុងទាំង ៦ *ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១* ។

• « *សត្តវិញ្ញាណដ្ឋិតិសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៧ គឺ វិញ្ញាណដ្ឋិតិ ៧ នានត្តកាយា នានត្តសញ្ញី សត្វមានកាយផ្សេងគ្នា មានសញ្ញាក៏ផ្សេងគ្នា ១ នានត្តកាយា ឯកត្តសញ្ញី សត្វមានកាយផ្សេងគ្នា មានសញ្ញាត្រូវគ្នា ១ ឯកត្តកាយា នានត្តសញ្ញី សត្វមានកាយត្រូវគ្នា មានសញ្ញាផ្សេងគ្នា ១ ឯកត្តកាយា ឯកត្តសញ្ញី សត្វមានកាយត្រូវគ្នា មានសញ្ញាក៏ត្រូវគ្នា ១ អាកាសានញ្ចាយតនៈ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ ។ ពួកទេវតា និងវិនិបាតិកប្រេត មានរូបកាយផ្សេងគ្នា មានបដិសន្ធិផ្សេងគ្នា, ពួកមនុស្សមានរូបកាយផ្សេងគ្នា មានបដិសន្ធិផ្សេងគ្នា ខ្លះជាអហេតុកៈ ខ្លះជាទុហេតុកៈ ខ្លះជាត្រីហេតុកៈ សត្វពួកនេះឈ្មោះថាមានកាយផ្សេងគ្នា មានសញ្ញាក៏ផ្សេងគ្នា, អបាយិកសត្វ គឺសត្វដែលកើតក្នុងអបាយភូមិ មានរូបផ្សេង១គ្នា ខ្លះខ្លស់ ខ្លះទាប ខ្លះតូច ខ្លះធំជាដើម ដូចពួកយោដបិដ្ឋប្រេត មានកំពស់

តាំងពី ១ យោជន៍ រហូតដល់ ១០ យោជន៍ ក៏មាន តែបដិសន្ធិដូចគ្នា គឺឧបេក្ខាសន្តីរណៈខាងអកុសលវិបាកអហេតុកៈដូចគ្នា ។ ពួកព្រហ្មក្នុងបឋមជ្ឈានភូមិ ៣ គឺ ព្រហ្មបារិសជ្ជា ១ ព្រហ្មបរោហិតា ១ មហាព្រហ្មា ១ ព្រហ្មទាំង ៣ ពួកនេះមានរូបផ្សេងៗគ្នា ; មហាព្រហ្ម រូបរាងធំ និងវិសេសជាងព្រហ្មបរោហិតា ។ ព្រហ្មបរោហិតា មានរូបរាងធំ និងវិសេសជាងព្រហ្មបារិសជ្ជា តែតូបដិសន្ធិជាមួយគ្នា គឺ បឋមជ្ឈានវិបាកដូចគ្នាទាំង ៣ ភូមិ សត្វពួកនេះឈ្មោះថាមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ។ ពួកព្រហ្មក្នុងទុតិយជ្ឈានភូមិ ៣ គឺ បរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ មានរូបរាងធំប្រហែលគ្នា តែតូបដិសន្ធិផ្សេងគ្នា ខ្លះតូបដិសន្ធិជាទុតិយជ្ឈានវិបាក ខ្លះជាតតិយជ្ឈានវិបាក, ដូច្នេះ ឈ្មោះថាមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ១ ។ ពួកព្រហ្មក្នុងតតិយជ្ឈានភូមិ ៣ គឺ បរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ មានរូបរាងប្រហែលៗគ្នា តូបដិសន្ធិក៏ប្រហែលគ្នា តែតតិយជ្ឈានវិបាកដូចគ្នា, សត្វពួកនេះឈ្មោះថាមានកាយដូចគ្នា មានសញ្ញាក៏ដូចគ្នា ។ ពួកព្រហ្មក្នុងជាន់សុទ្ធាវាសភូមិ ៥ គឺ អវិហា ១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋកា ១[(១)] មានរូបកាយប្រហែលៗគ្នា ទាំងតូបដិសន្ធិ ក៏ដូចគ្នា, សត្វពួកនេះឈ្មោះថាមានកាយដូចគ្នា មានសញ្ញាក៏ដូចគ្នា ។ ឯសង្ខារធមិរបស់អសញ្ញីសត្ត មិនបានរាប់បញ្ចូលក្នុងវិញ្ញាណដ្ឋិតិណាមួយទេ ពីព្រោះសត្វពួកនេះបដិសន្ធិដោយរូប ។ សង្ខារធមិរបស់អរូបព្រហ្មក្នុងជាន់អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ ចាត់ជាវិញ្ញាណដ្ឋិតិមួយ១ ឈ្មោះថាឯកត្តសញ្ញា មានសញ្ញាដូចគ្នា

(១) សុទ្ធាវាសភូមិ ៥ ជាន់នេះ ជាទីលំនៅនៃព្រះអានាគាមិ និងព្រះអរហន្ត ។ អាយុព្រហ្ម ក្នុងសុទ្ធាសវាភូមិ ទាំង ៥ ជាន់ មួយមុឺនប្រាំមួយពាន់មហាកប្ប បើដល់កំណត់មួយមុឺនប្រាំមួយពាន់មហាកប្បនោះហើយ មិនមាន ព្រះពុទ្ធជាម្ចាស់បានត្រាស់ថ្មីទ្យេត សុទ្ធាវាសភូមិនោះ ក៏សាបសូន្យ មិនមានវិញ្ញាណដ្ឋិតិ ព្រោះមិនមានសត្វទៅកើត ។

តាមជាន់របស់ខ្លួន ព្រោះពួកព្រហ្មក្នុងជាន់អាកាសានញ្ចាយតនៈ បដិសន្ធិដោយអាកា-សានញ្ចាយតនវិបាក, ជានវិញ្ញាណនញ្ចាយតនៈ បដិសន្ធិដោយវិញ្ញាណញ្ចាយតនវិបាក, ជាន់អាកិញ្ចញ្ញាយតនៈ បដិសន្ធិដោយអាកិញ្ចញ្ញាតនវិបាក, តែមិនមាននិយាយអំពីកាយទេ ព្រោះសត្វពួកនេះមិនមានរូប ។ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនមានវិញ្ញាណដ្ឋិតិទេ ព្រោះសង្ខារធមិនោះល្អិតសុខុមពេកណាស់ មានកិច្ចរបស់វិញ្ញាណមិនប្រាកដ ។ ទាំងនេះឈ្មោះថា វិញ្ញាណដ្ឋិតិ ។

• « *អដ្ឋលោកធម្មសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៨ គឺ លោកធមិ[(1)] ៨ ប្រការ : *លាភោ* លាភ ១ *អលាភោ* ឥតលាភ ១ *យសោ* យស ១ *អយសោ* ឥតយស ១ *និន្ទា* តំណិះដំណៀល ១ *បសំសា* សរសើរ ១ *សុខំ* សុខ ១ *ទុក្ខំ* ទុក្ខ ១ ។

• « *នវសត្តាវាសសង្ខាតំ* » ព្រះអង្គជ្រាបច្បាស់នូវសង្ខារលោក ៩ គឺ ទីលំនៅរបស់សត្ត ៩ បានដល់វិញ្ញាណដ្ឋិតិ ៧ ដូចរៀបរាប់មកហើយ និងអសញ្ញីសត្ត ១ នេវសញ្ញានាសញ្ញាយតនៈ ១ ផ្សំផងគ្នាត្រូវជា ៩ ហៅថា សត្តាវាស ។

• « *ទសាយតនសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១០ គឺ អាយតនៈ ១០ : *ចក្ខ្វាយតនៈ* បសាទរូបដែលជ្រាបសើមទូទៅក្នុងភ្ជាតរូប មានសណ្ឋានប្រមាណប៉ុនក្បាលចៃ តាំងនៅកណ្តាលប្រស្រីភ្នែកទាំងគូ ១ *សោតា-យតនៈ* បសាទរូបដែលជ្រាបសើមទូទៅក្នុងភ្ជាតរូប មានសណ្ឋានដូចវង់ចិញ្ជៀន តាំងនៅក្នុងប្រហោងត្រចៀកទាំងគូ ១ *ឃានាយតនៈ* បសាទរូបដែលជ្រាបសើមទូទៅក្នុងភ្ជាតរូប មានសណ្ឋានដូចក្រចកជើងពពែ តាំងនៅក្នុងក្តោងច្រមុះ ១ *ជិវ្ហាយតនៈ* បសាទរូបដែលជ្រាបសើមទូទៅក្នុងភ្ជាតរូប មានសណ្ឋានដូចស្រទាប់ផ្តា

(1) ធមិសម្រាប់លោក គឺតែងត្របសង្កត់សត្វលោកទូទៅ ។

ឧប្បល តាំងនៅពាក់កណ្តាលអណ្តាត ១ *កាយាយតនៈ* បសាទរូបដែលជ្រាបសើម ទូទៅក្នុងសព្វសពិាង្គកាយ វៀរលែងតែសក់ រោម ក្រចក និងធ្មេញ ដែលដុះផុតចាក កាយ ១ *រូបាយតនៈ* រូបារម្មណ៍ដែលមានពណិខ្យៀវលឿងជាដើម ឬស្រីប្រុស ជាដើម ១ *សទ្ទាយតនៈ* សូស័ព្ទសំឡេងពិរោះ ឬមិនពិរោះ ដែលកើតប្រាកដដល់ចិត្ត ១ *គន្ធាយតនៈ* គន្ធារម្មណ៍គឺក្លិនទាំងពួង ១ *រសាយតនៈ* រសារម្មណ៍គឺរស់របស់អាហារ ទាំងពួង ១ *ផោដ្ឋព្វាយតនៈ* សម្ផស្សទាំងពួងដែលសម្រាប់ប៉ះពាល់រាងកាយ ១ រួមត្រូវជា អាយតនៈ ១០ ។

• « *ឯកាទសវិធារម្មណសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១១ បានដល់អារម្មណ៍ដែលជាតូវិបាកចិត្ត ១១ គឺ *សោមនស្សញាណសម្បយុត្ត ២ សោមនស្សញាណវិប្បយុត្ត ២ ឧបេក្ខាញាណសម្បយុត្ត ២ ឧបេក្ខាញាណ-វិប្បយុត្ត ២ ឧបេក្ខាសម្បដិច្ឆន្ទៈ ១ ឧបេក្ខាសន្តីរណៈ ១ សោមនស្សសន្តីរណៈ ១* ផ្សំគ្នាជា ១១ ។

• « *ទ្វាទសាយតនសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១២ បានដល់អាយតនៈ ១២ គឺ អាយតនៈខាងក្នុង ៦ មានចក្ខ្វាយតនៈជាដើម មានធម្មាយតនៈជាទីបំផុត និងអាយតនៈខាងក្រៅ ៦ មានរូបាយតនៈជាដើម មានផោដ្ឋព្វាយតនៈជាទីបំផុត ត្រូវជាអាយតនៈ ១២ ។

• « *តេរសហសនចិត្តសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១៣ បានដល់ហសនចិត្ត[(១)] ១៣ គឺ *លោភសោមនស្ស ៤ មហាកុសលសោមនស្ស ៤ មហាកិរិយាសោមនស្ស ៤ ហសិតុប្បាទ ១* ត្រូវជា ១៣ ។

• « *ចុទ្ទសចិត្តុប្បាទសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១៤ បាន

(១) ចិត្តដែលបណ្តាលឱ្យសើចញញឹមទៅបាន ។

ដល់ចិត្តបា្លទដែលប្រកបដោយអកុសល ១៤ គឺ *មោហោ* សភាពញ៉ាំងចិត្តឱ្យលង់ក្នុងអារម្មណ៍ ១ *អហិរិកំ* ធម្មជាតិមិនខ្មាសបាប ១ *អនោត្តប្បំ* ធម្មជាតិមិនក្តៅនឹងបាប ១ *ឧទ្ធច្ចំ* ធម្មជាតិញ៉ាំងចិត្តឱ្យរវើរវាយ ១ *លោភោ* សភាពធ្វើចិត្តឱ្យជាប់ជំពាក់ក្នុងអារម្មណ៍ ១ *ទិដ្ឋិ* សេចក្តីយល់ខុស ១ *មានោ* សេចក្តីស្មានខ្លួន ១ *ទោសោ* សភាពប្រទូស្តក្នុងអារម្មណ៍ ១ *ឥស្សា* សេចក្តីច្រណែន ១ *មច្ឆរិយំ* សេចក្តីកំណាញ់ ១ *កុក្កុច្ចំ* ធម្មជាតិធ្វើចិត្តឱ្យស្តុងទៅរកការដែលខ្លួនប្រព្រឹត្តខុសកន្លងហើយ ១ *ថីនំ* ធម្មជាតិធ្វើចិត្តឱ្យរួញរាមិនឱ្យខ្ចប់ខ្ចាយ ១ *មិទ្ធំ* ធម្មជាតិធ្វើចិត្តឱ្យងោកងុយ និងឱ្យប្រព្រឹត្តលក់ ១ *វិចិកិច្ឆា* ធម្មជាតិធ្វើចិត្តឱ្យសង្ស័យ ឬកន្ទះរា ១ រួមគ្នាត្រូវជា ១៤ ។

• « *អដ្ឋារសធាតុសង្ខាតំ* » ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១៨ បានដល់ធាតុ ១៨ គឺ *ចក្ខុធាតុ* ចក្ខុបសាទ ១ *រូបធាតុ* រូបារម្មណ៍ ១ *ចក្ខុវិញ្ញាណធាតុ* វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យចក្ខុបសាទ និងរូបារម្មណ៍ខ្ចប់គ្នា ១ *សោតធាតុ* សោតបសាទ ១ *សទ្ទធាតុ* សទ្ទារម្មណ៍ ១ *សោតវិញ្ញាណធាតុ* វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យសោតបសាទ និងសទ្ទារម្មណ៍ខ្ចប់គ្នា ១ *ឃានធាតុ* ឃានបសាទ ១ *គន្ធធាតុ* គន្ធារម្មណ៍ ១ *ឃានវិញ្ញាណធាតុ* វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យឃានបសាទ និងគន្ធារម្មណ៍ខ្ចប់គ្នា ១ *ជិវ្ហាធាតុ* ជិវ្ហាបសាទ ១ *រសធាតុ* រសារម្មណ៍

---

(១) វិញ្ញាណទាំងនេះចែកចេញជា ២ គឺជាកុសលវិបាក ១ អកុសលវិបាក ១ ។ (២) បានដល់ចិត្ត ៣ គឺ បញ្ចទ្វា.រាវជ្ជនចិត្ត ១ សម្បដិច្ឆន្នចិត្ត ២ ។ (៣) ធម្មារម្មណ៍មាន ៦ គឺ បសាទរូប ១ សុខុមរូប ១ ចិត្ត ១ ចេតសិក ១ និព្វាន ១ បញ្ញត្តិ ១ ។ (៤) បានដល់ចិត្ត ៧២ គឺ អកុសលចិត្ត ១២ សត្តិរណៈ ៣ មនោទ្វារាវជ្ជនៈ ១ ហសនចិត្ត ១ ទាំង ៤ នេះរាប់ថា ១ : កាមាវចរសោភណចិត្ត ២៤ រូបាវចរ ១៥ អរូបាវចរ ១២ លោកុត្តរ ៨ ត្រូវជាចិត្ត ៧២ ។

១ *ជិវ្ហាវិញ្ញាណធាតុ* វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យជិវ្ហាបសាទ និងរសា.រម្មណ៍ខ្ចប់គ្នា ១ *កាយធាតុ* កាយបសាទ ១ *ផោដ្ឋព្វធាតុ* ផោដ្ឋព្វារម្មណ៍ ១ *កាយ.វិញ្ញាណធាតុ* វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យកាយបសាទ និងផោដ្ឋព្វារម្មណ៍ខ្ចប់គ្នា ១ *មនោធាតុ* ចិត្ត[2] ១ *ធម្មធាតុ* ធម្មារម្មណ៍[3] ១ *មនោវិញ្ញាណធាតុ* វិញ្ញាណ[4] ដែលកើតឡើងអាស្រ័យចិត្តនិងធម្មារម្មណ៍ខ្ចប់គ្នា ១ « ឥតិ សង្ខារ.លោកំ ជានាតីតិ >លោកវិទូ » សម្តេចព្រះសព្វញ្ញូ ទ្រង់ត្រាស់ដឹងនូវសង្ខារលោក ដូចពណ៌នាមកនេះ ទើបបានទ្រង់ព្រះនាមថា « លោកវិទូ » ។

បុ. ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជ្រាបនូវសត្វលោក ដូចម្តេចខ្លះ ?

វិ. • « *សព្វសត្តានំ អាសយំ* » ព្រះអង្គជ្រាបច្បាស់នូវទីកចិត្តរបស់សព្វសត្វ ដែលមានធម៌អាស្រ័យនៅក្នុងខន្ធសន្តានយ៉ាងណា១ គឺជ្រាបថា ធម៌ ២ ប្រការ គឺ សស្សតទិដ្ឋិ ១ ឧច្ឆេទទិដ្ឋិ ១ តែងអាស្រ័យនៅក្នុងខន្ធសន្តានរបស់បុថុជ្ជន អនុ.លោមខន្តី គឺវិបស្សនាញាណទាំង ១០ និងយថាភូតញាណ តែងអាស្រ័យនៅក្នុងសន្តានរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

• « *អនុសយំ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវបាបធម៌ដែលដេកត្រាំនៅក្នុងសន្តានចិត្តរបស់សត្វរង់ចាំឱកាសនឹងកើតក្លាឡើង បានដល់ពួកកិលេស មានកាមរាគ និងព្យាបាទ ជាដើម ។

• « *ចរិតំ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវចរិត គឺលំនាំប្រព្រឹត្តជាប្រក្រតីរបស់សត្វទាំង ៦ ប្រការ គឺ *រាគចរិត* លំនាំសត្វដែលច្រើនដោយតម្រេក ១ *ទោស.ចរិត* លំនាំសត្វដែលច្រើនដោយសេចក្តីប្រទូស្ត ១ *មោហចរិត* លំនាំសត្វដែលច្រើនដោយសេចក្តីវង្វេង ១ *សទ្ធាចរិត* លំនាំសត្វដែលច្រើនដោយសេចក្តីជឿ ១ *ពុទ្ធិ.ចរិត* លំនាំសត្វដែលច្រើនដោយការចេះដឹង ១ *វិតក្កចរិត* លំនាំសត្វដែលច្រើន

ដោយសេចក្តីត្រិះរិះ ១ ។

• « *អធិមុត្តី* » ព្រះអង្គជ្រាបច្បាស់នូវអធ្យាស្រ័យ សេចក្តីចំណូលធមិរបស់សត្វដែលក្លៀវក្លា និងទន់ទាប ឬដែលជាបុណ្យ និងជាបាប ។

• « *អប្បរជ្ជក្ខេ មហារជ្ជក្ខេ សត្តេ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានធូលី គឺរាគាទិកិលេសក្នុងភ្នែកតិច និងមានធូលី គឺរាគាទិកិលេសក្នុងភ្នែកច្រើន ។

• « *តិក្ខិន្ទ្រិយេ សត្តេ មុទិន្ទ្រិយេ សត្តេ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានឥន្ទ្រិយក្លៀវក្លា និងពួកសត្វដែលមានឥន្ទ្រិយទន់ ។ ឥន្ទ្រិយនោះមាន ៥ គឺ *សទ្ធិន្ទ្រិយ* សេចក្តីជឿជាធំ ១ *វីរិយិន្ទ្រិយ* សេចក្តីព្យាយាមជាធំ ១ *សតិន្ទ្រិយ* សេចក្តីរពឹកចងចាំមិនភ្លេចជាធំ ១ *សមាធិន្ទ្រិយ* សេចក្តីតាំងចិត្តមាំជាធំ ១ *បញ្ញិន្ទ្រិយ* បញ្ញាជាធំ ១ ។

• « *ស្វាការេ សត្តេ ទ្វាការេ សត្តេ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានអាការៈល្អ វៀរចាកអំពើទុច្ចរិត និងពួកសត្វដែលមានអាការៈអាក្រក់ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិត ។

• « *សុវិញ្ញាបយេ សត្តេ ទុវិញ្ញាបយេ សត្តេ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានប្រាជ្ញាងាយពន្យល់ឱ្យចេះដឹងបាន និងពួកសត្វដែលអប្បឥតប្រាជ្ញា និងដឹកនាំឱ្យចេះដឹងបាន ។

• « *ភព្វាភព្វេ សត្តេ* » ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានភ័ព្វ គឺសត្វដែលគួរត្រាស់ដឹងមគ្គផល និងសត្វដែលឥតភ័ព្វ មិនគួរត្រាស់ដឹងមគ្គផល ។ សត្វពួកណាប្រកបដោយអាវរណធមិ គឺធមិជាគ្រឿងរារាំង ៣ ប្រការ គឺ *កាមាវរណៈ ១ កិលេសាវរណៈ ១ វិបាកាវរណៈ ១* ។

កាមាវរណៈ បានដល់តណ្ហា ៥ យ៉ាង គឺ *រូបតណ្ហា* ប្រាថ្នារូប ១ *សទ្ទតណ្ហា* ប្រាថ្នាសំឡេង ១ *គន្ធតណ្ហា* ប្រាថ្នាក្លិន ១ *រសតណ្ហា* ប្រាថ្នារស ១ *ផោដ្ឋព្វតណ្ហា* ប្រាថ្នាផ្សព្វគ្រឿងកម្រាលដេក **វង្គុយ** ជាដើម ១ ។

កិលេសាវរណៈ បានដល់កិលេស ១០ ប្រការ គឺ *កាមរាគ* សេចក្តីត្រេកអរក្នុងកាម ១ *ភវរាគៈ* សេចក្តីត្រេកអរក្នុងភព ១ *រូបរាគៈ* សេចក្តីត្រេកអរក្នុងរូបភព ១ *អរូបរាគៈ* សេចក្តីត្រេកអរក្នុងអរូបភព ១ *លោភៈ* សេចក្តីជំពាក់ចិត្ត ១ *ទោសៈ* សេចក្តីប្រទូស្ត ១ *មោហៈ* សេចក្តីភាន់ច្រឡំ ១ *មានៈ* សេចក្តីខ្ពាសខ្ពស់ ១ *ទិដ្ឋិ* សេចក្តីយល់ខុស ១ *វិចិកិច្ឆា* សេចក្តីសង្ស័យ ១ ។

វិបាកាវរណៈ បានដល់ទិដ្ឋិ ៣ យ៉ាងគឺ *អហេតុកទិដ្ឋិ* សេចក្តីយល់ថា សត្វដែលសៅហ្មង ឬបរិសុទ្ធឥតមានហេតុបច្ច័យល្អក៏ល្អឯង អាក្រក់ក៏អាក្រក់ឯង ឥតមានកុសលាកុសលមកឧបត្ថម្ភ ១ *អកិរិយទិដ្ឋិ* សេចក្តីយល់ថា ធ្វើបាបខ្លួនឯងក្តី ញុាំងអ្នកដទៃឱ្យធ្វើក្តី ឥតបានបាប ១ *នត្ថិកទិដ្ឋិ* សេចក្តីយល់ថាឱ្យទានមិនមានផល ធ្វើការបូជាក៏មិនមានផល ប្រតិបត្តិមាតាបិតាក៏មិនមានផល ១ ។ សត្វដែលប្រកបដោយធម៌ទាំងនុ៎ះ ឈ្មោះថាជាសត្វ**អភ័ព្វ** មិនគួរបានត្រាស់ដឹងមគ្គផលឡើយ ។

មួយទៀត សត្វពួកណាធ្វើបញ្ចានន្តរិយកម្ម គឺ : *មាតុឃាត* ពិឃាតមាតាឯង ១ *បិតុឃាត* ពិឃាតបិតាឯង ១ *អរហន្តឃាត* ពិឃាតព្រះអរហន្ត ១ *ពុទ្ធលោហិតុប្បាទ* ញុាំងព្រះលោហិតព្រះពុទ្ធឱ្យពុរពងឡើង ១ *សង្ឃភេទ* បំបែកសង្ឃដែលរាប់អានគ្នាស្មោះសរនៅក្នុងសីមាជាមួយឱ្យបែកចាកគ្នា ១ និងពួកសត្វដែលធ្វើភិក្ខុនីទូសកកម្ម ប្រទូស្តនាងភិក្ខុនីជាព្រះខីណាស្រព ដោយអសទ្ធកម្ម ១ ។ សត្វពួកនេះក៏ទុកជាសត្វ**អភ័ព្វ** មិនគួរត្រាស់ដឹងមគ្គផលដែរ ។

សត្វពួកណាប្រាសចាកអាវរណៈ ៣ ប្រការ មិនប្រកាន់មិច្ឆាទិដ្ឋិទាំង ៣ មិនធ្វើបញ្ជានន្តរិយកម្ម និងភិក្ខុនីទូសកកម្ម ជាអ្នកឧស្សាហ៍បំពេញទាន រក្សាសីល ចំរើនមេត្តា ភាវនា ស្តាប់ព្រះសទ្ធម្មវិសេសទេសនា ផ្តត់ផ្តង់បំរើមាតាបិតា សត្វពួកនោះឈ្មោះថាសត្វមានភ័ព្ធ គួរត្រាស់ដឹងមគ្គផលបាន បើទុកជាមិនបានមគ្គផលក្នុងបច្ចុប្បន្នជាតិនេះ ក៏គង់បានជាបច្ច័យនៃមនុស្សសម្បត្តិ និងសគ្គសម្បត្តិដែរ ដល់វេលាមានបារមីចាស់ក្លា គង់នឹងបានទទួលផលក្នុងខាងក្រោយមិនខាន ។

« ឥតិ សត្តលោកំ ជានាតីតិ > លោកវិទូ » សម្តេចព្រះអនាវរណ-ញ្ញ ាណទ្រង់ជ្រាបច្បាស់នូវសត្វលោក ដូចរៀបរាប់មកនេះ ទើបទ្រង់ព្រះនាមថា « លោកវិទូ » ។

បុ. ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវឱកាសលោក ដូចម្តេចខ្លះ ?

វី. ទ្រង់ជ្រាបច្បាស់នូវភាជនលោកទាំងមូលឥតចន្លោះទើសទាក់ ។ ហេតុដែលហៅឱកាសលោកថា « ភាជនលោក » ពីព្រោះ ឱកាសលោកទាំងមូល ដូចជាភាជនៈសម្រាប់រង សម្រាប់ដាក់ទ្រូត១ ត១គ្នាគឺ ខ្យល់រងទឹក, ទឹករងផែនដី, ផែនដីរងភ្នំត្រីកូដ, ភ្នំត្រីកូដរងភ្នំព្រះសុមេរុ, ភ្នំព្រះសុមេរុរងឆកាមាវចរសួគិ ដូច្នេះ ទើបហៅថា ភាជនលោក គឺសំដៅយកផ្ទៃចក្រវាលទាំងមូល ។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវលោកទាំង ៣ ដូចពណិនាមកនេះ បានជាទ្រង់ព្រះនាមថា - « លោកវិទូ » ប្រែថា « ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ។

ចប់បទ « លោកវិទូ » ដោយសង្ខេប

កែបទ « **អនុត្តរោ** »

បុ. ហេតុអ្វីបានជាព្រះជាគ្រូទ្រង់ព្រះនាមថា « អនុត្តរោ » ?

វិ. បានជាទ្រង់ព្រះនាមថា « អនុត្តរោ » ព្រោះព្រះអង្គប្រសើរវិសេសរកបុគ្គលណាប្រសើរជាងគ្មាន ។

បុ. ព្រះអង្គប្រសើរដោយគុណអ្វី ដែលរកគេប្រៀបផ្ទឹមស្មើគ្មាននោះ ?

វិ. ព្រះអង្គប្រសើរដោយគុណសព្វគ្រប់ ដូចសំដែងតទៅនេះ :

• « *រូបកាយេសុ អនុត្តរោ* » ព្រះអង្គប្រសើរលើសដោយរូបកាយ គឺរូបកាយរបស់ព្រះអង្គមិនប្រកបដោយទោសទាំងពួង មានមិនវិកលវិការខ្វាក់ស្រលៀងជាដើម ទ្រង់មានព្រះឥរិយាបថស្រគត់ស្រគំសមសោភា ទោះទ្រង់ផ្ដក្ដី ទ្រង់យាងក្ដី ទ្រង់គង់ក្ដី ក៏សមឥតឆ្គង ព្រោះព្រះអង្គប្រកបដោយមហាបុរិស.លក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ មានរស្មីផ្សាយចេញពីតួអង្គ រកមនុស្ស និងទេវតាណាមួយមកផ្ទឹមស្មើគ្មាន ។

• « *សីលេសុ អនុត្តរោ* » ព្រះអង្គប្រសើរដោយសីល ២ យ៉ាងគឺ លោកិយសីល ១ លោកុត្តរសីល ១ ។ លោកិយសីល បានដល់សីល ៥, សីល ៨, សីល ១០, និងសីល ៤ ដែលព្រះអង្គធ្លាប់រក្សាក្នុងកាលដែលកំពុងត្រាច់រង្គាត់ក្នុងវដ្តសង្សារនៅឡើយ រស់ ៤ អសង្ខេយ្យ កប្បមួយសែនកប្ប ជាសីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដរាបមកទល់នឹងកាលដែលបានត្រាស់សព្វញ្ញុតញ្ញាណ ឥតមានមោះហ្មង ជាសីលស្អាតបរិសុទ្ធប្រពៃពិត ។ ឯលោកុត្តរសីលនោះ បានដល់វិរតិ ៣ គឺ សម្មាវាចា ១ សម្មាកម្មន្តោ ១ សម្មាអាជីវោ ១ ដែលកើតមួយអន្លើដោយអរិយមគ្គ លះកាត់បាបធម៌បានដោយសមុច្ឆេទប្បហាន ។

• « *សមាធិម្ហិ អនុត្តរោ* » ព្រះអង្គប្រសើរដោយសមាធិ ២ ប្រការគឺ

ឧបចារសមាធិ ១ អប្បនាសមាធិ ១ ។ ឧបចារសមាធិ បានដល់ឯកត្តតាចិត្តដែលមានក្នុងមហាកិរិយាញាណសម្បយុត្ត ជាឧបចារជ្ឈានសមាបត្តិ ។ ឯអប្បនាសមាធិចែកជា ២ ប្រការទៀតគឺ លោកិយអប្បនា ១ លោកុត្តរអប្បនា ១ ។ លោកិយ-អប្បនា បានដល់សមាធិដែលមានក្នុងសមាបត្តិ ៨ គឺ រូបាវចរកិរិយាសមាបត្តិ ៤ អរូបាវចរកិរិយាសមាបត្តិ ៤ ។ លោកុត្តរអប្បនា ចាត់ជារូបាវចរ ៤ អរូបាវចរ ៤ ដោយអំណាចឈាន ។

• « *បញ្ញាសុ អនុត្តរោ* » ព្រះអង្គប្រសើរលើសដោយបញ្ញា គឺ *មហាបញ្ញោ* ទ្រង់មានព្រះបញ្ញាច្រើនជាងទេវតា និងមនុស្សទាំងឡាយ, *បុថុប្បញ្ញោ* មានបញ្ញាក្រាស់ដូចមហាប្រឹថពី, *ហាសប្បញ្ញោ* មានព្រះបញ្ញាអាចញ្ចាំងចិត្តសត្វឱ្យរីករាយដោយធម្មទេសនា, *ជវនប្បញ្ញោ* មានព្រះបញ្ញាវាងវៃឈ្វេងយល់ឆាប់ *តិក្ខន-ប្បញ្ញោ* មានព្រះបញ្ញាក្ឋៀវក្លាមោះមុត, *និព្វេធិកប្បញ្ញោ* មានព្រះបញ្ញាមិនជាប់ជំពាក់ មិនទើសទាក់ក្នុងការសំដែងធមិ ។ មិនត្រឹមតែពេលដែលបានត្រាស់ហើយនោះទេ សូម្បីកាលដែលទ្រង់សាងព្រះសម្ភារ ត្រាសោយព្រះជាតិជាមហោសថក្តី ជាព្រះវិធូរក្តី ក៏មានប្រាជ្ញាច្រើនអាចគ្របសង្កត់នូវប្រាជ្ញាអ្នកដទៃបាន ។

• « *បុរិសសីលបមាចារេសុ* » ព្រះអង្គមានសីលាចារជាបុរសមែនពិតព្រោះឥរិយាបថទាំង ៤ នៃព្រះអង្គ ក៏ពេញជាបុរសឥតខ្ចោះត្រង់ណាឡើយ ហើយទាំងចេះសិល្បសាស្ត្រវិសេសជាងបុរសទាំងពួង អ្នកផងតែងតែកោតសិល្បសាស្ត្រព្រះអង្គគ្រប់ៗគ្នា ដូចជាគ្រាកាលពួកសក្យៈជាព្រះញាតិវង្សានុវង្សរបស់ព្រះអង្គបន្ទុះបង្អាប់ថា ព្រះសិទ្ធត្ថសក្យបុត្រនេះល្អតែរូបទេ សិល្បសាស្ត្រមិនចេះទេ បើជួនជាមានអាសន្នអន់ក្រ ដោយស្តេចអរិន្ទរាជដែលជាសត្រូវខ្មាំង គេលើកទ័ពមកច្បាំងដណ្តើមយកនគរ ឬក៏មានសឹកសង្ត្រាមពីណាមក ធ្វើម្តេចនឹងតតាំងច្បាំងនឹងគេបាន

បើដូច្នេះ យើងមិនគួរឱ្យធីតាទេ ។ គ្រានោះ ព្រះពោធិសត្វទ្រង់សំដែងចេស្តា កណ្តាលជំនុំពួកសក្យៈ លើកសហស្សថាមធនូឡើង លាន់ឮស័ព្ទសំឡេងកក្រើក រំជួលទូទៅ ពួកសក្យៈឮហើយភាន់ភាំងខ្លបខ្លាចថ្វីព្រះហស្តព្រះអង្ត ទើបនាំគ្នាយក ធីតា ចំនួន ៤ មុីនមកថ្វាយ ។

• « *ភវស្ស សម្មាចារេសុ* » ព្រះអង្តមានព្រះមារយាទថ្កើងថ្កានជាងអស់ សត្វទាំងត្រៃភព ។

• « *បរបុគ្តលវិមុត្តិញ្ញាណេ* » ព្រះអង្តប្រសើរលើសដោយប្រាជ្ញា ដែល ត្រាស់ដឹងឧបាយដែលនឹងចេញចាកបាប ជាជាងបុគ្តលដទៃ ។

• « *បុព្វេនិវាសានុស្សតិញ្ញាណេ* » ព្រះអង្តប្រសើរដោយប្រាជ្ញា ជា ត្រៀងដឹងនូវបុព្វេនិវាស ។

• « *ទិព្វចក្ខុញ្ញាណេ* » ព្រះអង្តប្រសើរលើសដោយទិព្វចក្ខុ ។

• « *កម្មវិបាកញ្ញាណេ* » ព្រះអង្តប្រសីរលើសដោយបញ្ញា សម្រាប់ ត្រាស់ដឹងនូវកុសលកម្ម និងអកុសលកម្មរបស់សត្ត ។

• « *យមកប្បាដិហារិយញ្ញាណេ* » ព្រះអង្តប្រសើរលើសដោយបញ្ញា ឈ្លាសក្នុងការសំដែងយមកប្បាដិហារ្យ ។

• « *លោកវិវរណប្បាដិហារិយញ្ញាណេ* » ព្រះអង្តប្រសើរដោយប្រាជ្ញា ធ្វើបាដិហារ្យ បើលោកឱ្យសត្វនរក និងមនុស្ស និងទេវតា មើលឃើញគ្នាទៅវិញទៅ មក ដូចកាលដែលព្រះអង្តសំដែងសត្តប្បករណាភិធម្មចប់ហើយ ស្តេចយាងចុះចាក ស្ថានតាវតឹង្សមកនោះឯង ។

• « *អាបត្តិកុសលតាយ* » ព្រះអង្តប្រសើរលើសដោយភាពជាអ្នក

ឈ្លាសក្នុងអាបត្តិ និងអនាបត្តិ ។

• « *អាបត្តិវុដ្ឋានកុសលតាយ* » ព្រះអង្គប្រសើរដោយភាពជាអ្នកឈ្លាសក្នុងពុទ្ធប្បញ្ញត្តិ កាលបើកុលបុត្រមានសេចក្តីប្រហែសធ្វេសភ្លេចភ្លាំងស្មារតីត្រូវអាបត្តិ ទ្រង់ព្រះមហាករុណាអនុញ្ញាតឱ្យធ្វើនូវកិច្ចចាកអាបត្តិនោះបាន ។

• « *ធាតុកុសលតាយ* » ព្រះអង្គប្រសើរដោយភាពជាអ្នកឈ្លាសក្នុងឧបាទិន្នកធាតុរបស់សត្វ និងអនុបាទិន្នកធាតុនៃផែនដី **ភ្នំរុក្ខជាតិ** និងធាតុនៃសត្វដែល ត្រេកអរដោយបថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

• « *មនសិការកុសលតាយ* » ព្រះអង្គប្រសើរដោយការឈ្លាសក្នុងកិរិយាធ្វើទុកក្នុងចិត្ត គឺថា បើព្រះអង្គកំណត់របស់អ្វីទុកក្នុងព្រះទ័យហើយ របស់នោះ គឺព្រះអង្គមិនភ្លេចឡើយ ។

• « *ឋានាឋានកុសលតាយ* » ព្រះអង្គប្រសើរលើសដោយភាពជាអ្នកឈ្លាសក្នុងហេតុ និងមិនមែនហេតុ ។ ហេតុនោះ សំដៅយកកុសលហេតុ ៣ យ៉ាង គឺ *អលោភោ ១ អទោសោ ១ អមោហោ ១* ។

• « *ទ្វីសុ ឥទ្ធីសុ* » ព្រះអង្គប្រសើរលើសដោយឫទ្ធិ ២ ប្រការគឺ *ចិត្តិទ្ធិ* ទ្រង់ផ្តែងឫទ្ធិដោយព្រះទ័យ ១ *វីមំសិទ្ធិ* ទ្រង់ផ្តែងឫទ្ធិដោយព្រះបញ្ញា ១ ។

• « *ទ្វីសុ អនុត្តរិយេសុ* » ព្រះអង្គប្រសើរដោយអនុត្តរិយៈ ២ ប្រការ គឺ *សីលានុត្តរិយៈ ១ បញ្ញានុត្តរិយៈ ១* ។

• « *តីសុ កថាវត្ថូសុ* » ព្រះអង្គប្រសើរលើលដោយកថាវត្ថុ ៣ គឺ *ទាន ១ សីល ១ ភាវនា ១* ។

• « *តីសុ សមាធីសុ* » ព្រះអង្គប្រសើរលើសដោយសមាធិ ៣ គឺ *វិតក្ក.វិចារសមាធិ* សមាធិដែលប្រកបដោយវិតក្កវិចារ ១ *អវិតក្កវិចារសមាធិ* សមាធិមិនមានវិតក្កប្រកបដោយវិចារ ១ *អវិតក្កអវិចារសមាធិ* សមាធិមិនមានវិតក្ក មិនមានវិចារ ១ ។

• « *តីសុ បាដិហារិយេសុ* » ព្រះអង្គប្រសើរដោយបាដិហារ្យ ៣ យ៉ាង គឺ កាលទ្រង់ឡើងធម្មាសនៈ ១ កាលទ្រង់កំពុងសំដែងធម្មទេសនា ១ កាលទ្រង់ចុះចាកធម្មាសនៈ ១ ។

• « *ចតូសុ សតិបដ្ឋានេសុ* » ព្រះអង្គប្រសើរក្នុងសតិបដ្ឋានទាំង ៤ គឺ *កាយានុបស្សនាសតិបដ្ឋាន ១ វេទនានុបស្សនាសតិបដ្ឋាន ១ ចិត្តានុបស្សនា.សតិបដ្ឋាន ១ ធម្មានុបស្សនាសតិបដ្ឋាន ១* ។

• « *ចតូសុ សម្បទាសុ* » ព្រះអង្គប្រសើរក្នុងសម្បទា ៤ គឺ *ចេតនា.សម្បទា* បរិបូណ៌ដោយចេតនាចី[1] ១ *បច្ចយសម្បទា* បរិបូណ៌ដោយបច្ច័យ ៤ មានចីវរបច្ច័យជាដើម ១ *វត្ថុសម្បទា* បរិបូណ៌ដោយវត្ថុ ១ *គុណាតិរេកសម្បទា* បរិបូណ៌ដោយគុណ ដែលព្រះអរិយបុគ្គលទើបចេញពីនិរោធសមាបត្តិ[2] ១ ។

• « *ចតូសុ ឥទ្ធិបាទេសុ* » ព្រះអង្គប្រសើរក្នុងឥទ្ធិបាទទាំង ៤ គឺ *ឆន្ទិទ្ធិបាទ ១ វីរិយិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ វីមំសិទ្ធិបាទ ១* ។

• « *ចតូសុ មគ្គេសុ ចតូសុ ផលេសុ* » ព្រះអង្គប្រសើរក្នុងមគ្គ ៤ ផល ៤ មានសោតាបត្តិមគ្គ និងសោតាបត្តិផល ជាដើម ។

• « *ចតូសុ អរិយវំសេសុ* » ព្រះអង្គប្រសើរដោយអរិយវង្ស ៤ គឺ

---

(១) បុព្វចេតនា ១ មុញ្ចនចេតនា ១ អបរាបរចេតនា ១ ។ (២) ព្រះអរិយបុគ្គល ២ ពួកគឺ ព្រះអនាគាមី និងព្រះអរហន្ត ។ (៣) វិមុត្តិ ៤ យ៉ាងទៀតគឺ តទង្គវិមុត្តិ បានដល់កាមាវចរកុសល ១ វិក្ខម្ភនវិមុត្តិ បានដល់រូបាវចរ.កុសល ១ បស្សទ្ធិវិមុត្តិ បានដល់លោកុត្តរកុសល ១ និស្សរណវិមុត្តិ បានដល់ព្រះនិព្វាន ១ ។

អប្បិច្ឆោ មានសេចក្តីប្រាថ្នាតិច ១ *សលេខោ* មានសេចក្តីសន្តោស ១ *សន្ទោ* មានកិរិយាជឿបារមីទាំង ១០ មានទានបារមីជាដើម ១ *សីលំ* រក្សាសីល ៥ សីល ៨ និងចតុបារិសុទ្ធិសីល ១ ។

• « *ចតូសុ វិមុត្តិញ្ញាណេសុ* » ព្រះអង្គប្រសើរដោយវិមុត្តិ[(៣)] គឺ *បញ្ញាវិមុត្តិ* រួចចាកបាបធមិទាំងពួងដោយលោកុត្តរប្បញ្ញា, *សមុច្ឆេទវិមុត្តិ* រួចចាកបាបធមិទាំងពួងដោយការលះកាត់ដាច់ស្រឡះ ១ *វិក្ខម្ភនវិមុត្តិ* រួចចាកបាបធមិទាំងពួងដោយសង្កត់សង្កិន ១ *តទង្គវិមុត្តិ* រួចចាកបាបធមិទាំងពួងបានតែមួយខណៈ១ ១ ។

• « *បញ្ចពលេសុ* » ព្រះអង្គប្រសើដោយពលៈ ៥ គឺ *សទ្ធា ១ សតិ ១ វីរិយៈ ១ សមាធិ ១ បញ្ញា ១* ។

• « *បញ្ចិន្ទ្រិយេសុ* » ព្រះអង្គប្រសើរដោយឥន្ទ្រិយ ៥ គឺ *សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១* ។

• « *បញ្ចាភិញ្ញាសុ* » ព្រះអង្គប្រសើដោយអភិញ្ញា ៥ គឺ *ទិព្វចក្ខុ ១ ទិព្វសោត ១ ឥទ្ធិវិធិ ១, បរចិត្តវិជ្ជា ១ បុព្វេនិវាសានុស្សតិ ១ ជា ៥*[(១)] *ថែម អាសវក្ខយៈ ១ ទៀត ជាអភិញ្ញា ៦* ។

• « *ឆអសាធារណញ្ញាណេសុ* » ព្រះអង្គប្រសើរដោយអសាធារណញ្ញាណ ៦ គឺ *អាសយានុសយញ្ញាណ* ប្រាជ្ញាឈ្វេងយល់នូវអាសយានុសយធមិរបស់សត្ត ១ *ឥន្ទ្រិយបរោបរិយត្តិញ្ញាណ* ប្រាជ្ញាឈ្វេងយល់នូវឥន្ទ្រិយដ៏ទន់ និងក្លៀវក្លារបស់សត្វដទៃ ១ *យមកប្បាដិហារិយញ្ញាណ* ប្រាជ្ញាវាងវៃក្នុងការសំដែងយមកប្បដិហារ្យ ១ *មហាករុណាសមាបត្តិញ្ញាណ* ប្រាជ្ញាឈ្លាសក្នុងការដោះទុក្ខសត្វក្នុង

---

(១) ពួកបុថុជ្ជន មានបានតែអភិញ្ញា ៥ ដែលជាលោកិយ ឯព្រះអរិយបុគ្គលជាម្ចាស់ មានព្រះពុទ្ធជាដើម ទើបបានអាសវក្ខយវិជ្ជា ដែលជាលោកុត្តរ ។ ២) ចិត្តវិសុទ្ធិ បានដល់សមាធិ ២ យ៉ាងគឺ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ។

ពេលចេញចាកសមាបត្តិ ១ *សព្វញ្ញុតញ្ញាណ* ប្រាជ្ញាដឹងសព្វគ្មានចន្លោះ ១ *អនាវរណញ្ញាណ* ប្រាជ្ញាដឹងឥតចើសទាក់ ១ ។

• « *សត្តវិសុទ្ធិទេសនាសុ* » ព្រះអង្គប្រសើរដោយវិធីទេសនានូវវិសុទ្ធិទាំង ៧ គឺ *សីលវិសុទ្ធិ* បរិសុទ្ធក្នុងចតុបារិសុទ្ធិសីល ១ *ចិត្តវិសុទ្ធិ*[(២)] បរិសុទ្ធចិត្ត ១ *ទិដ្ឋិវិសុទ្ធិ* បរិសុទ្ធប្រាជ្ញាពិចារណាត្រូវ ១ *កង្ខាវិតរណវិសុទ្ធិ* បរិសុទ្ធផុតចាកសេចក្តីសង្ស័យ ១ *មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ* បរិសុទ្ធប្រាជ្ញាពិចារណានូវខន្ធ ៥ ស្គាល់ថាជាអតីត បច្ចុប្បន្ន ហើយចិត្តយាងចុះកាន់ត្រៃលក្ខណ៍ដឹងជាក់ថាជាមគ្គ ឬមិនមែនមគ្គ ១ *បដិបទាញ្ញាណទស្សនវិសុទ្ធិ* បរិសុទ្ធប្រាជ្ញាពិចារណាឃើញមគ្គ ៤ ផល ៤, ១ *ញាណទស្សនវិសុទ្ធិ* បរិសុទ្ធដោយលោកុត្តរប្បញ្ញាទាំង ៨ មានសោតាបត្តិមគ្គញ្ញាណ ជាដើម មានអរហត្តផលញ្ញាណ ជាទីបំផុត ១ ។

• « *សត្តខីណាសវពលេសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវអរិយបុគ្គល ៧ ជំពូក មានសោតាបត្តិមគ្គដ្ឋៈជាដើម មានអរហត្តមគ្គដ្ឋៈជាទីបំផុត ថាបុគ្គលជាន់នេះ មានកម្លាំងអាចលះបង់អាសវកិលេសបានប៉ុណ្ណេះ ។

• « *នវសត្តាវាសទេសនាសុ* » ព្រះអង្គប្រសើរក្នុងការសំដែងនូវទីលំនៅរបស់សត្វទាំង ៩ ដែលហៅថា « សត្តាវាស » ដូចសំដែងរួចក្នុងខាងដើមហើយ ។

• « *ទសកសិណាយតនេសុ* » ព្រះអង្គប្រសើរក្នុងកសិណ ១០ គឺ *បថវីកសិណ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោកសិណ ១ នីលកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ អាកាសកសិណ ១ អាលោកកសិណ ១* ។

• « *ឯកាទសមេត្តានិសង្សទេសនាសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវអានិសង្សអ្នកផ្សាយមេត្តាចិត្ត ១១ គឺ *សុខំ សុបតិ* ដេកលក់ស្រួល ១

សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងស្រួល ១ *ន បាបកំ សុបិនំ បស្សតិ* មិនយល់សប្តអាក្រក់ ១ *មនុស្សានំ បិយោ ហោតិ* ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ ១ *ទេវតា រក្ខន្តិ* មានទេវតារក្សា ១ *នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ* ភ្លើងមិនឆេះ អសិរ្ពិស មិនហ៉ានប្ឋេតប្ឋេន និងមិនមានរបួសដោយគ្រឿងសស្ត្រាវុធ ១ *ចិត្តំ សមាធិយតិ* ចិត្តតាំងនៅនឹងនួន ១ *មុខវណ្ណោ វិប្ឋសីទតិ* សម្ឃុរមុខជ្រះថ្លា ១ *អសម្មុឡ្ហោ កាលំ ករោតិ* មិនវង្វេងក្នុងពេលធ្វើកាលកិរិយា ១ *ឧត្តរឹ អប្ឋដិវិជ្ឈន្តោ ព្រហ្មលោក្ឯ-បគា ហោតិ* បើមិនបានចាក់ធ្លុះនូវធមិជាន់ខ្ពស់ បានតែត្រឹមឈានសមាបត្តិ ពេលដែលច្យុតបានទៅកើតក្នុងព្រហ្មលោក ១ រួមជា ១១ ។

• « *ទ្វាទសាកុសលទេសនាសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវវារៈទឹកចិត្តនៃបុគ្គលដែលមានបាបប្រកបដោយអកុសលចិត្ត ១២ គឺ *លោភ: ៨ ទោស: ២ មោហ: ២* ។

• « *តេរស ធុតង្គគុណេសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវធុតង្គគុណ ១៣ គឺ *អារញ្ញិក ១ បត្តបិណ្ឌិក ១ បិណ្ឌបាតិក ១ តេចីវរិក ១ នេសជ្ជិក ១ ឯកាសនិក ១ សបទានចារិក ១ យថាសន្ថតិក ១ ខលុបច្ឆាភត្តិក ១ រុក្ខមូលិក ១ អព្ភោកាសិក ១ បំសុកូលិក ១ សោសានិក ១* ជា ១៣ ប្រការ ។

• « *ចុទ្ទសពុទ្ធញ្ញាណេសុ* » ព្រះអង្គប្រសើរដោយពុទ្ធញ្ញាណ ១៤ គឺ *ទុក្ខេញ្ញាណំ* ប្រាជ្ញាពិចារណាយើញទុក្ខសច្ច ១ *ទុក្ខសមុទយេ ញ្ញាណណំ* ប្រាជ្ញាពិចារណាយើញសមុទយសច្ច ១ *ទុក្ខនិរោធេ ញ្ញាណំ* ប្រាជ្ញាពិចារណាយើញនិរោធេសច្ច ១ *ទុក្ខនិរោធគាមិនីបដិបទាយ ញ្ញាណំ* ប្រាជ្ញាពិចារណាយើញមគ្គសច្ច និង *អត្ថបដិសម្ភិទា ១ ធម្មបដិសម្ភិទា ១ និរុត្តិបដិសម្ភិទា ១ បដិភាណបដិសម្ភិទា ១* រួមត្រូវជា ពុទ្ធញ្ញាណ ៨ យកអសាធារណញ្ញាណ ៦ មកផ្សំផងទៀត ត្រូវជាព្រះពុទ្ធញ្ញាណ ១៤ ។

• « *ឯកវិសតិកុសលទេសនាសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវទេសនាព្រះសង្គណិប្បករណៈ ចែកកុសល ២១ គឺ កាមាវចរកុសល ៨ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ ជា ២១ ។

• « *ចតុវិសតិបច្ចយទេសនាសុ* » ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវទេសនាព្រះមហាបដ្ឋានដែលប្រកបដោយបច្ច័យ ២៤ មានហេតុប្បច្ច័យ ជាដើម មានអវិគតប្បច្ច័យជាទីបំផុត ។

• « *កោដិសតសហស្សសញ្ញិតធម្មវជិរញ្ញាណេសុ* » ព្រះអង្គប្រសើរដោយវជិរញ្ញាណ ដែលត្រាស់ដឹងនូវព្រះធម្មក្រៃលែងសែនកោដិ រកទីបំផុតគ្មាន គឺ *ទុកបដ្ឋាន តិកបដ្ឋាន ទុកតិកបដ្ឋាន តិកទុកបដ្ឋាន* នេះឯង ។

• « *ឥតិ ភគវា អនុត្តរោ* » សម្តេចព្រះដ៏មានព្រះភាគប្រសើរក្នុងធម៌ទាំងឡាយ ដូចពណ៌នាមកនេះ បានជាទ្រង់ព្រះនាមថា " អនុត្តរោ " ប្រែថា « ព្រះអង្គប្រសើរកបុគ្គលណាស្មើគ្មាន » ។

ចប់បទ « អនុត្តរោ » ដោយសង្ខេប

កែបទ « បុរិសទម្មសារថិ [1] »

បុ. ព្រោះហេតុអ្វីបានជាព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា « បុរិសទម្ម-សារថិ » ?

វិ. បានជាទ្រង់ព្រះនាមថា « បុរិសទម្មសារថិ » ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

បុ. បុរសដូចម្តេចដែលហៅថា « អ្នកមានឧបនិស្ស័យ » ?

វិ. បុរសដែលបានកសាងបារមីអំពីអតីតជាតិ គឺ បានឱ្យទាន, រក្សាសីល, ចំរើនភាវនា, ស្តាប់ធម៌ទេសនាជាដើម ទោះបីតិចក្តី ច្រើនក្តី ល្មមជាបច្ច័យឱ្យព្រះអង្គទូន្មានបាន ហើយស្ថិតនៅក្នុងគុណធម៌ជាន់ទាបក្តី ជាន់ខ្ពស់ក្តី តាមសមគួរដល់ការកសាងរបស់ខ្លួននោះ ហៅថា « បុរសមានឧបនិស្ស័យ » ។

បុ. ចុះបុរសដែលមានឧបនិស្ស័យនោះ គួរទូន្មានបានតែព្រះពុទ្ធ ១ ព្រះអង្គទេឬ ឬក៏ពួកសាវ័កដទៃ១ គួរទូន្មានបានខ្លះដែរ ? ។

វិ. ការទូន្មាននូវបុរសដែលមានឧបនិស្ស័យនោះ១ មិនបានចំពោះតែព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះទេ ទោះបីសាវ័កដទៃ១ ក៏ត្រូវទូន្មានបានខ្លះ ពីព្រោះ បុរសដែលគួរទទួលយកដំបូន្មានបាននោះ ចែកចេញជា ២ គឺ *ពុទ្ធវេនេយ្យ ១ សាវក-វេនេយ្យ ១* ។ ពុទ្ធវេនេយ្យ អ្នកដែលគួរព្រះពុទ្ធប្រោសបាន សាវកវេនេយ្យ អ្នកដែលគួរសាវ័កប្រោសបាន ព្រះមុនីសាស្តាទ្រង់ជ្រាបច្បាស់ថា សត្វណាដែលគួរព្រះអង្គប្រោសបាន ទើបទ្រង់យាងទៅប្រោសដោយព្រះអង្គឯង បើសត្វណាគួរដល់សាវ័ក

---

(១) ព្រះនាមនេះ បើរួមទ្វន្ទនឹងព្រះនាមថា « អនុត្តរោ » ខាងដើម ជាព្រះនាមតែមួយក៏បាន ចែកចេញជា ២ ដូចន័យនេះក៏បាន ។

ព្រះអង្គក៏ចាត់សាវ័កឱ្យទៅប្រោស ។

ប៊. ក្នុងវិធីដែលនឹងប្រៀនប្រដៅសត្វ តើព្រះបរមគ្រូទ្រង់ប្រើឧបាយបែបណា ?

វិ. ទ្រង់ប្រើវិនយូបាយ គឺ ឧបាយជាគ្រឿងណែនាំពន្យល់អំពីទោស និងអានិសង្ស ឱ្យសត្វចូលចិត្តស្រឡាញ់ ឱ្យវៀរ គឺ បើសត្វណាគាប់ចិត្តនឹងពាក្យពិរោះផ្អែម ព្រះអង្គក៏សំដែងអំពីសុចរិត ៣ ប្រការ មានកាយសុចរិតជាដើម និងអានិសង្សរបស់សុចរិតឱ្យសត្វកើតសេចក្តីរីករាយ បើសត្វណាចូលចិត្តនឹងពាក្យជ្រោកជ្រាក ព្រះអង្គទូន្មានដោយពាក្យជ្រោកជ្រាក គឺទ្រង់ប្រកាសទុច្ចរិតទាំង ៣ ប្រការ មានកាយទុច្ចរិតជាដើម និងផលរបស់ទុច្ចរិត ដើម្បីឱ្យសត្វភិតភ័យ ខំប្រឹងវៀរឡើងហើយនិងបានតម្កល់នៅក្នុងកុសលធម៌ ។ ប្រការមួយទៀត ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅសត្វដោយអាការ ៣ យ៉ាង គឺ :

. *អភិញ្ញា* ទ្រង់ប្រដៅឱ្យសត្វដឹងជាក់ស្តែង នូវគុណនិងទោស ជាដើម ១

. *សនិទាន* ទ្រង់ប្រដៅតាមដំណើរហេតុដំណើររឿង ១

. *សប្បាដិហារិយ* ទ្រង់ប្រដៅប្រកបដោយបាដិហារិយ ១ [1] ។

ព្រះអង្គជាគ្រូ ទ្រង់ឈ្លាសវៃក្នុងវិធីប្រៀនប្រដៅសត្វ ដូចវេជ្ជាចារ្យ ឬអស្សាចារ្យដែលប៊ិនប្រសប់ហ្វឹកហ្វឺនប្រដៅនូវគជសា និងអស្សតរ ពីព្រោះ ព្រះអង្គជ្រាបច្បាស់នូវសត្វលោកសព្វទាំងអស់ ដូចបានអធិប្បាយរួចហើយក្នុងបទលោកវិទូ សត្វណាមានចរិតយ៉ាងណា ឫក្សពាមារយាទយ៉ាងណា ក៏ទ្រង់ជ្រាបបានទាំងអស់ម្ល៉ោះហើយបានជាទ្រង់ប្រដៅសត្វចេះតែលុះក្នុងពាក្យដ៏ប្ញទ្ធានព្រះអង្គទាំងអស់

---

(១) អនុសាសនីបាដិហារ្យ ទ្រង់ប្រដៅដោយកិរិយាដាស់តឿនក្រើនរំលឹក ១ ឥទ្ធិប្បាដិហារ្យ ទ្រង់ប្រដៅដោយសំដែងឫទ្ធិ ១ អាណាទេសនាបាដិហារ្យ ទ្រង់ប្រដៅដោយសំដែងអំណាច ១ ។

ហេតុនេះទើបទ្រង់មានស្មាដៃ ថ្វីព្រះឱស្ឋល្បីថា « បុរិសទម្មសារថិ » ព្រះអង្គជាអ្នកទូន្មានន្ទវបុរសដែលមាន ឧបនិស្ស័យគួរនឹងទូន្មានបាន ។

ប. មុខគួរឱ្យងឿងឆ្ងល់ត្រង់ពាក្យថា « បុរស ១ » សំដៅយកតែមនុស្សប្រុស បើដូច្នោះព្រះពុទ្ធជាម្ចាស់ប្រដៅតែប្រុស១ មិនប្រដៅស្រី១ ផងទេឬ ?

វិ. មិនមែនដូច្នោះទេ ព្រះពុទ្ធជាម្ចាស់ប្រដៅបានទាំងអស់ ទាំងបុរស ទាំងស្ត្រី តែក្នុងទីនេះបានជាលោកចេញឈ្មោះតែបុរស ពីព្រោះ បុរសជាឧក្កដ្ឋជាតិ ជាតិខ្ពស់ជាងស្ត្រី ។ ស្ត្រីជាហីនជាតិ ជាតិទាបជាងបុរស បានជាលោកតាំងបុរសនេះដាក់ជាប្រធាន តែគង់សាធារណៈដល់ស្ត្រីផងដែរ ។

ប. ចុះបុរសដែលព្រះអង្គទូន្មានបាន ចំពោះតែជាតិមនុស្សទេឬ ?

វិ. មិនចំពោះតែជាតិមនុស្សទេ បុរសដែលព្រះអង្គទូន្មានបានមាន ៣ ពួក គឺ *តិរច្ឆានបុរសពួក ១ មនុស្សបុរសពួក ១ អមនុស្សបុរសពួក ១* ។

តិរច្ឆានបុរស ដែលព្រះអង្គទូន្មានបាន ដូចយ៉ាង អបលាលោនាគរាជ ដែលនៅអាស្រ័យក្នុងហេមវន្តប្រទេស ចុល្លោទរនាគរាជ និងមហោទរនាគរាជ ដែលនៅអាស្រ័យក្នុងនាគទ្វីប អគ្គិសិខនាគរាជ និងធូមសិខនាគរាជ ដែលនៅអាស្រ័យក្នុងសីហលទ្វីប ហើយនិងអាឡវ្ហាឡនាគរាជជាដើម ព្រះអង្គទ្រង់ព្រះមហាករុណាស្តេចយាងទៅទូន្មានដោយបាដិហារ្យផ្សេង១ ញុំាងស្តេចនាគទាំងឡាយនោះឱ្យលះព្យុះកំណាចចោលសូន្យចាកពិស គឺទោសោ ហើយតាំងនៅក្នុងព្រះត្រៃសរណគមន៍ និងសីល ។ ដីរិធនបាលហស្តិន្ទសោតទៀត ក៏ព្រះអង្គទូន្មានឱ្យតាំងនៅក្នុងព្រះត្រៃសរណគមន៍ ។ តិរច្ឆានបុរសដែលព្រះអង្គទូន្មានបាន មិនមានតែត្រឹមប៉ុណ្ណេះទេ នៅមានច្រើនតទៅទៀត ។

មនុស្សបុរស ដែលប្រព្រឹត្តធ្វើអំពើទុច្ចរិតប្រកាន់ធមិលាមក ប្រកបដោយទិដ្ឋិ យ៉ាងសច្ចកនិគ្រណ្ឌបុត្ត អម្ពដ្ឋមាណព បោក្ខរសាសាតិព្រាហ្មណ៍ សោណ-ទណ្ឌព្រាហ្មណ៍ ក្ខដទន្តព្រាហ្មណ៍ជាដើម ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះមហាករុណាទ្ធន្មានដោយព្រះសទ្ធម្មទេសនាជាអនេកបរិយាយ ត្រាតែកើតសេចក្តីជ្រះថ្លា ជឿគុណព្រះរតនត្រ័យ លះបង់ទិដ្ឋិចោល កាន់យកសម្មាទិដ្ឋិបានសម្រេចមគ្ត និងផល ។ មនុស្សបុរសដែលលុះក្នុងសំណាញ់ញាណរបស់ព្រះអង្ត ហើយទ្រង់ទ្ធន្មានបាន មិនមែនមានប្រមាណតិចទេ គឺច្រើនពន់ពេកណាស់ ។ ឯមនុស្សបុរសនោះ ដូចយ៉ាងអាឡវកយក្ស សុចិលោមយក្ស ខលោមយក្ស អម្រិន្ទ្រាធិរាជ និងពកាព្រហ្មជាដើម សុទ្ធតែប្រកបដោយទិដ្ឋិយ៉ាងទ្រនង់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ទ្ធន្មានដោយឧបាយទាំងឡាយដ៏វិចិត្រ គឺព្រះសទ្ធម្មទេសនា ត្រាតែមានសេចក្តីជ្រះថ្លាក្នុងរតនត្រ័យជាភិយ្យោភាព ។

បុ. ពាក្យសំដីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ទ្ធន្មានសត្ធ តើយ៉ាងណាខ្លះ ?

វិ. ពាក្យសំដីព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ទ្ធន្មានសត្ធ មានវិចិត្រច្រើនប្រការពិស្តារណាស់ ព្រោះកាលដែលទ្រង់ប្រៀនប្រដៅ តែងប្រដៅអនុលោមតាមចរិត និងនិស្ស័យ វាសនា តាមសតិបញ្ញារបស់វេនេយ្យសត្ធ និងអនុលោមតាមឧបត្តិហេតុ និងតាមកាល តាមសម័យ តាមទំនៀមស្រុកប្រទេសខ្លះ ព្រោះហេតុនោះបានជាមានន័យជាអនេកបរិយាយ តែបើរួបរួមឱ្យខ្លីចុះមក ទោះបីច្រើនម្លោះ ក៏គង់ចូលមកនៅក្នុងពាក្យ ៣ ម៉ាត់ គឺ :

- សព្វបាបស្ស អករណំ ទ្រង់ប្រដៅមិនឱ្យធ្វើបាបគ្រប់យ៉ាង ១ ,
- កុសលស្ស្ឱបសម្បទា ទ្រង់ប្រដៅឱ្យសន្សំទុកនូវកុសល ១ ,
- សចិត្តបរិយោទបនំ ទ្រង់ប្រដៅឱ្យដុសខាត់ចិត្តរបស់ខ្លួនឱ្យផ្ទរផង់ ១ ។

សេចក្តីអធិប្បាយទី ១ ព្រះអង្គប្រដៅមិនឱ្យធ្វើអំពើអកុសលគ្រប់ជំពូក គឺឱ្យវៀរចាកទុច្ចរិត កិរិយាប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត មានសម្លាប់សត្ត និងលួចទ្រព្យគេជាដើម ; ទី ២ ព្រះអង្គប្រដៅឱ្យសន្សំទុកនូវកុសលធមិ គឺបុញ្ញកិរិយាវត្ថុ ១០ មានទានជាដើម ; ទី៣ ព្រះអង្គប្រដៅឱ្យដុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតចាកអនុ-សយកិលេស គឺសេចក្តីសៅហ្មងរបស់ចិត្ត ដែលដេកត្រាំនៅក្នុងសន្តានចិត្តសត្ត ជាកិលេសដ៏គ្រោតគ្រាតខ្លះ ល្អិតខ្លះ ណាដែលគ្រោតគ្រាតមានសម្លាប់សត្ត និងសម្លឹងរំពៃចង់បានទ្រព្យអ្នកដទៃមកជារបស់ខ្លួនជាដើម អាចលះបង់បានដោយអំណាចសីល ឬសមាធិណាដែលល្អិត ជាដើមហេតុ ជាមេឱ្យកើតកិលេសដទៃ ដូចឬសកៃវនោះ តោងលះដោយបញ្ញា ។ ក៏ឯពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ប្រើរូមឱ្យខ្លីចុះមក នៅត្រឹមតែពាក្យពីរម៉ាត់ គឺ :

- ប្រដៅឱ្យលះសេចក្តីប្រមាទ,
- ប្រដៅឱ្យចំរើនអប្បមាទ ។

បមាទ គឺសេចក្តីធ្វេសប្រហែស មានកិរិយាភ្ជាំងភ្លេចស្មារតី ឬបណ្តែតបណ្តោយស្មារតីជាលក្ខណៈ ។ បមាទនេះជាមេកំពូលនៃអកុសលទាំងពួង តែងកើតឡើងដោយសារបមាទ ដែលនឹងរកឱកាសចូលមកលុកលុយក្នុងខន្ធសន្តានរបស់សត្ថបាន ក៏អាស្រ័យសេចក្តីប្រមាទនេះដែរ ព្រោះហេតុនោះទើបបានជាព្រះបរមគ្រូទ្រង់ប្រដៅឱ្យលះបង់សេចក្តីប្រមាទ ។

ឯអប្បមាទនោះ បានដល់ការមិនធ្វេសប្រហែស គឺប្រុងប្រយ័ត្ន មានមិនភ្លាំងភ្លេចស្មារតី ឬមិនបណ្តែតបណ្តោយស្មារតីជាលក្ខណៈ កាលបើសេចក្តីមិនធ្វេសប្រហែសនេះមានហើយ សត្ថរមែងប្រឹងប្រែងធ្វើកុសល មានទានជាដើម ដើម្បីបិទផ្លូវមិនឱ្យអកុសលធមិចូលមកលុកលុយក្នុងខន្ធសន្តានបាន ព្រោះហេតុ

នោះបានជាមានព្រះពុទ្ធបរិហារថា « *បណ្ឌិតគេតែងបន្ទោរបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ* » គឺបើសេចក្តីមិនប្រមាទកំពុងមាននៅ ធ្វើម្តេចឡើយ សេចក្តីប្រមាទនឹងរកឱកាសចូលមកបាន ។ សេចក្តីមិនប្រមាទនេះជាដើមនៃកុសល. ធម៌ទាំងពួង ជាប្រឡាយបង្ហូរកុសលមកក្នុងខន្ធសន្តាន ជាមេនាំមុខកុសលឱ្យកើត ប៉ែកខាងកុសលធម៌ទាំងអស់ ធំចម្បងជាងគេនៅលើអប្បមាទ ប្រៀបដូចជាដានជើងដ៏រឹងធំក្រៃលែង ដានជើងសត្វម្រឹគផងទាំងពួង ដានជើងសត្វទាំងពួងដ៏សេស រមែងជាន់ចុះក្នុងដានជើងដ៏រឹងបានទាំងអស់ ។ យ៉ាងណាមិញ កុសលធម៌ទាំងពួង ក៏ដូច្នោះដែរ រមែងប្រជុំចុះមកក្នុងអំណាចអប្បមាទនេះទាំងអស់ ពីព្រោះ អប្បមាទ. ធម៌ជាចម្បង ហេតុហ្នឹងហើយបានជាព្រះបរមគ្រូ វេលាទ្បើបស្តេចនឹងចូលកាន់និព្វាន ទ្រង់ឈ្បោងព្រះនេត្រាទៅមើលបរិស័ទទាំង ៤ គឺ ភិក្ខុ ១ ភិក្ខុនី ១ ឧបាសក ១ ឧបាសិកា ១ អង្គុយប្រជុំគ្នាត្រៀបត្រា ខ្លះមានមុខក្រៀមក្រំ សញ្ជប់សញ្ជឹង ខ្លះមានជលនេត្រាហូរសស្រាក់ ដោយខ្លោចផ្សាចិត្ត នឹកស្តាយស្រណោះ ព្រះជាគ្រូទ្រង់ទតឃើញ ក៏មានព្រះទ័យអាណិតអាសូរ ងាកបែរព្រះភក្ត្រទៅរក ហើយស្តេចខំប្រឹងមានព្រះពុទ្ធដីកាផ្តែផ្តាំទាំងកំពុងប្រឈួនខ្លាំងក្លា « *សង្ខារធម៌ទាំងឡាយរមែងវិនាសសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងប្រយោជន៍របស់ខ្លួនឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះណា !* » ។ ពាក្យប៉ុណ្ណេះនេះហើយដែលជាពាក្យផ្តែផ្តាំបង្ហើយក្រោយបំផុតរបស់ព្រះពុទ្ធជាបរមគ្រូ ហៅថា «បច្ឆិមពុទ្ធវចនៈ» ព្រះពុទ្ធបណ្តាំចុងក្រោយបំផុត ។ លុះទ្រង់មានព្រះបន្ទូលផ្តែផ្តាំស្រេចហើយ ព្រះទ័យព្រះអង្គក៏ឡើងស្រឹតតាមថ្នាក់ឈានទាំង ៤ និងអរូបជ្ឈាន ដរាបដល់ផុតវេទនា និងសញ្ញា ចូលសញ្ញាវេទយិតនិរោធ ហើយត្រឡប់ថយមកតាមកន្លែងដើម រួចឡើងរហូតដល់ចតុត្ថជ្ឈានវិញ ទើបស្តេចទ្រង់រំលត់ខន្ធចូលកាន់ព្រះនិព្វានក្នុងរវាងនោះឯង ។

ក៏ពាក្យថា « មិនប្រមាទ » មួយម៉ាត់នេះ ជាកំពូលនៃធមិទាំងពួង ព្រោះ ហេតុនោះ ក្នុងពេលដែលព្រះជាគ្រូទ្រង់ព្រះពុទ្ធដំណើរចូលកាន់ព្រះនិព្វាន ស្តេចគ្រាន់តែផ្តែផ្តាំថា « កុំប្រមាទ » ប៉ុណ្ណោះ ហាក់ដូចជាទ្រង់ត្រាស់សំដែងធមិទាំងឡាយដែលទ្រង់បានសំដែងរួចហើយថែមមួយត្រួតទៀត ពីព្រោះ ពាក្យបណ្តាំថា « កុំប្រមាទ » គឺត្រូវឱ្យថែទាំមរតក គឺព្រះធមិ វិន័យ ដែលទ្រង់បានចែករំលែកទុកឱ្យ ហើយ អស់ ៤៥ ឆ្នាំ នោះទាំងអស់ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គឈ្លាសវៃក្នុងវិធីអនុគ្រោះស្រោចស្រង់សត្វដោយបរិយាយដ៏វិចិត្រ មុខគួរឱ្យសត្វស្រណោះ ឱ្យសត្វចង់ស្តាប់ចង់ធ្វើតាម ដូចសេចក្តីដែលបានពណិនាមកនេះ ទើបទ្រង់ព្រះនាមថា « បុរិសទម្មសារថិ » ព្រះអង់ប៊ុនប្រសប់ទូន្មាននូវបុរសដែលមានឧបនិស្សយគួរនឹងទូន្មានបាន ។

ចប់បទ « បុរិសទម្មសារថិ » ដោយសង្ខេប

កែបទ « សត្ថាទេវមនុស្សានំ »

បុ. ព្រះសម្មាសម្ពុទ្ធដ៏មានជោគ ហេតុដូចម្តេចបានជាទ្រង់ព្រះនាមថា « សត្ថាទេវមនុស្សានំ » ?

វិ. បានជាទ្រង់ព្រះនាមថា « សត្ថាទេវមនុស្សានំ » ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ។

បុ. ចុះព្រះអង្គប្រដៅអ្វីខ្លះដល់ទេវតា និងមនុស្សទាំងឡាយ ?

វិ. ព្រះអង្គទ្រង់ប្រៀនប្រដៅប្រយោជន៍ ៣ យ៉ាង គឺ :

- *ទិដ្ឋធម្មិកត្ថ:* ប្រយោជន៍ក្នុងបច្ចុប្បន្ន ១
- *សម្បរាយិកត្ថ:* ប្រយោជន៍ក្នុងបរលោក ១
- *បរមត្ថ:* ប្រយោជន៍ក្នុងព្រះនិព្វាន ១ ។

បុ. ប្រយោជន៍ក្នុងបច្ចុប្បន្ន មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. មាន ៤ យ៉ាង គឺ :

- *ឧដ្ឋានសម្បទា* ដល់ព្រមដោយការខ្នះខ្នែងប្រឹងប្រែងចាត់ការងារដែលខ្លួនត្រូវប្រកបនោះ១ ដែលជាការប្រាសចាកទោស មានកសិកម្ម ជាដើម ១ ,
- *អារក្ខសម្បទា* ដល់ព្រមដោយការថែទាំរក្សាទ្រព្យដែលរកបានមក មិនឱ្យវិនាសទៅដោយហេតុផ្សេង១ មានភ្លើងឆេះ ចោរលួច និងលេងល្បែងភ្នាល់ជាដើម,
- *កល្យាណមិត្តតា* សេពគប់មិត្រល្អ គឺមិត្រដែលមានសទ្ធា មានសីល មានចាគ: មានបញ្ញាដ៏ល្អ,
- *សមជីវិតា* ចិញ្ចឹមជីវិតដ៏ស្មើ គឺរកទ្រព្យបានមកហើយ ចាយវាយតាម

កម្លាំងដែលរកបាន មិនឱ្យខ្ជះខ្ជាយហួសប្រមាណ លៃឱ្យស្មើដូចគេថ្នឹងនឹងជញ្ជីង ។

ទាំង ៤ នេះឈ្មោះថា ប្រយោជន៍ក្នុងបច្ចុប្បន្ន ។

ប្អូ. ចុះប្រយោជន៍ក្នុងបរលោក មានប៉ុន្មានយ៉ាង ? **គឺអ្វីខ្លះ ?**

ឆ្លើយ. មាន ៤ យ៉ាង គឺ :

- *សទ្ធាសម្បទា* ដល់ព្រមដោយសេចក្តីជឿគុណព្រះរតនត្រ័យ ជឿកម្ម ជឿផល,
- *សីលសម្បទា* ដល់ព្រមដោយសីល មានសីល ៥ ជាដើម,
- *ចាគសម្បទា* ដល់ព្រមដោយការលះបង់បច្ច័យ ៤ មានចីវរបច្ច័យ ជាដើម ដល់សមណៈ និងព្រាហ្មណ៍,
- *បញ្ញាសម្បទា* ដល់ព្រមដោយបញ្ញា គឺការចេះដឹង ។

ប្រយោជន៍ទាំង ៤ យ៉ាងនេះ បើបុគ្គលណាបានធ្វើហើយ ឈ្មោះថាបានជម្រះផ្លូវទៅកាន់លោកខាងមុខជានិច្ច លុះរំលាងខន្ធពីនេះទៅ នឹងបានដើរទៅដោយស្រួល មិនលំបាក ដូចមនុស្សដែលដើរតាមថ្នល់ដ៏ស្អាត រមែងមិនលំបាក ។

ប្អូ. ចុះព្រះអង្គទ្រង់ប្រៀនប្រដៅបរមត្ថប្រយោជន៍ដោយធម៌ណា ?

ឆ្លើយ. ព្រះអង្គទ្រង់ប្រៀនប្រដៅដោយសច្ចធម៌ ៤ គឺ :

- ប្រដៅឱ្យឃើញកងទុក្ខទាំង ១២ មានជាតិទុក្ខជាដើម,
- ប្រដៅឱ្យឃើញហេតុដែលនាំឱ្យកើតទុក្ខ គឺតណ្ហាទាំង ៣ ឬទាំង ១០៨,
- ប្រដៅឱ្យឃើញទីរលត់ទុក្ខ គឺព្រះនិព្វាន,
- ប្រដៅឱ្យឃើញផ្លូវទៅកាន់ទីរលត់ទុក្ខ គឺអដ្ឋង្គិកមគ្គ ។

ព្រះអង្គទ្រង់ប្រៀនប្រដៅតាមឧបនិស្ស័យ បើសត្វណាមានឧបនិស្ស័យតិច មានកិលេសក្រាស់ ព្រះអង្គទ្រង់ប្រៀនប្រដៅដោយប្រយោជន៍ជាបច្ចុប្បន្ន និង

ប្រយោជន៍ក្នុងបរលោក សត្វណាមានឧបនិស្ស័យចាស់ក្លា ព្រះអង្គទ្រង់ប្រៀន ប្រដៅដោយបរមត្ថប្រយោជន៍ ទើបព្រះអង្គបានទ្រង់ព្រះនាមថា « សត្ថាទេវ-មនុស្សានំ » ។

ន័យមួយទៀតថា ព្រះវិជិតមារបានជាទ្រង់ព្រះនាមថា « សត្ថា » ព្រោះ ព្រះអង្គជាគ្រូញ្ជាំងសត្វឱ្យឆ្លងចាកកន្តារ ដូចជាបុរសអ្នកនាំផ្លូវពួកឈ្មួញ ។ សេចក្តីថា បុរសអ្នកនាំផ្លូវពួកឈ្មួញ តែងញ្ជាំងពួកឈ្មួញឱ្យឆ្លងចាកផ្លូវឆ្ងាយដាច់ស្រយាល ជាផ្លូវប្រកបដោយសេចក្តីអន្តរាយ ដែលហៅថា « កន្តារ » មាន ៥ គឺ :

- ចោរកន្តារ ផ្លូវឆ្ងាយដែលមានចោរ ១,
- ពាលកន្តារ ផ្លូវឆ្ងាយដែលមានសត្វសាហាវ ១,
- និរុទកកន្តារ ផ្លូវឆ្ងាយដែលដាច់ទឹក ១,
- អមនុស្សកន្តារ ផ្លូវឆ្ងាយដែលមានអមនុស្សចាំប្រៀតប្រៀន ១,
- អប្បភក្ខកន្តារ ផ្លូវឆ្ងាយដែលគ្មានភោជនាហារ ១

ឱ្យទៅដល់ខេមន្តភូមិ គឺទីដ៏ក្សេមក្សាន្តបានយ៉ាងណា, ឯសម្តេចព្រះសម្ពុទ្ធជាម្ចាស់ក៏ដូច្នោះដែរ ទ្រង់តែងចម្លងសត្វឱ្យផុតអំពីផ្លូវកន្តារ ១៣ ប្រការ ដែលប្រកបដោយអន្តរាយផ្សេង១គឺ : ជាតិកន្តារ ១, ជរាកន្តារ ១, ព្យាធិកន្តារ ១, មរណកន្តារ ១ ទុក្ខទុក្ខ ១, សោកៈ ១, បរិទេវៈ ១, ទោមនស្សៈ ១, ឧបាយាសៈ ១, ទិដ្ឋិ ១, ឧទ្ធច្ចៈ ១, វិចិកិច្ឆា ១, សីលព្វត្តបរាមាសៈ ១ ។ ផ្លូវកន្តារទាំង ១៣ ប្រការនេះ ព្រះសាស្តាស្តេចទ្រង់យកព្រះបារមីទាំង ៣០ មកធ្វើជាសំពៅ ធ្វើជាហត្ថិយាន រថយាន ជិះឆ្លងសមុទ្ទកន្តារ គឺវដ្តសង្សារ ចំពោះព្រះអង្គឯងរួចហើយ ទើបស្តេចចម្លងសត្វទាំងពួងឱ្យឆ្លងចាកជាតិកន្តារ ជរាកន្តារ ព្យាធិកន្តារ មរណកន្តារ ជាដើម តាមព្រះអង្គផង ។

បុ. សត្វបែបណាដែលព្រះអង្គចម្លងឱ្យផុតចាកជាតិកន្តារ លែងកាន់យក

ន្ធវបដិសន្ធិក្នុងផ្ទៃមាតា តទៅទៀត ?

វិ. *យេ តេ កប្បសតសហស្សា ធម្មំ សុត្វា បញ្ញាយ បស្សន្តិ* សត្វទាំងឡាយឯណាបានបំពេញបារមីអស់ ១ សែនកប្ប ហើយបានស្តាប់ធមិទេសនា ក្នុងសំណាក់ព្រះសាស្តា ញ្ញុាំងបញ្ញាឱ្យយាងចុះ តាមន័យដែលព្រះអង្គទ្រង់សំដែងនោះ ឃើញច្បាស់ន្ធវអរិយសច្ចទាំង ៤ ប្រការ កាត់លះកិលេស និងតណ្ហាអស់ពីខន្ធសន្តានដោយអរហត្តមគ្គញ្ញាណ ជាសមុច្ឆេទប្បហាន សត្វបែបនេះបានឆ្លងចាកជាតិកន្តារ មិនកាន់យកន្ធវបដិសន្ធិក្នុងគភិមាតាតទៅទៀតទេ ដូចបញ្ចវគ្គិយភិក្ខុ និងយសកុល-បុត្រ និងសំឡាញ់យសកុលបុត្រ ជាដើម ។

បុ. បើសត្វឆ្លងរួចចាកជាតិកន្តារហើយ ឈ្មោះថាឆ្លងរួចចាកជរា ពីព្រោះព្រះអរិយបុគ្គលដែលឆ្លងចាកជាតិកន្តារហើយ រមែងមិនកើតទៀតទេ និងមិនមានជរា ព្យាធិ មរណកន្តារ ក្នុងអនាគត ដ្បិតថា ធមិ ៣ ប្រការ គឺ ជរា ព្យាធិ មរណៈ នេះ តែងកើតឡើងអាស្រ័យជាតិ កាលបើជាតិមិនមានក្នុងពេលណា ជរា ព្យាធិ មរណៈ ក៏មិនមានក្នុងពេលនោះ ព្រោះហេតុនោះ ជាតិកើតឡើងហើយ ជាបច្ច័យដល់ជរា, ជរាជាបច្ច័យដល់ព្យាធិ, ព្យាធិជាបច្ច័យដល់មរណៈ និងសោកៈ ទុក្ខទោមនស្ស ឧបាយាសៈ នោះផង បើជាតិមិនមាន ធមិទាំងឡាយមានជរាជាដើម មានឧបាយាសៈជាទីបំផុត និងធមិទាំងឡាយដទៃក្រៅពីនេះ គឺចិត្ត និងចេតសិក និងរូប ក៏មិនមានទាំងអស់ បើធមិទាំងអស់មិនមានយ៉ាងនេះហើយ ព្រះអរិយបុគ្គលអង្គនោះ ឈ្មោះថាបានឆ្លងផុតចាកកន្តារទាំង ១៣ ។ ព្រះសក្យមុនីស្តេចចម្លងសត្វទាំងឡាយឱ្យឆ្លងផុតអំពីកន្តារ គឺភពវដ្តសង្សារ នាំទៅដាក់ដល់ត្រើយ គឺព្រះនិព្វានយ៉ាងនេះបានជាទ្រង់ព្រះនាមថា « សត្ថា » ប្រែថា « ជាគ្រូញ្ញុាំងសត្វឱ្យឆ្លងចាកផ្លូវឆ្ងាយ » ។

ក៏ពាក្យថា « ទេវមនុស្សានំ ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ » នោះ លោកពោលដោយឧក្រិដ្ឋ សំដៅតែភព្វបុគ្គល គឺបុគ្គលដែលគួរទទួលមគ្គផលបានក្នុងបច្ចុប្បន្នជាតិ តែដែលពិតនោះ ព្រះអង្គមិនប្រៀនប្រដៅចំពោះតែទេវតា និងមនុស្សប៉ុណ្ណោះទេ ព្រះអង្គប្រៀនប្រដៅទាំងសត្វតិរច្ឆាន ដោយអនុសាសនីទេសនាផងដែរ ។ តិរច្ឆានទាំងនោះដែលបានស្តាប់ធម៌ព្រះអង្គហើយ នឹងបានជាឧបនិស្ស័យសម្បត្តិដល់ជាតិជាអនាគតក្នុងអត្តភាពទី២ ទី៣ ទើបបានសម្រេចមគ្គផល ត្អូយ៉ាងដូចមណ្ឌុកទេវបុត្រ[1] ជាដើម ។

ដំណាលសេចក្តីថា កាលព្រះសម្ពុទ្ធប្រោសប្រទានព្រះធម៌ទេសនាដល់បរិស័ទនៅទ្បៀបក្រុងចម្ប៉ា តែ្បរមាត់ស្រះបោក្ខរណី ឈ្មោះគគ្គរា ។ គ្រានោះ មានសត្វកង្កែប ១ សំងំស្តាប់ស័ព្ទធម៌ទេសនារបស់ព្រះអង្គ មានគង្វាលគោម្នាក់ដើរមកឈរច្រត់ដំបងសង្កត់ពីលើក្បាលកង្កែប ។ កង្កែបក៏ធ្វើមរណកាលទៅកើតក្នុងភពតាវតឹង្ស នៅក្នុងវិមានមាសកំពស់ ១២ យោជន៍ ហាក់ដូចជាភ្ញាក់ពីដេក ស្រាប់តែឃើញស្រីទេពអប្សរចោមរោមជាបរិវារនៅស្ថាននោះ ទេវបុត្រនឹកពិភាល់ក្នុងចិត្តគិតថា យីអើហ្ន៎ គួរឱ្យឆ្ងល់ពន់ពេក ហេតុអ្វីអេះ អញលោបានមកកើតក្នុងទីនេះ រំពឹងគិតសព្វ១ទៅ មិនឃើញបុញ្ញ កម្មអ្វីដទៃ ក្រៅពីកិរិយាកាន់យកនូវនិមិត្តក្នុងសំឡេងធម៌ទេសនាព្រះសម្ពុទ្ធសោះ ទើបហោះមកតាមអាកាសវេហាស៍នភាល័យ ព្រមទាំងវិមានមកក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ។ គ្រានោះ ព្រះអង្គទ្រង់មានព្រះពុទ្ធតម្រាស់សួរថា :

កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ
អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។

---

(១) ទេវបុត្តនេះ កាលពីមុនជាសត្វកង្កែប

អ្នកណាហ្នឹ មានឫទ្ធិ មានយសរុងរឿង មានរស្មីចែងចាំង
ញ្ជាំងទិសទាំងពួងឱ្យភ្លឺស្វាងមកសំពះបាទានៃតថាគត ?
ទេវបុត្រក្រាបទូលស្នងព្រះពុទ្ធដីកាថា :

មណ្ឌូកោហំ ឫរេ អាសឺ ឧទកេ វារិគោចរោ
តវ ធម្មំ សុណន្តស្ស អវធិ វច្ឆបាលកោ ។

ខ្ញុំព្រះអង្ត កាលពីដើមឡើយជាសត្វកង្កែបនៅអាស្រ័យក្នុងទឹក មានវារីជាទីគោចរ កាលកំពុងស្តាប់ធមិព្រះអង្ត អ្នកគង្វាលគោគេសម្លាប់ខ្ញុំព្រះអង្ត ។

ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ប្រោសប្រទានព្រះសទ្ធម្មវិសេសទេសនា សត្វទាំងឡាយ ៨ ម៉ឺន ៤ ពាន់ បានលុះធម្មាភិសម័យ ។ ឯទេវបុត្រនោះបានលុះសោតាបត្តិផល មានចិត្តរីករាយ ហើយហោះចាកទីនោះទៅកាន់លោកនាយវិញ ។ ព្រះសម្ពុទ្ធដែលទ្រង់ព្រះនាមថា « សត្ថាទេវមនុស្សានំ » ព្រោះព្រះអង្តជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ហើយនិងសត្វដទៃ ដូចសេចក្តីដែលពណិនាមកនេះឯង ។

ចប់បទ « សត្ថាទេវមនុស្សានំ » ដោយសង្ខេប

កែបទ « ពុទ្ធោ »

បុ. ព្រោះហេតុអ្វីបានជាព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា « ពុទ្ធោ » ?

វិ. បានជាទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គជាអ្នកភ្ញាក់រឲក, ជាបុគ្គលរីក ជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ្ជាំងអ្នកដទៃឱ្យត្រាស់ដឹងផង ។

បុ. ពាក្យថា « ព្រះអង្គជាបុគ្គលភ្ញាក់រឲក » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះបរមសាស្តាព្រះអង្គភ្ញាក់អំពីកិរិយាដេកលក់ក្នុងអនុស័យ ៧ គឺ *កាមរាគានុស័យ* ដេកលក់ក្នុងសេចក្តីត្រេកត្រអាលទៅរកបញ្ចកាម-គុណ ១ *ភវរាគានុស័យ* ដេកលក់ក្នុសេចក្តីត្រេកត្រអាលក្នុងភព ១ *បដិឃានុស័យ* ដេកលក់ក្នុងបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ ១ *មានានុស័យ* ដេកលក់ក្នុងទិដ្ឋិ (សេចក្តីប្រកាន់) ១ *ទិដ្ឋានុស័យ* ដេកលក់ក្នុងទិដ្ឋិ (គំនិតយល់ខុស) មានប្រភេទ ៦២ យ៉ាង ១ *វិចិកិច្ឆានុស័យ* ដេកលក់ក្នុងវិចិកិច្ឆា គឺសេចក្តីសង្ស័យស្ទាក់ស្ទើរមិនចេះអស់មិនចេះហើយ ១ *អវិជ្ជានុស័យ* ដេកលក់ក្នុងអវិជ្ជា គឺសេចក្តីល្ងង់ទាំង ៨ ប្រការដែលបិទបាំងបញ្ញាមិនឱ្យឃើញអរិយសច្ច ១ រួមគ្នាត្រូវជាអនុសយធម៌ ៧ ប្រការ ។

ព្រះសាស្តាស្តេចទ្រង់តើនឡើងចាកធម៌ ៧ ប្រការនេះ ដឹងខ្លួនច្បាស់លាស់ ទ្រង់យាងដាស់សត្តនិករទាំងឡាយដែលកំពុងដេកត្រាំ ឬកំពុងដេកលក់សិប់ក្នុងអនុស័យឱ្យភ្ញាក់ ឱ្យដឹងខ្លួន ដូចព្រះអង្គផង ។ សត្វណាដែលដេករវៀសរវៃ មាននិស្ស័យក្រាស់ ក៏ភ្ញាក់ឡើងដឹងខ្លួន សត្វណាមាននិស្ស័យស្តើង និងមិនមាននិស្ស័យគ្រាន់តែប្រែប្រួលខ្លះ សំងំដេកនៅខ្លះ ព្រះអង្គបានយាងដាស់សត្វតាំងតែអំពីពេលបានត្រាស់រហូតទៅទល់នឹងចូលព្រះនិព្វានអស់ ៤៥ វស្សា ឥតមានទំនេរពេលណាឡើយ ព្រោះទ្រង់ឃើញទោសក្នុងកិរិយាដេកលក់ ឃើញសេចក្តីសុខក្នុងព្រះនិព្វាន

បានជាទ្រង់ខ្វល់ខ្វាយដាស់សត្វ ព្រោះទ្រង់ភ្ញាក់មុនគេ ។ ពិតមែន ព្រះសាស្តាជាម្ចាស់ កាលដែលទ្រង់ភ្ញាក់ឡើងឥតមាននរណាមួយដាស់ព្រះអង្គឡើយ គឺបារមីទាំង ៣០ ដែលព្រះអង្គកសាងអស់ ៤ អសង្ខេយ្យ កប្បមួយសែនមហាកប្ប គ្រប់កំណត់ហើយ ដាស់ព្រះអង្គឱ្យភ្ញាក់រឭក ប្រៀបដូចមនុស្សដែលដេកលក់ ដល់ពេលម៉ោងហើយ រមែងរវៃសរវែក្រោកឡើងធ្វើការងារ មិនចាំបាច់អ្នកណាតឿនឡើយ ។ ព្រះដ៏មានបុណ្យជាម្ចាស់ ទ្រង់ភ្ញាក់ឡើងហើយយ៉ាងដាស់សត្វឯទៀត ដូចផ្លែងមកនេះ ទើបទ្រង់ព្រះនាមថា « ពុទ្ធោ » ប្រែថា « ព្រះអង្គជាបុគ្គលភ្ញាក់រឭក » ។

ប្ុ. ពាក្យថា « ព្រះអង្គជាបុគ្គលរីក » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គរីកចេញអំពីអវិជ្ជា គឺសេចក្តីល្ងង់ ។ កាលសត្វទាំងឡាយកំពុងអន្ទោលទៅក្នុងវដ្តសង្សារ មិនមាន់បានត្រាស់ដឹងនៅឡើយ អវិជ្ជារមែងរឹតរុំហ៊ឺជិតមិនឱ្យមានពន្លឺ គឺបញ្ញារីកសាយឡើងបាន និងមិនឱ្យឃើញនូវធម៌ពិតឡើយ ដូចជាកូនមាន់មិនទាន់ញាស់ សំបកពងនៅកំពុងរុំស្រោប រមែងមិនឃើញពន្លឺព្រះអាទិត្យ លុះតែកូនមាន់នោះខំប្រឹងយកចំពុះ និងចុងក្រចកចឹកកកាយចម្លុះសំបកពងនោះចេញរួចមក ទើបឃើញពន្លឺព្រះអាទិត្យ ។ ព្រះសម្មាសម្ពុទ្ធសោត ក៏ព្រះអង្គមានព្រះបញ្ញាញាណឆ្លុះរំពោងព្រាយ ព្រោះទ្រង់ចម្លាយនូវសំបកពង គឺអវិជ្ជាបាន ទ្រង់មានព្រះទ័យស្អាតផូរផង់ ឥតមានគ្រឿងរឹតរុំហ៊ុំស្រោប គឺអវិជ្ជាឡើយ ហើយព្រះអង្គខំបំពេញពុទ្ធកិច្ចទាំងអស់ ដរាបដល់ចូលព្រះនិព្វាន ដោយប្រការដូច្នេះ ទើបទ្រង់ព្រះនាមថា « ពុទ្ធោ » ប្រែថា « ព្រះអង្គជាបុគ្គលរីក » ។

បុ. ពាក្យថា « ព្រះអង្គជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ចនោះ » តើអធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវអរិយសច្ចទាំង ៤ ប្រការ គឺ :

- ទុក្ខសច្ច ទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើម ១
- សមុទយសច្ច ហេតុដែលនាំឱ្យកើតទុក្ខ គឺតណ្ហាទាំង ៣ ប្រការ មានកាមតណ្ហា ជាដើម ១
- និរោធសច្ច សេចក្តីរលត់កងទុក្ខ ១
- មគ្គសច្ច អរិយមគ្គទាំង ៨ ជាឧបាយសម្លាប់នូវសេចក្តីទុក្ខ ១ ។

បណ្តាសច្ចៈទាំង ៤ នោះ ក្នុងសច្ចៈមួយ១ មានអត្ថបួន១ ដូច្នេះ គឺ :

• ទុក្ខសច្ច មានអត្ថ ៤ គឺ *បិឡនត្ថោ* មានអត្ថថាបៀតបៀននូវសត្វ ១ *សង្ខតត្ថោ* មានអត្ថថាជាធម៌ គឺបច្ច័យទាំងឡាយមានតណ្ហាជាដើម ប្រជុំគ្នាតាក់តែងឱ្យកើត ១ *សន្តាបត្ថោ* មានអត្ថថាញ៉ាំងសត្វឱ្យក្តៅក្រហាយអន្ទះអន្ទែង ១ *វិបរិណាមត្ថោ* មានអត្ថថាចេះតែប្រែប្រួល មិនឋិតថេរ ១ ។

• សមុទយសច្ច មានអត្ថ ៤ ដ៏ *អាយូហនត្ថោ* មានអត្ថថាប្រមូលគ្បែរគរសេចក្តីទុក្ខឱ្យកើត ១ *និទានត្ថោ* មានអត្ថថានាំមកសេចក្តីទុក្ខមកប្រគល់ឱ្យជាផលរបស់ខ្លួន ១ *សំយោគត្ថោ* មានអត្ថថាប្រកបចាក់ចងសត្វដោយសេចក្តីទុក្ខ ១ *បលិពោធត្ថោ* មានអត្ថថាធ្វើឱ្យសត្វរវល់រំខានចិត្តស្ទាក់ដំណើរមិនឱ្យបានមគ្គផល ១

• និរោធសច្ច មានអត្ថ ៤ គឺ *និស្សរណត្ថោ* មានអត្ថថារលាស់ចោលនូវឧបធិធម៌ដែលសម្រាប់ឱ្យសេចក្តីទុក្ខចូលទៅរែបនៃបនៅ ហើយដោះខ្លួនចេញពីភព ១ *វិវេកត្ថោ* មានអត្ថថាស្ងប់មិនមានសង្ខារធម៌ទាំងពួង ១ *អសង្ខតត្ថោ* មានអត្ថ

ថាលែងមានធម៌ជាបច្ច័ប្រជុំតាក់តែងឱ្យកើត ១ *អមតត្តោ* មានអត្តថាជាធម្មជាតិមិនចេះស្លាប់ ព្រោះជារបស់ទៀង ១ ។

• មគ្គសច្ច មានអត្ថ ៤ គឺ *និយានត្តោ* មានអត្តថាដឹកជញ្ជូនសត្វចេះដួសសង្សារ ១ *ហេតុត្តោ* មានអត្តថាជាហេតុញុំងសត្វឱ្យដល់ព្រះនិព្វាន ១ *ទស្សន* មានអត្តថាឃើញនូវព្រះនិព្វានដែលជាធម៌ល្អិតសុខុមក្រៃលែង ១ *អធិបតេយ្យ* មានអត្តថាជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន ១ ។

ក្នុងសច្ចៈទាំង ៤ នោះ មានលក្ខណៈ ២ យ៉ាង គឺ *សង្ខតលក្ខណៈ ១ អសង្ខតលក្ខណៈ ១* ។

សង្ខតលក្ខណៈ ចែកចេញជា ៣ យ៉ាង គឺ *ឧប្បាទោ* កិរិយាកើតឡើង ១ *វយោ* កិរិយាសោះសូន្យទៅ ១ *ឋិតិ* កិរិយាតាំងនៅ ១ ។

អសង្ខតលក្ខណៈ ក៏ចែកចេញជា ៣ យ៉ាងដែរ គឺ *អនុប្បាទា* កិរិយាមិនកើតឡើង ១ *នវយោ* សេចក្តីមិនសាបសូន្យទៅ ១ *នឋិតិ* ការមិនតាំងនៅ ១ ។

បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសច្ចៈ សមុយសច្ចៈ និងមគ្គសច្ចៈ ទាំង ៣ នេះរាប់ចូលក្នុងសង្ខតលក្ខណៈ, និរោធសច្ចៈ រាប់ចូលក្នុងអសង្ខតលក្ខណៈ ។

សច្ចៈទាំង ៤ នេះ បើចែកដោយកុសល អកុសល និងអព្យាកតៈវិញ សមុទយសច្ចៈជាអកុសលសុទ្ធ មគ្គសច្ចៈជាកុសល និរោធសច្ចៈជាអព្យាកតៈ ទុក្ខសច្ចៈជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតៈខ្លះ ។

ទុក្ខសច្ចៈដែលជាកុសល ជាគូគ្នានឹងមគ្គសច្ចៈជាកុសល, អធិប្បាយថា កាលបុរសបុគ្គលខំប្រឹងប្រែងរៀនសូត្រ និងចំរើនសមថកម្មដ្ឋាន ឬប្រព្រឹត្តធុតង្គ ១៣ ឬក៏ធ្វើកុសលផ្សេង១ បានសេចក្តីលំបាកនឿយហត់ យ៉ាងនេះឈ្មោះថាទុក្ខ ប៉ុន្តែ អំពើនោះជាកុសល ទើបឈ្មោះថាទុក្ខសច្ចៈជាកុសល ។

ទុក្ខសច្ចជាអកុសល ជាគូគ្នានឹងសមុទយសច្ចជាអកុសល, អធិប្បាយថា កាលដែលបុរសបុគ្គលប្រព្រឹត្តធ្វើបាបកម្ម មានបាណាតិបាតជាដើម លំបាកដោយត្រូវភ្លៀងត្រូវភ្លៅ និងភ័យដោយគេចាប់គេចង ព្រោះធ្វើចោរកម្មជាដើម យ៉ាងនេះឈ្មោះថាទុក្ខ ថែមទាំងអំពើនោះជាអកុសល ទើបឈ្មោះថាទុក្ខសច្ចជាអកុសល ។

ទុក្ខសច្ចជាអព្យាកតៈ ជាគូគ្នានឹងនិរោធសច្ចជាអព្យាកតៈ អធិប្បាយថា លោកដែលបានសម្រេចព្រះអរហត្តមានព្រះពុទ្ធជាដើម តែងខំប្រឹងប្រតិបត្តិវត្តតឹងតែង និងសំដែងធម៌ប្រោសសត្វលំបាកនឿយហត់ តែឥតបានផលឡើយ យ៉ាងនេះបានជាឈ្មោះថាទុក្ខសច្ចជាអព្យាកតៈ ។

ក៏សច្ចៈទាំង ៤ ប្រការនេះ បើពិចារណាដោយអំណាចខន្ធ ៥ មានរូបជាដើម ត្រូវពិចារណាបំបែកមួយខន្ធម្តង១ ឱ្យបានជាសច្ចៈ ៤ ១ ដូច្នេះថា សេចក្តីទុក្ខសោមនស្សឯណាដែលកើតឡើងដោយសាររូប ហៅថាសេចក្តីត្រេកអរជ្រះថ្លារបស់រូប ចាត់ជាសមុទយសច្ច ត្រាស់ដឹងបានដោយការលះបង់, រូបដែលមិនទៀងជាទុក្ខនឹងចេះតែប្រែប្រួលទៅ ហៅថាទោសរបស់រូបកើតឡើងដោយសាររូប ចាត់ជាទុក្ខសច្ច ត្រាស់ដឹងបានដោយការកំណត់, ការលះបង់បានន័យសេចក្តីប្រាថ្នាក្នុងរូប ហៅថារលាស់ចោលនូវរូប ចាត់ជានិរោធសច្ច ត្រាស់ដឹងបានដោយកិរិយាធ្វើឱ្យជាក់ច្បាស់, អដ្ឋង្គិកមគ្គទាំង ៨ មានសម្មាទិដ្ឋិ សេចក្តីយល់ត្រូវក្នុងហេតុទាំង ៣ យ៉ាងនេះជាដើម ហៅថាមគ្គសច្ច ត្រាស់ដឹងបានដោយកិរិយាចំរើន ។ ឯវេទនា សញ្ញា សង្ខារ និងវិញ្ញាណ មានន័យដែលត្រូវចែកដូចគ្នានឹងរូបខាងដើមនេះដែរ ។ ក្នុងកងអរិយសច្ច បើពោលដោយធម៌ដែលកើត អាស្រ័យគ្នាដូច្នេះគឺ ជរា មរណៈ មានជាតិជាហេតុជាដែនកើត, ឥណ្ហា មានវេទនាជាហេតុជាដែនកើត, វេទនាមានផស្សៈជាហេតុជាដែនកើត, ផស្សៈមានសឡាយតនៈជាហេតុជាដែនកើត, សឡាយតនៈមាន

នាមរូបជាហេតុជាដែនកើត, នាមរូបមានវិញ្ញាណជាហេតុជាដែនកើត, វិញ្ញាណមាន
សង្ខារជាហេតុជាដែនកើត, សង្ខារមានអវិជ្ជាជាហេតុជាដែនកើត ។ ជរាចាត់ជា
ទុក្ខសច្ច, ជាតិចាត់ជាសមុទយសច្ច, ភាវៈរលាស់ផុតចាកជរា មរណៈ ព្រមទាំង
ចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច ; ជាតិចា
ទុក្ខសច្ច, ភពចាត់ជាសមុទយសច្ច, ភាវៈរលាស់ផុតចាកជាតិ និងភព ចាត់ជានិរោ
សច្ច, សេចក្តីដឹងច្បាស់ចាត់ជាមគ្គសច្ចៈ ឧបាទាន និងតណ្ហា ចាត់ជានិរោធសច្ច
សេចក្តីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច តណ្ហាចាត់ជាទុក្ខសច្ច, វេទនាចាត់ជា
សមុទយសច្ច, ភាវៈរលាស់ផុតចាកតណ្ហា និងវេទនា ចាត់ជានិរោធសច្ច សេចក្តីដឹង
ច្បាស់នូវនិរោធចាត់ជាមគ្គសច្ច ; វេទនាចាត់ជាទុក្ខសច្ច ផស្សៈចាត់ជាសមុទយសច្ច,
ភាវៈរលាស់ផុតចាកវេទនា និងផស្សៈចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវ
និរោធចាត់ជាមគ្គសច្ច ផស្សៈចាត់ជាទុក្ខសច្ច, សឡាយតនៈចាត់ជាសមុទយសច្ច,
ភាវៈរលាស់ផុតចាកផស្សៈ និងសឡាយតនៈ ចាត់ជានិរោធសច្ច សេចក្តីដឹងច្បាស់
នូវនិរោធចាត់ជាមគ្គសច្ច ; សឡាយតនៈចាត់ជាទុក្ខសច្ច, នាមរូបចាត់ជាសមុទយសច្ច
ភាវៈរលាស់ផុតចាកសឡាយតនៈ និងនាមរូប ចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់
នូវនិរោធចាត់ជាមគ្គសច្ច, នាមរូបចាត់ជាទុក្ខសច្ច, វិញ្ញាណចាត់ជាសមុទយសច្ច,
ភាវៈរលាស់ផុតចាកនាមរូប និងវិញ្ញាណចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវ
និរោធចាត់ជាមគ្គសច្ច ; វិញ្ញាណចាត់ជាទុក្ខសច្ច, សង្ខារចាត់ជាសមុទយសច្ច ភាវៈ
រលាស់ផុតចាកវិញ្ញាណ និងសង្ខារចាត់ជានិរោធសច្ច សេចក្តីដឹងច្បាស់នូវនិរោធ
ចាត់ជាមគ្គសច្ច សង្ខារចាត់ជាទុក្ខសច្ច អវិជ្ជាចាត់ជាសមុទយសច្ច ភាវៈរលាស់ផុត
ចាកសង្ខារ និងអវិជ្ជាចាត់ជានិរោធសច្ច សេចក្តីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច ។

ក៏ធម៌ទាំងឡាយមានអវិជ្ជាជាដើមនេះ ជាសភាវៈ, មិនមែនសត្វ មិនមែន
បុគ្គល មិនមែនខ្លួនប្រាណ មិនមែនគេ មិនមែនយើង ជាសភាវៈមួយ។ អាស្រ័យ

គ្នានឹងគ្នា ហើយកើតឡើង និងរលត់ស្ងន្យទៅជាធម្មតា កាលដែលកើតឡើងដំបូង គឺអវិជ្ជា ។ អវិជ្ជាមានហើយ ជាបច្ច័យឱ្យកើតសង្ខារ, សង្ខារមានហើយ ជាបច្ច័យឱ្យកើតវិញ្ញ ាណ, វិញ្ញ ាណមានហើយ ជាបច្ច័យឱ្យកើតនាមរូប,នាមរូបមានហើយ ជាបច្ច័យឱ្យកើតអាយតនៈ, អាយតនៈមានហើយ ជាបច្ច័យឱ្យកើតផស្សៈ, ផស្សៈ មានហើយ ជាបច្ច័យឱ្យកើតវេទនា, វេទនាមានហើយ ជាបច្ច័យឱ្យកើតតណ្ហា ។ តណ្ហាមានហើយ ជាបច្ច័យឱ្យកើតឧបាទាន, ឧបាទានមានហើយ ជាបច្ច័យឱ្យកើត កើតភព, ភពមានហើយ ជាបច្ច័យឱ្យកើតជាតិ, ជាតិមានហើយ ជាបច្ច័យឱ្យកើត ជរា ព្យាធិ មរណ សោកៈ បរិទេវៈ ទុក្ខទោមនស្សុបាយាសឡើង ដូចជាភ្លើងដុតឱ្យ ក្តៅរោលរាលឥតអាក់យ៉ាងនេះឯង ជាធមិអាស្រ័យគ្នានឹងគ្នាហើយកើតឡើង ញ្ចុំង សត្វឱ្យវិលវល់ក្នុងវដ្តសង្សារប្រព្រឹត្តទៅក្នុងអនាទិកាលរកដើមចុងគ្មាន ។ សេចក្តី ទុក្ខលំបាក ព្រោះតែជាតិ ជរា ជាដើមនេះ ឈ្មោះថាទុក្ខសច្ច ព្រះជាគ្រូទ្រង់កំណត់ដឹង ដោយបរិញ្ញាភិសម័យ, អវិជ្ជា និងតណ្ហា ដែលជាឫសគល់នៃសង្សារវដ្ត ឬជាក្បាល នៃវដ្តសង្សារជាហេតុឱ្យកើតកងទុក្ខ ឈ្មោះថាសមុទយសច្ច ព្រះអង្គលះបង់ដោយ បហានាភិសម័យ បើអវិជ្ជានិងតណ្ហារលត់អស់ហើយ ធមិដទៃ។ មានសង្ខារ វិញ្ញាណ នាមរូបជាដើម ដែលជាទុក្ខក៏រលត់ទៅផងដែរ សេចក្តីរលត់ទុក្ខនេះឯង ហៅថា និរោធសច្ច ព្រះអង្គធ្វើឱ្យច្បាស់ដោយសច្ឆិកិរិយាភិសម័យ, ដំណើរដែលធ្វើឱ្យ រលត់ទុក្ខ ឈ្មោះថាមគ្គសច្ច ព្រះអង្គធ្វើឱ្យមានឡើងដោយភាវនាភិសម័យ ។ ព្រះ សម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ក្នុងចតុរារិយសច្ចយ៉ាងនេះ ហើយញ្ចុំងសត្វដទៃឱ្យដឹង ផង ទើបទ្រង់ព្រះនាមថា « ពុទ្ធោ » ប្រែថា « ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ្ចុំងអ្នកដទៃឱ្យត្រាស់ដឹងផង » ។

សព្វទស្សាវិតា ពុទ្ធោ ម្យ៉ាងវិញទៀត ព្រះមហាករុណាទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គទ្រង់ឃើញភ័យទាំងពួងក្នុងអតីត អនាគត បច្ចុប្បន្ន ។

ខីណាសវសង្ខាតេន ពុទ្ធោ ទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គអស់អាសវៈទាំង ៣ គឺ *កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ* ។

និរុបកិលេសសង្ខាតេន ពុទ្ធោ ទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គប្រាសចាកកិលេស ១០ យ៉ាង គឺ *លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ថីនមិទ្ធៈ អហិរិកៈ អនោតប្បៈ* ។

ឯកាយ មគ្គំ គតោតិ ទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គទ្រង់ព្រះពុទ្ធដំណើរតាមផ្លូវដែលមួលតែ ១ ត្រង់ស្លុងទៅកាន់អមួតនិព្វាន គឺ មជ្ឈិមាបដិបទា ។

ឯកោ អនុត្តរសម្មាសម្ពោធិ អភិសម្ពុទ្ធោ ទ្រង់ព្រះនាមថា « ពុទ្ធោ » ព្រោះព្រះអង្គជាបុគ្គលឯក ត្រាស់ដឹងនូវទសពលញ្ញាណ និងសព្វញ្ញុតញ្ញាណ មិនមានទេវតា ឥន្ទ ព្រហ្ម ណាប្រសើរស្មើ ។ ព្រះដ៏មានជោគប្រកបដោយគុណទាំងឡាយដូចថ្លែងមកនេះឯង បានជាទ្រង់ព្រះនាមថា « ពុទ្ធោ » ។

ចប់បទ « ពុទ្ធោ » ដោយសង្ខេប

កែបទ « ភគវា »

បុ. ព្រះសម្ពុទ្ធបរមគ្រូ ហេតុអ្វីបានជាទ្រង់ព្រះនាមថា « ភគវា » ?

វិ. បានជាទ្រង់ព្រះនាមថា « ភគវា » ព្រោះព្រះអង្គមានព្រះភាគ, ព្រះអង្គជាអ្នកចែក, ព្រះអង្គមានជោគ, ព្រះអង្គជាអ្នកបំបាក់បង់, ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ ។

បុ. ដែលថា « ព្រះអង្គមានព្រះភាគ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់មាន « ភាគ » គឺចំណែកកុសលដ៏ឧត្តមថ្លៃថ្លា មានទាន សីល ជាដើម អាចញ្ជាំងលោកិយសុខ និងសោកុត្តរសុខកើតឡើងដោយប្រការទាំងពួង ព្រោះហេតុនោះបានជាទ្រង់ព្រះនាមថា « ភគវា » ប្រែថា « ព្រះអង្គមានព្រះភាគ » ។

បុ. ដែលថា « ព្រះអង្គជាអ្នកចែក » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់ចែកវំលែកនូវធមិទាំងឡាយជាផ្នែក៣ គឺធមិល្អចាត់ជាកុសល ធមិអាក្រក់ចាត់ជាអកុសល ធមិមិនល្អមិនអាក្រក់ចាត់ជាអព្យាកតៈ ជាដើម ហើយបែងជាចិត្ត ចេតសិក បំបែកជាភូមិ ៤ ជាដើម ហើយញ្ជែកធមិទាំងនោះជាខន្ធ ធាតុ អាយតនៈ ឥន្ទ្រីយ អរិយសច្ច បដិច្ចសមុប្បាទ ជាដើម ដូច្នេះ ទើបទ្រង់ព្រះនាមថា « ភគវា » ប្រែថា « អ្នកចែក » ។

បុ. ដែលថា « ព្រះអង្គមានជោគ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះពុទ្ធជាម្ចាស់ទ្រង់មានជោគ មានគ្រោះល្អ គ្រាកាលដែលទ្រង់ទើបបានត្រាស់ច្បាស់ជាព្រះអរហំសម្មាសម្ពុទ្ធជាដំបូង ទ្រង់ប្រកាសសាសនា ញ្ជាំងជនដទៃឱ្យលុះធមិវិសេស កើតបានជាព្រះសង្ឃកុះការ ហើយនិងអាចញ្ជាំងវេនេយ្យសត្វក្រៅពីនោះ ឱ្យមានសទ្ធាជ្រះថ្លា តាំងនៅក្នុងព្រះពុទ្ធសាសនា

បាន ។ ប្រការមួយទៀត កាលព្រះអង្គកំពុងប្រកាសសាសនានោះ ពួកជនទាំងឡាយ ដែលជាសត្រូវ មានតិរ្ថិយជាដើម តែងប៉ងប្រាថ្នាល្បងថ្វីដៃនឹងព្រះអង្គ ចង់បំបាក់ព្រះអង្គ តែព្រះអង្គមិនដែលថ្លោះធ្លោយ មិនដែលភ័យអន្តរាយអំពីសំណាក់ជនជាសត្រូវទាំងឡាយ មានតិរ្ថិយជាដើមនោះឡើយ មានតែព្រះអង្គឯងអាចធ្វើឱ្យជនទាំងនោះបាក់បបខ្លបខ្លាចវិញ ព្រោះហេតុនោះបានជាទ្រង់ព្រះនាមថា « ភគវា » ប្រែថា « ព្រះអង្គមានជោគ » ។

បុ. ដែលថា « ព្រះអង្គអ្នកបំបាក់បង់ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់កាច់កិនញាំញីកងកិលេសទាំងឡាយ មានលោភៈ ទោសៈ មោហៈ ជាដើម ឬថាកាច់កិនញាំញីនូវមារទាំង ៥ បានជាទ្រង់ព្រះនាមថា « ភគវា » ប្រែថា « ជាអ្នកកាច់បំបាក់ » ។

ឯមារទាំង ៥ នោះ គឺ :

- កិលេសមារ កិលេសទាំងពួងដែលប្រៀតប្រៀនសត្ត ១
- អភិសង្ខារមារ កុសលនិងអកុសលដែលប្រៀតប្រៀនសត្ត ១
- មច្ចុមារ សេចក្តីស្លាប់ដែលប្រៀតប្រៀនសត្ត ១
- ទេវបុត្តមារ ទេវបុត្តអ្នកប្រៀតប្រៀន ១
- ខន្ធមារ ១ មារគឺខន្ធទាំង ៥ ជាប់តាមចាំប្រៀតប្រៀនពួកសត្ត ១

កិលេសមារ បានដល់កិលេស ១៥០០ រាប់យកលោកិយចិត្ត ៨១ ថាជាមួយ យកចេតសិក ៥២ មកផ្សំជា ៥៣ យកនិប្ផន្នូរប ១៨ មកផ្សំជា ៧១ យកអាកាស ១ ជាតិ ១ ជរា ១ ភវង្គ ១ មកផ្សំជា ៧៥ ចាត់ជាកិលេសខាងក្នុង ៧៥ ខាងក្រៅ ៧៥ ផ្សំជាមួយគ្នាជាកិលេស ១៥០ ហើយកិលេស ១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនមិទ្ធៈ អហិរិកៈ អនោតប្បៈ និងឧទ្ធច្ចៈ មកគុណ

និងកិលេស ១៥០ ត្រូវជាកិលេស ១៥០០ ។ កិលេសទាំង ១០ យ៉ាងនេះហើយដែលតែងញ៉ាំងសត្វឱ្យបានសេចក្តីទុក្ខ ក្តៅក្រហាយក្នុងឥធលោក និងបរលោក រកល្អែគ្មាន បានជាឈ្មោះថា កិលេសមារ ។

ខន្ធមារនោះ បានដល់ឧបាទានក្ខន្ធទាំង ៥ គឺ *រូបូបាទានក្ខន្ធ ១ វេទនូ-បាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ និងវិញ្ញាណូបាទានក្ខន្ធ ១* ។ ឧបាទានក្ខន្ធទាំង ៥ នេះដូចជាចោរ ៥ នាក់ ជាប់តាមចាំបៀតបៀនពួកសត្វ ទើបឈ្មោះថា ខន្ធមារ ។

អភិសង្ខារមារនោះ បានដល់បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ គឺកុសលា-កុសលដែលតាក់តែងសត្វឱ្យល្អ ឱ្យអាក្រក់ កុសល និងអកុសល ទាំងនេះបានជាឈ្មោះថាមារ ពីព្រោះអកុសល ១២ គឺ លោភមូល ៨ ទោសមូល ២ មោហមូល ២ រមែងនាំសត្វឱ្យធ្វើកម្មផ្សេងៗ ឱ្យបានសេចក្តីលំបាកក្នុងឥធលោក និងបរលោក ។ ឯលោកិយកុសលទាំង ១៧ គឺ កាមាវចរកុសល ៨ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ រមែងល្បួងលួងលោមសត្វឱ្យនៅវិលវល់កើតស្លាប់ជានិច្ចតែក្នុងភូមិទាំង ៣ នេះ បានជាឈ្មោះថា **អភិសង្ខារមារ** ។

មច្ចុមារនោះ បានដល់មច្ចុរាជ គឺសេចក្តីស្លាប់ ហេតុតែសេចក្តីស្លាប់នោះតែងតែផ្តាច់ផ្តិលជីវិតសត្វទាំងពួងមិនឱ្យលឿនទៅមុខបាន បានជាហៅថា មច្ចុមារ ។

ទេវបុត្តមារនោះ បានដល់ស្តេចមារាធិរាជដែលជាអ្នកចងសត្វទុកដោយខ្សែទាំង ៣ គឺ រាគៈ ទោសៈ និងតណ្ហា ឱ្យបានសេចក្តីវិនាសដោយភ័យ ៥ ប្រការ គឺ រាជភ័យ ចោរភ័យ ឧទកភ័យ អប្បិយភ័យ ចាវកភ័យ ភ័យទាំងនេះតែងកើតឡើងព្រោះទេវបុត្តមារ ។ ព្រះមហាករុណាជាម្ចាស់ ព្រះអង្គញ៉ាំញីនូវមារទាំង ៥ នេះបានទើបបានទ្រង់ព្រះនាមថា « ភគវា » ។

ឬ. ដែលថា « ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ » អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះបរមសាស្តាព្រះអង្គធ្វើនូវភពទាំង ៣ ឱ្យផុតហើយ គឺព្រះអង្គបានត្រាច់រង្គាត់ទាល់តែចប់ផុតអស់ភពទាំង ៣ ហើយទ្រង់លែងវិលត្រឡប់ទៅរកភពទាំងនោះវិញទៀតហើយ ទ្រង់ខ្ចាក់ចោលនូវដំណើរដែលត្រូវដើរទៅក្នុងត្រៃភព គឺលែងកើតទៀតហើយ បានជាទ្រង់ព្រះនាមថា « ភគវា » ប្រែថា « ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ » ។

ព្រះសម្មាសម្ពុទ្ធប្រកបដោយគុណទាំងឡាយ ដូចសំដែងមកនេះ ទើបទ្រង់ព្រះនាមថា « ភគវា » ។

ចប់បទ « ភគវា » ដោយសង្ខេប

ព្រះនាមទាំង ១០ ចប់ដោយសង្ខេប

•••

អវសានកថា

បុ. ព្រះនាមរបស់ព្រះពុទ្ធជាម្ចាស់ទាំង ១០ រាប់តាំងអំពី អរហំ ដល់ ភគវា ជាមិបំផុត នរណាថ្វាយដល់ព្រះអង្គ ? ព្រះចៅសិរីសុទ្ធោទន និងព្រះនាងមហាមាយាទេវី ថ្វាយឬ ?

វិ. មិនមានបុគ្គលណាមួយថ្វាយដល់ព្រះអង្គទេ មិនមែនព្រះចៅសិរីសុទ្ធោទន និងព្រះនាងមហាមាយាទេវី ឬក្សត្រជាព្រះញាតិវង្សទាំងប៉ែតសិបពាន់ ឬក៏ទេវតាដ៏វិសេសណា មានសក្កសន្តុសិតជាដើមថ្វាយទេ ព្រះនាមទាំង ១០ នេះ ជានេមិត្តកនាម រមែងកើតប្រាកដឡើងដល់ព្រះពុទ្ធទាំងឡាយ ជាមួយនឹងកិរិយាបាន ព្រះសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ។

បុ. ចុះគុណ គឺព្រះនាមទាំងអម្បាលនេះ បើរាប់បញ្ចូលក្នុងគុណ ដ៏សង្ខេប ៣ ខាងដើម គឺបញ្ញាគុណ ១ វិសុទ្ធិគុណ ១ ករុណាគុណ ១ តើព្រះនាមណា រាប់ចូលក្នុងព្រះគុណណា ?

វិ. • សម្មាសម្ពុទ្ធោ, វិជ្ជាចរណសម្បន្នោ, លោកវិទូ ទាំង ៣ ព្រះនាមនេះ រាប់ចូលក្នុងបញ្ញាគុណ ។

• អរហំ, សុគតោ, អនុត្តរោ ទាំង ៣ ព្រះនាមនេះ រាប់ចូលក្នុងវិសុទ្ធិគុណ ។

• បុរិសទម្មសារថិ, សត្ថាទេវមនុស្សានំ, ពុទ្ធោ, ភគវា ទាំង ៤ ព្រះនាមនេះ រាប់ចូលក្នុងករុណាគុណ ។

ម្យ៉ាងទៀត គុណគឺព្រះនាម ១០ ចែកដោយសង្ខេបទៅទៀត មាន ២ យ៉ាងគឺ *អត្តហិតគុណ* គុណដែលជាប្រយោជន៍ចំពោះព្រះអង្គ ១ *បរហិតគុណ*

គុណជាប្រយោជ៍ចំពោះសត្វដទៃ ១ ;

• អរហំ, សម្មាសម្ពុទ្ធោ, វិជ្ជាចរណសម្បន្នោ, សុគតោ, លោកវិទូ ទាំង ៥ ព្រះនាមនេះជាអត្តហិតគុណ ។

• អនុត្តរោ, បុរិសទម្មសារថិ, សត្ថាទេវមនុស្សានំ ទាំង ៣ ព្រះនាមនេះជាបរហិតគុណ ។

• ឯព្រះនាមពីរគឺ ពុទ្ធោ និងភគវា នេះជាអត្តហិតគុណផង ជាបរហិតគុណផង ។

ពណ៌នាអំពីពុទ្ធរតនៈ ចប់ដោយសង្ខេប

ពណ៌នាអំពីធម្មរតនៈ

បន្ទាប់អំពីពុទ្ធរតនៈមក នឹងពណ៌នាក្នុងធម្មរតនៈ តទៅទៀត

ប្អូ. សភាវៈដូចម្តេច ហៅថា « ធម៌ » ?

ឯ. សភាវៈដែលពិតមែន ឬសភាវៈដែលត្រឹមត្រូវល្អ ហៅថា « ធម៌ » ក្នុងទីនេះ។ ធម៌នោះមានគុណត្រង់រក្សាសត្វ អ្នកប្រតិបត្តិតាមល្អ មិនឱ្យធ្លាក់ទៅក្នុងទីទាប ឱ្យផុតចាកសេចក្តីទុក្ខ ជាសភាវៈសម្រាប់បំភ្លឺសត្វដែលមានសេចក្តីល្ងង់ខ្លៅកំពុងងងឹតដោយមោហៈ ឱ្យភ្ញើស្វាងឡើងបាន ឱ្យស្គាល់គុណទោស ខុសត្រូវ និងផ្លូវប្រតិបត្តិជាដំណើរទៅកាន់ស្ថានសួគ៌ ស្ថានព្រះនិព្វានបាន ជាគ្រឿងបំភ្លឺសត្វឱ្យស្វែងរកសេចក្តីសុខយើញ ហេតុនោះបានជាលោកប្រៀបថា ព្រះធម៌ដូចជាប្រទីបសម្រាប់បំភ្លឺសត្វក្នុងលោក ឬដូចជាព្រះអាទិត្យសម្រាប់បន្ទោបង់នូវងងឹត កាលបើងងឹតខ្ចាត់ចេញហើយ សត្វលោករមែងយល់ផ្លូវល្អ ដែលសម្រាប់សញ្ជរទៅកាន់ស្ថានដ៏ក្សេម ព្រះធម៌មានគុណអាចយ៉ាងណា ឬស្រោចស្រង់សត្វឱ្យបានសេចក្តីសុខយ៉ាងនេះ។

កែបទ « ស្វាក្ខាតោ ភគវតា ធម្មោ »

បុ. ព្រះធមិមានគុណតែប៉ុណ្ណោះទេ ឬនៅមានទ្យៅតដែរ ?

វិ. នៅមានច្រើនតទៅទ្យៅត ដូចពណិនាតទៅនេះ :

បទនេះប្រែថា « ព្រះបរិយត្តិធមិ និងព្រះនពលោកុត្តរធមិ គឺព្រះដ៏ ព្រះភាគទ្រង់សំដែងទុកដ៏ពិរោះ ឬដោយប្រពៃ » ។

បុ. ធមិដូចម្តេច ហៅថា « បរិយត្តិធមិ » ? ធមិនោះពិរោះដូចម្តេ ទៅ ?

វិ. ធមិសម្រាប់ទន្ទេញស្វាធ្យាយ ហៅថា « បរិយត្តិធមិ » បានដល់ព្រះ ពុទ្ធវចនៈ ព្រះត្រៃបិដក ជាធមិគឺព្រះអង្គសំដែងដ៏ពិរោះដោយបទដើម បទកណ្តាល និងបទចុង ។

អធិប្បាយថា ព្រះភគវាជាម្ចាស់ ស្ងម្បីទ្រង់សំដែងតែគាថាមួយ ក៏គង់ មានពិរោះគ្រប់ទាំង ៣ បទគឺ បទដើម ពិរោះដោយបឋមបាទ, បទកណ្តាល ពិរោះ ដោយទុតិយបាទ និងតតិយបាទ, បទចុង ពិរោះដោយបច្ឆិមបាទ ។ បើទ្រង់សំដែង ស្ងត្រដែលមានអនុសន្ធិតែមួយ មានពិរោះបទដើមដោយនិទានរឿងរ៉ាវ, ពិរោះបទ ចុងដោយនិគមវចនៈ គឺព្រះពុទ្ធដីកាត្រាស់សំដែងផ្ទួនម្តងទ្យៅត, ពិរោះបទកណ្តាល ដោយពាក្យបរិយាយសេសសល់ពីនោះទាំងប៉ុន្មាន ។ បើសំដែងស្ងត្រដែលមានអនុ-សន្ធិផ្សេងគ្នា បទដើមពិរោះដោយនិទានរឿងរ៉ាវ និងឧប្បត្តិហេតុ, បទកណ្តាល ពិរោះដោយសមគ្ងរដល់វេនេយ្យសត្ង និងអត្ថដ៏ក្បោះក្បាយ មិនយ្ឍៀងយ្ឋាត ហើយ និងមានហេតុ មានឧទាហរណ៍, បទចុងពិរោះដោយមានពាក្យបន្ថែម ជាហេតុជម្រុល សត្ងអ្នកស្តាប់ឱ្យមានសទ្ធា ។ ប្រការមួយសោត សាសនធមិទាំងអស់ មានពិរោះបទ ដើមដោយសីល, ពិរោះបទកណ្តាលដោយសមថវិបស្សនា និងមគ្គផល, ពិរោះបទ

ចុងដោយព្រះនិព្វាន ។ ម្យ៉ាងទៀត សាសនធម៌ពិរោះបទដើមដោយសមាធិ, ពិរោះបទកណ្តាលដោយវិបស្សនា និងមគ្គទាំងឡាយ, ពិរោះបទចុងដោយផល និងព្រះនិព្វាន ។ ម្យ៉ាងទៀត សាសនធម៌នោះនាំមកនូវគុណដ៏ល្អដល់អ្នកស្តាប់ ព្រោះសង្កត់សង្កិននូវនីវរណធម៌បាន ទើបឈ្មោះថាពិរោះបទដើម នាំមកនូវគុណដ៏ល្អដល់អ្នកប្រតិបត្តិ ព្រោះបានសេចក្តីសុខដែលកើតឡើងអំពីសមថវិបស្សនា ទើបឈ្មោះថាពិរោះបទកណ្តាល នាំមកនូវគុណដ៏ល្អដល់អ្នកប្រតិបត្តិដែលបានសំរេចផលហើយ ព្រោះនាំមកនូវតាទិភាព ទើបឈ្មោះថាពិរោះបទចុង ។ ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដ៏ពិរោះដោយបទដើម បទកណ្តាល និងបទចុង ដូចសេចក្តីដែលពណ៌នាមកនេះ ។

ន័យមួយទៀត ព្រះបរិយត្តិធម៌ឈ្មោះថា គឺព្រះដ៏មានព្រះភាគទ្រង់សំដែងដោយប្រពៃ ពីព្រោះជាធម៌ប្រកាសនូវសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈដ៏បរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

អធិប្បាយថា សាសនោវាទ ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសាស្តា ឈ្មោះថា សាសនព្រហ្មចរិយៈ ។ **អង្គនៃមគ្គទាំង ៨ ឈ្មោះថា** មគ្គព្រហ្មចរិយៈ ។ ព្រហ្មចរិយៈទាំងពីរយ៉ាងនេះ បរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ បរិសុទ្ធរកចន្លោះឱកាសនឹងបំពេញថែមទៀតមិនបាន ដូចយ៉ាងសតិបដ្ឋាន ៤ ជាដើម គង់នៅជា ៤ ដដែល មិនមានអ្នកប្រាជ្ញណាពោលថាខ្វះ ហើយបញ្ចូលថែមឱ្យទៅជា ៥ បាន និងជាធម៌បរិសុទ្ធរកទោសគ្មាន ដូចជាអង្គមគ្គទាំង ៨ ដែលព្រះអង្គសំដែងរួចហើយ នៅជា ៨ ដូចដែល ឥតមានអ្នកប្រាជ្ញណាអាចពោលទោសតិះដៀលថាខុស មិនសម ត្រូវដកខ្លះចេញ ឬត្រូវបញ្ចូលថែមទៀតបានឡើយ ។ យ៉ាងនេះបានជាព្រះបរិយត្តិធម៌ គឺព្រះដ៏មានព្រះភាគសំដែងដោយប្រពៃ ។ ក៏ព្រះពុទ្ធវចនៈដែលព្រះដ៏មានព្រះភាគទ្រង់

សំដែងចុកដោយប្រពៃ ទាំងអស់នេះបើពោលដោយកិច្ចមានតែម្យ៉ាង ; ដោយធម៌និងវិន័យមាន ២ យ៉ាង ; ដោយវចនៈ និងបិដកមាន ៣ យ៉ាង ; ដោយនិកាយមាន ៥ យ៉ាង ; ដោយអង្គមាន ៩ យ៉ាង ; ដោយធម្មក្ខន្ធមានប្រាំបីម៉ឺនបួនពាន់ ។

ប្ . ពុទ្ធវចនៈដែលពោលដោយកិច្ចមានតែម្យ៉ាងនោះ តើដូចម្តេច ?

វិ. ដែលពោលដោយកិច្ចមានតែម្យ៉ាងនោះដូច្នេះថា ព្រះពុទ្ធជាម្ចាស់តាំងពីពេលដែលព្រះអង្គបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ មកទល់នឹងចូលកាន់អនុបាទិសេសនិព្វាន ក្នុងរវាង ៤៥ ព្រះវស្សា ព្រះអង្គតែងសំដែងធម៌ប្រោសទេវតា និងមនុស្ស និងនាគ យក្ស ជាដើម ឥតមានល្ហែ រួចពុទ្ធវចនៈទាំងអស់នោះរួមមកមានកិច្ច ឬរសតែម្យ៉ាងគឺ វិមុត្តិរស ព្រោះហេតុនោះបានជាថា ព្រះពុទ្ធវចនៈទាំងអស់មានត្រឹមតែម្យ៉ាង ។

ប្ . ចុះពុទ្ធវចនៈដែលមាន ២ គឺ ធម៌ និងវិន័យនោះ តើដូចម្តេច ?

វិ. ដែលមាន ២ នោះដូច្នេះថា ព្រះពុទ្ធដីការបស់ព្រះជាគ្រូទាំងអស់រាប់ចូលមកក្នុងពាក្យពីរម៉ាត់គឺ ធម៌ ១ វិន័យ ១ ។

ព្រះវិន័យបិដកទាំងមូលហៅថា វិន័យ ក្រៅពីនោះទាំងប៉ុន្មានហៅថា ធម៌ ព្រោះហេតុនោះបានជា ព្រះមហាកស្សបត្ថេរ ពេលដែលធ្វើបឋមសង្គាយនា លោកមានថេរវាចាថា « *យន្នូន មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយេយ្យាម* ម្នាលអាវុសោទាំងឡាយ បើដូច្នោះមានតែយើងនាំគ្នាផ្គាត់ផ្គង់រៀបរៀងធម៌ និងវិន័យឡើង » កាលដែលព្រះបរមគ្រូមានព្រះពុទ្ធដីកាផ្តាំនឹងអានន្ទ ក៏សំដៅតែពាក្យ ២ ម៉ាត់នោះដែរថា « *យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា* ម្នាលអានន្ទ, ធម៌ឯណាដែលតថាគតបានសំដែងហើយ វិន័យឯណាដែលតថាគតបានបញ្ញត្តហើយដល់អ្នកទាំងឡាយ ធម៌និងវិន័យនោះ ដល់

អំណើះឥតអំពីតថាគតទៅ នឹងជាគ្រូអ្នករាល់គ្នាហើយ » ព្រះពុទ្ធវចនៈមានបការពីរដូច្នេះឯង ។

ប្អូ. ពុទ្ធវចនៈដែលពោលដោយវចនៈមាន ៣ នោះ តើជាអ្វីខ្លះ ?

ឆ្លើ. ដែលពោលដោយវចនៈមាន ៣ នោះ គឺ :

- បឋមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលជាដំបូង ១
- មជ្ឈិមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលត្រង់កណ្តាល ១
- បច្ឆិមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលបង្គើយចុងក្រោយបំផុត ១ ។

បឋមពុទ្ធវចនៈនោះ ដូចជាព្រះពុទ្ធដីកាដែលព្រះអង្គបានត្រាស់ជាដំបូង ទ្រង់មានព្រះទ័យសោមនស្សបន្ទីន្ទ្រវនមានវាចាឡើងចំពោះតណ្ហាថា *អនេកជាតិសំសារំ ។ បេ ។ តណ្ហានំ ខយមជ្ឈគា* ។ ជាលីគ្រប់គ្រាន់ ព្រមទាំងសេចក្តីប្រែដូចមានក្នុងពុទ្ធគុណស្រាប់ (១) ។

បច្ឆិមពុទ្ធវចនៈ បានដល់ព្រះពុទ្ធដីកាផ្តែផ្តាំក្នុងពេលទៀបស្តេចនឹងចូលកាន់ព្រះនិព្វានថា *ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថ* « នែភិក្ខុទាំងឡាយអើយ ម្តងណោះ តថាគតផ្តាំអ្នករាល់គ្នា សង្ខារទាំងឡាយមានកិរិយាសាបស្ងួយទៅជាធម្មតា អ្នកទាំងឡាយរាល់គ្នា ចូរកុំប្រមាទ » ។

ឯមជ្ឈិមពុទ្ធវចនៈ បានដល់ពាក្យដែលព្រះអង្គទ្រង់ពោលក្នុងចន្លោះកណ្តាលបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈទាំងពីរនេះទាំងអស់ ។

ប្អូ. ព្រះពុទ្ធវចនៈដែលមានបការ ៣ ដោយអំណាចបិដកនោះ ដូចម្តេច ?

(១) មើលត្រង់ទំព័រលេខ ១៤ . ១៥ ។

វិ. • ព្រះពុទ្ធវចនៈទាំងអស់មានប្រភេទតែ ៣ គឺ វិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។ បាតិមោក្ខទាំង ២ គឺ ភិក្ខុបាតិមោក្ខ និងភិក្ខុនីបាតិ-មោក្ខ, វិភង្ត ទាំង ២ គឺ ភិក្ខុវិភង្ត និងភិក្ខុនីវិភង្ត, ខន្ធកៈទាំង ២២ មានមហាខន្ធក ជាដើម, បរិវារ ១៦ មានកត្ថបញ្ញត្តន្តិវារៈជាដើម ដែលព្រះថេរៈទាំងឡាយសមោ-រូបរូមក្នុងបឋមសង្គីតិ ហៅថា វិនយបិដក ។

• ព្រះពុទ្ធវចនៈ ដែលមាននៅក្នុងនិកាយទាំង ៥ គឺ *ទីឃនិកាយ* សង្ត្រោះដោយសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ១, *មជ្ឈិមនិកាយ* សង្ត្រោះដោយសូត្រ ២៥២ មានមូលបរិយាយសូត្រជាដើម ១, *សំយុត្តនិកាយ* សង្ត្រោះដោយសូត្រ ៧៧៦២ មានឱឃតរណសូត្រជាដើម ១, *អង្គុត្តរនិកាយ* សង្ត្រោះដោយសូត្រ ៩៥៥៧ មានចិត្តបរិយាទានសូត្រជាដើម ១, *ខុទ្ទកនិកាយ* មានប្រភេទ ១៥ មានខុទ្ទកបាឋ ជាដើម ១, ហៅថា សុត្តន្តបិដក ។

• ព្រះពុទ្ធវចនៈ ដែលមាននៅក្នុងគម្ពីរទាំង ៧ គឺ ធម្មសង្គណី, វិភង្ត, ធាតុកថា, បុគ្គលប្បញ្ញត្តិ, កថាវត្ថុ, យមកៈ និងបដ្ឋាន ហៅថា អភិធម្មបិដក ។

ក៏ពាក្យថា « វិនីយ » ប្រែថា « មានន័យផ្សេងៗ, មានន័យវិសេស » ឬថា « ច្បាប់សម្រាប់ទ្ធន្មាន » ។

អធិប្បាយថា ច្បាប់របស់ព្រះសម្ពុទ្ធតែមួយមែនពិត ប៉ុន្តែ មានប្រការផ្សេងៗ ដូចជាបាតិមោក្ខុទ្ទេស ៥ ប្រការផ្សេងពីគ្នា អាបត្តិទាំង ៧ កង ក៏ផ្សេងដោយឡែកពីនោះទៅទៀត គឺ បារាជិកមាន ៤ ប្រការផ្សេងដោយឡែកទៅ ; សង្ឃាទិ-សេសមាន ១៣ ប្រការផ្សេងដោយឡែកទៅ ; ផ្សេងៗពីគ្នាដោយបការដូច្នេះជាដើម ទើបឈ្មោះថាមានន័យផ្សេងៗ ។ ម្យ៉ាងទៀត វិនីយនេះមានន័យវិសេសឡើង ដូចយ៉ាងអនុប្បញ្ញត្តិមានក្នុងសិក្ខាបទនីមួយៗ មានប្រយោជន៍ធ្វើឱ្យតឹងឡើងខ្លះ ឱ្យធូរចុះមកខ្លះ យ៉ាងនេះទើបហៅថាមានន័យវិសេស ; ឬថា « ច្បាប់សម្រាប់

ទ្ធានកាយវាចា » ព្រោះវិន័យជាគ្រឿងទ្ធានកាយវាចាឱ្យមានរបៀបបៃបផែន ឱ្យមានសណ្តាប់ធ្នាប់ មិនឱ្យច្រឡោះបោះប្រព្រឹត្តអនាចារផ្សេងៗ ។

ពាក្យថា « សុត្ត » ប្រែថា « សំដែងចេញ » ថា « គឺព្រះដ៏មានព្រះភាគពោលដោយប្រពៃ » ថា « ញុំាងប្រយោជន៍ឱ្យកើត » ថា « ខ្សែបន្ទាត់ » ថា « ដោតក្រង » ។

អធិប្បាយថា ព្រះសូត្រនោះឯងសំដែងចេញនូវប្រយោជន៍ច្រើនប្រការ មានប្រយោជន៍ចំពោះខ្លួន និងប្រយោជន៍របស់អ្នកដទៃជាដើម ។ ប្រយោជន៍ទាំងអស់នោះ ព្រះដ៏មានព្រះភាគពោលដោយប្រពៃ គឺព្រះអង្គទ្រង់សំដែងអនុលោមតាមអធ្យាស្រ័យនៃវេនេយ្យសត្វ ; អាចញុំាងប្រយោជន៍គ្រប់ជំពូកឱ្យកើតឡើងបាន ; ជាពុទ្ធវចនៈត្រង់ដូចជាខ្សែបន្ទាត់នៃជាងឈើ គួរឱ្យវិញ្ញូជនទាំងឡាយកាន់យកជាបៃបជាប្រមាណ ; មិនជាពាក្យរាត់រាយទេ ជាពាក្យមានចង្កោម មានកម្រង ដូចជាផ្កាដែលនាយមាលាការអ្នកប៉ិនប្រសប់ដោតក្រងជារបៀបល្អ ។ ដោយបការនេះឯងទើបឈ្មោះថា « សុត្ត » ។

ឯពាក្យថា « អភិធម្ម » ប្រែថា « ធម៌មានសេចក្តីចំរើន, ធម៌ប្រកបដោយសេចក្តីកំណត់, ធម៌គួរឫជា, ធម៌មិនច្រឡំគ្នា, ធម៌ដ៏ក្រៃលែង » ។

ដែលថា « ធម៌មានសេចក្តីចំរើន » អធិប្បាយថា ព្រះយោគីណាដែលបានចំរើនធម៌នោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទាំងពួង ញុំាងឈានឱ្យកើតឡើងហើយ រមែងបានទៅកើតក្នុងឈានភូមិ ទើបឈ្មោះថា « មានសេចក្តីចំរើន » ។

ដែលថា « ធម៌ប្រកបដោយសេចក្តីកំណត់ » អធិប្បាយថា ធម៌នោះ, រមែងមានលក្ខណៈគ្រឿងកំណត់សំគាល់ដោយសភាវៈទាំងឡាយ មានអារម្មណ៍ទាំង ៥ ជាដើម ។

ដែលថា « ធមិគ្ខរបូជា » អធិប្បាយថា ធមិទាំងឡាយនោះ, គ្ខរដល់ កិរិយាបូជាដោយពិត ព្រោះជាសេក្ខធមិ, អសេក្ខធមិ និងលោកុត្តរធមិជាដើម ។

ដែលថា « ធមិមិនច្រឡំគ្នា » អធិប្បាយថា ធមិទាំងឡាយនោះ, មិន ច្រឡំគ្នាដោយសភាវៈ មានផស្សៈ និវេទនាជាដើម ។

ដែលថា « ធមិដ៏ក្រៃលែង » អធិប្បាយថា ធមិទាំងឡាយនោះ, ព្រះ មានព្រះភាគទ្រង់ត្រាស់សំដែងដ៏ក្រៃលែង មានមហគ្គតធមិ និងអប្បមាណធមិ និង អនុត្តរធមិជាដើម ។ ដោយការដែលរៀបរាប់មកនេះហៅថា « អភិធម្ម » ។

រួមប្រភេទទាំង ៣ គឺ ព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្ម ហៅថា បរិយត្តិ ឬព្រះត្រៃបិដក ។ ស័ព្ទថា « បិដក » ប្រែថា « ចំណែក » ឬថា « ភាជនៈ » ព្រោះព្រះបរិយត្តិធមិ មានកិរិយាចែកនូវអត្ថច្រើនផ្នែកផ្សេងដោយឡែកពីគ្នា, ឬថា ភាជនៈសម្រាប់ទ្រនូវពុទ្ធវចនៈទាំងពួង ។

ព្រះត្រៃបិដកនោះ, បើចែកជាទេសនា មាន ៣ គឺ *អាណាទេសនា ១ វោហារទេសនា ១ បរមត្ថទេសនា ១* ។ វិន័យបិដក ចាត់ជាអាណាទេសនា ព្រោះ ព្រះសម្ពុទ្ធសំដែងដោយអាជ្ញា គឺក្រឹត្យបញ្ញត្តិអំពីការខុសត្រូវ ។ សុត្តន្តបិដក ចាត់ជា វោហារទេសនា ព្រោះព្រះអង្គសំដែងដោយវោហារ ហេតុព្រះអង្គបុិនប្រសប់ក្នុងវិធី បញ្ជុះបញ្ជូលសត្ត ។ អភិធម្មបិដក ចាត់ជាបរមត្ថទេសនា ព្រោះព្រះអង្គសំដែងដោយ បរមត្ថសាច់ធមិដ៏ជ្រាលជ្រៅ ហេតុព្រះអង្គឈ្លាសវៃក្នុងប្រយោជន៍ខត្តម ។

ព្រះត្រៃបិដក បើចែកដោយសាសនា មាន ៣ គឺ *យថាបរាធសាសនា* ពាក្យប្រៀនប្រដៅតាមសមគ្ខរដល់កំហុសរបស់សត្ត បានដល់វិន័យបិដក ១ *យថានុលោមសាសនា* ពាក្យប្រៀនប្រដៅអនុលោមតាមសមគ្ខរដល់អធ្យាស្រ័យ និងអនុស័យ និងចរិតរបស់សត្ត បានដល់សុត្តន្តបិដក ១ *យថាធម្មសាសនា* ពាក្យ ប្រៀនប្រដៅដ៏សមគ្ខរដល់ធមិជាន់ខ្ពស់ ចំពោះសត្ត្ថដែលមានមានះខ្លាំង បានដល់

អភិធម្មបិដក ១ ។

បើចែកដោយកថា មាន ៣ គឺ *សំវរាសំវរកថា* ព្រះពុទ្ធដីកាសំដែងអំពីការសង្រួម និងមិនសង្រួម ដែលជាបដិបក្ខដល់អជ្ឈាចារ គឺការប្រព្រឹត្តល្មើស ចាត់ជាវិន័យបិដក ១ *ទិដ្ឋីវិនិវេឋនកថា* ព្រះពុទ្ធដីកាសំដែងអំពីការលះបង់នូវទិដ្ឋិ ដែលជាបដិបក្ខដល់ទិដ្ឋិ ៦២ ចាត់ជាសុត្តន្តបិដក ១ *នាមរូបបរិច្ឆេទកថា* ព្រះពុទ្ធដីកាសំដែងអំពីការកំណត់នូវនាមនិងរូប ដែលជាបដិបក្ខដល់កិលេស មានរាគៈជាដើម ចាត់ជាអភិធម្មបិដក ១ ។

បើចែកដោយសិក្ខា មាន ៣ គឺ *អធិសីលសិក្ខា* បានដល់វិន័យបិដក ១ *អធិចិត្តសិក្ខា* បានដល់សុត្តន្តបិដក ១ *អធិបញ្ញាសិក្ខា* បានដល់អភិធម្មបិដក ១ ។

បើចែកដោយបហាន មាន ៣ គឺ *វិតិក្ខមប្បហាន* កិរិយាលះបង់នូវវិតិក្កមកិលេសដែលជាសត្រូវដល់សីល ចាត់ជាវិន័យបិដក ១ *បរិយុដ្ឋានប្បហាន* កិរិយាលះបង់នូវបរិយុដ្ឋានកិលេស ដែលជាសត្រូវដល់សមាធិ ចាត់ជាសុត្តន្តបិដក ១ *អនុសយប្បហាន* កិរិយាលះបង់នូវអនុសយកិលេស ដែលជាសត្រូវដល់បញ្ញា ចាត់ជាអភិធម្មបិដក ១ ។ ម្យ៉ាងទៀត *តទង្គប្បហាន* កិរិយាលះបង់នូវកិលេសបានដោយពេលដោយស្របក់ ចាត់ជាវិនយបិដក, *វិក្ខម្ភនប្បហាន* កិរិយាលះបង់នូវកិលេសដោយការសង្កត់សង្កិនញ៉ាំញី ចាត់ជាសុត្តន្តបិដក, *សមុច្ឆេទប្បហាន* កិរិយាលះបង់នូវកិលេសដោយផ្តាច់ផ្តិលដាច់ស្រឡះ ចាត់ជាអភិធម្មបិដក ។

បណ្តាបិដកទាំង ៣ បិដកមួយ១ មានជម្រៅគម្ភីរភាព ៤ គឺ *ធម្មគម្ភីរ* មានជម្រៅដោយបាលី ១ *អត្ថគម្ភីរ* មានជម្រៅដោយសេចក្តីនៃបាលីនោះ ១ *ទេសនាគម្ភីរ* មានជម្រៅដោយកិរិយាសំដែងនូវបាលីនោះ ១ *បដិវេធគម្ភីរ* មានជម្រៅដោយការចាក់ធ្លុះចំពោះបាលី និងអត្ថរបស់បាលី ១ ។ ន័យមួយទៀតថា ធមិ

បានដល់ហេតុ, អត្ថ បានដល់ផលនៃហេតុ, ទេសនា បានដល់បញ្ញត្តិ គឺព្រះពុទ្ធដីកា ដែលពោលមិនភ្លាត់តាមសមគួរដល់ធម៌ពិត, បដិវេធ បានដល់**អភិសម័យ** គឺការត្រាស់ដឹងជាលោកិយ និងលោកុត្តរ ។

ក្នុងបិដកទាំង ៣ មានភាសិត ៤ គឺ :

- ពុទ្ធភាសិត ធម៌ដែលព្រះពុទ្ធទ្រង់សំដែងផ្ទាល់ព្រះអង្គ ១
- សាវកភាសិត ធម៌ដែលសាវ័កសំដែង បានដល់អនង្គណសូត្រ និងសម្មាទិដ្ឋិសូត្រ ជាដើម ១
- ឥសិភាសិត ធម៌ដែលឥសី ឬ បរិព្វាជកសំដែង បានដល់បរិព្វាជកវគ្គ ជាដើម ១
- ទេវតាភាសិត ធម៌ដែលទេវតា មារ ព្រហ្មសំដែង បានដល់របៀបពាក្យក្នុងទេវតាសំយុត្ត ជាដើម ១ ។

បរិយត្តិប្បភេទក្នុងបិដកមាន ៣ យ៉ាង គឺ អលគ្គទ្ធបមាបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិយបរិយត្តិ ១ ។ បរិយត្តិមានឧបមាដូចពស់មានពិសយ៉ាងណា គឺបរិយត្តិដែលបុគ្គលរៀនមិនល្អ ប្រកបដោយហេតុអាក្រក់ មានច័ងប្រាថ្នាតែបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម និងរៀនគ្រាន់តែប្រណាំងប្រជែងដណ្តើមយកមុខ គ្រាន់តែដោះពាក្យតំណិះដំណៀលជាដើមប៉ុណ្ណោះ រៀនន្ថវធម៌ហើយមិនពិចារណាសេចក្តីនៃធម៌នោះដោយបញ្ញា មិនពិនិត្យឱ្យជាក់ច្បាស់ ឱ្យបានគុណវិសេសដែលត្រូវបាន ត្រឡប់ជាបានតែសេចក្តីទុក្ខអស់កាលជាអង្វែង ព្រោះតែរៀនមិនល្អ ឧបមាដូចបុរសចង់បានពស់ ក្រឡេកឃើញពស់ធំ ល្មកដៃទៅចាប់ត្រង់កន្ទុយពស់ វាងាកបែរមកចឹក ជួនត្រូវកដៃ ជួនត្រូវដើមដៃជាដើម បុរសនោះរមែងដល់នូវមរណៈ បើពុំនោះទេ ក៏គង់ដល់នូវសេចក្តីទុក្ខស្ទើរតែនឹងស្លាប់ ព្រោះហេតុអ្វី ? ព្រោះតែខ្លួនចាប់មិនល្អ ពស់វាចឹក យ៉ាងណាមិញ មោយបុរសក្នុងសាសនានេះដែល

វៀនធម៌មិនល្អក៏ដូច្នោះដែរ បរិយត្តិបែបនេះហៅថា អលគ្គទ្ធូបមាបរិយត្តិ ។ បរិយត្តិដែលបុគ្គលវៀនល្អ គឺវៀនប្រាថ្នានឹងបំពេញនូវសីលក្ខន្ធជាដើម ដើម្បីរលាស់ខ្លួនឱ្យផុតពីវដ្តទុក្ខ បរិយត្តិបែបនេះឈ្មោះ និស្សរណត្ថបរិយត្តិ ។ បរិយត្តិដែលព្រះខីណាស្រពលោកអ្នកលះកិលេសបានអស់ហើយ លោកវៀនគ្រាន់តែរក្សាបវេណី រក្សាវង្សប៉ុណ្ណោះ បរិយត្តិបែបនេះឈ្មោះ ភណ្ឌាគារិយបរិយត្តិ ។

សេចក្តីប្រតិបត្តិក្នុងបិដកទាំង ៣ ហុចប្រយោជន៍ឱ្យផ្សេងគ្នាដូច្នេះ ភិក្ខុប្រតិបត្តិល្អក្នុងវិន័យ រមែងបានត្រៃវិជ្ជា ព្រោះអាស្រ័យសីលសម្បត្តិ ។ ប្រតិបត្តិល្អក្នុងព្រះសូត្រ រមែងបានអភិញ្ញា ៦ ព្រោះអាស្រ័យសមាធិសម្បត្តិ ប្រតិបត្តិល្អក្នុងអភិធម្ម រមែងបានបដិសម្ភិទា ៤ ព្រោះអាស្រ័យបញ្ញាសម្បត្តិ ។ បើប្រតិបត្តិខុសក្នុងព្រះវិន័យ ដល់នូវភាពទ្រុស្តសីល, ប្រតិបត្តិខុសក្នុងព្រះសូត្រ ដល់នូវភាពជាមិច្ឆាទិដ្ឋិ ប្រតិបត្តិខុសក្នុងព្រះអភិធម្ម ដល់នូវចិត្តក្អេច (ក្រឡាកចិត្ត ឬឆ្កួតចិត្ត) ។ ព្រះពុទ្ធវចនៈមានបការៈ ៣ ដូចពណ៌នាមកនេះ ។

បុ. ព្រះពុទ្ធវចនៈ មានបការ ៥ ចែកដោយនិកាយនោះ តើដូចម្តេច ?

វិ. ចែកដោយនិកាយ ៥ នោះដូច្នេះគឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

បុ. ពុទ្ធវចនៈ ចែកដោយអង្គ ៩ នោះ គឺអ្វីខ្លះ ?

វិ. សុត្តៈ ១ គេយ្យៈ ១ វេយ្យាករណៈ ១ គាថា ១ ឧទានៈ ១ ឥតិវុត្តកៈ ១ ជាតកៈ ១ អព្ភូតធម្មៈ ១ និងវេទល្លៈ ១ ។

. សុត្តៈ នោះបានដល់ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និងបរិវារៈ ជាដើមផង បានដល់ពួកសូត្រក្នុងសុត្តនិបាត មានមង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្តកសូត្រ ជាដើមផង និងបានដល់ពុទ្ធវចនៈដទៃដែលមានឈ្មោះថា សុត្តន្តៈផង ។

. គេយ្យៈ បានដល់សូត្រប្រកបដោយគាថាទាំងអស់ លើយនិងសគាថវគ្គ

ទាំងអស់ក្នុងសំយុត្តនិកាយ ។

- វេយ្យាករណៈ បានដល់អភិធម្មបិដកទាំងអស់ និងសូត្រដែលមិនលាយ ដោយគាថា ហើយនិងពុទ្ធវចនៈដទៃដែលមិនបានសង្ត្រោះចូលក្នុងអង្ត ៨ នេះផង ។

- គាថា បានដល់ធម្មបទ ថេរគាថា ថេរីគាថា ដែលជាគាថាសុទ្ធ ហើយមិន មានឈ្មោះថា សូត្រ ។

- ឧទានៈ បានដល់សូត្រទាំង ៨២ ដែលប្រកបដោយគាថា អាស្រ័យ សោមនស្សញ្ញាណ ។

- ឥតិវុត្តកៈ លោកសង្ត្រោះយកសូត្រ ១១០ ដែលពួកសាវ័កសំដែងអាង ដល់ព្រះពុទ្ធដីកាថា « *វុត្តំ ហេតំ ភគវតា* អាងដល់ព្រះពុទ្ធដីកានេះ ដែលព្រះមាន ជោគទ្រង់ត្រាស់សំដែងហើយ » ដូច្នេះជាដើម ។

- ជាតកៈ គឺរឿងរ៉ាវដែលព្រះអង្គសំដែងស្រាវជ្រាវអំពីអតីត សំដៅយក ជាតក ៥៥០ មានអបណ្ណកជាតកជាដើម ។

- អព្ភូតធម្មៈ បានដល់ព្រះសូត្រទាំងអស់ដែលប្រកបដោយអច្ឆរិយព្ភូតធមិ គឺធមិដែលព្រះអង្គសំដែង មានពាក្យថាមិនដែលកើត ឥឡូវកើតឡើងហើយ ថាគួរ អស្ចារ្យ គួរស្ងើច ដូចសូត្រមានបាលីថា « *ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ* ម្នាលភិក្ខុទាំងឡាយ ធមិមិនដែលកើតហើយ កើតឡើងបានគួរអស្ចារ្យ ៤ ប្រការនេះ រមែងមានក្នុងអានន្ទ » ដូច្នេះជាដើម ។

- វេទល្លៈ គឺពួកសូត្រដែលគេសួរហើយ បានចេះដឹង បានសេចក្តីរីករាយ ហៅថា វេទល្លៈ ។ ពុទ្ធវចនៈមានអង្ត ៩ ដូចពណិនាមកនេះ ។

ឃុ. ដូចម្តេច ពុទ្ធវចនៈដែលចែកដោយធម្មក្ខន្ធជា ៨៤០០០ ព្រះធម្ម-ក្ខន្ធ ?

វិ. ព្រះពុទ្ធវចនៈទាំងអស់ មានប្រភេទ ៨៤000 ចាត់ដោយធម្មក្ខន្ធតាម ថេរវាចាដែលព្រះអានន្ទបានប្រកាសថា :

ទ្វាសីតិ ពុទ្ធតោ គណ្ហី ទ្វេសហស្សានិ ភិក្ខុតោ
ចតុរាសីតិ សហស្សានំ យេ មេ ធម្មា បវត្តិនោ ។

ប្រែថា « ធមិទាំងឡាយដែលមាននៅក្នុងហ្ជូទ័យរបស់ខ្ញុំ ៨៤000 ព្រះធម្មក្ខន្ធនោះ, ខ្ញុំបានរៀនផ្ទាល់អំពីសំណាក់ព្រះពុទ្ធអង្ត ៨២000 ធម្មក្ខន្ធ, រៀនអំពីសំណាក់ភិក្ខុ ២000 ធម្មក្ខន្ធ ។ ឯធម្មក្ខន្ធមួយ១ បើក្នុងព្រះសូត្រ, សូត្រដែលមានអនុសន្ធិមួយ ហៅថា ធម្មក្ខន្ធ ១, សូត្រដែលមានអនុសន្ធិច្រើនត្រូវរាប់អនុសន្ធិមួយ១ ក្នុងសូត្រនោះថាជាធម្មក្ខន្ធមួយ១, ក្នុងគាថាពន្ធ ពាក្យដែលសូរបញ្ហាចាត់ជាធម្មក្ខន្ធមួយ១, ពាក្យដែលឆ្លើយក៏ចាត់ជាធម្មក្ខន្ធមួយដែរ ។ បើក្នុងអភិធម្ម ផ្នែកតិកៈទុកៈមួយ១ ឬផ្នែកចិត្តវារៈមួយ១ ចាត់ជាធម្មក្ខន្ធមួយ១ ។ ចំណែកខាងវិន័យ មានរឿង មានមាតិកា មានបទភាជនីយៈ មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ មានកំណត់តិកៈ ហើយក្នុងរឿងមួយ១ ត្រូវចាត់ជាធម្មក្ខន្ធមួយ១ មាតិកាមួយ១ ចាត់ជាធម្មក្ខន្ធមួយ១ ដូចគ្មាតទៅ ។ ពុទ្ធវចនៈចែកដោយធម្មក្ខន្ធយ៉ាងនេះឯង ។

ឯវិ តាវ បរិយត្តិធម្មោ ស្វាក្ខាតោ

ព្រះបរិយត្តិធមិ ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រពៃ ដូចសេចក្តីដែលសំដែងមកក្នុងខាងលើទាំងប៉ុណ្ណេះនេះ ។

បុ. ចុះចំណែកខាងលោកុត្តរធមិ ដែលព្រះអង្តសំដែងដោយប្រពៃនោះ តើដូចម្តេច ?

វិ. លោកុត្តរធមិ ដែលព្រះអង្តសំដែងដោយប្រពៃនោះ គឺព្រះអង្តសំដែងអំពីបដិបទា សេចក្តីបដិបត្តិមានសភាពសមគួរដល់ព្រះនិព្វាន ។ ព្រះនិព្វាន ក៏មាន

សភាពសមគួរដល់សេចក្តីបដិបត្តិ ព្រោះព្រះនិព្វានដែលបុគ្គលគប្បីដល់ដោយសេចក្តីប្រតិបត្តិ ជាស្ថានបរិសុទ្ធ មិនមានកិលេសគឺ រាគៈ ទោសៈ មោហៈ រួចចំណែកខាងបដិបទាដែលជាដំណើរទៅកាន់ព្រះនិព្វាន គឺត្រៃសិក្ខាសោត ក៏ជាធម្មជាតិសម្រាប់ឃាត់កិលេសដែរគឺ សីលឃាត់រាគៈ ទោសៈ មោហៈ ដ៏ជ្រោកជ្រាកដែលជាវិតក្កៈ គឺសេចក្តីប្រព្រឹត្តកន្លងសិក្ខាបទដោយកាយវាចា ចំណែកសមាធិឃាត់កិលេសគឺ រាគៈ ទោសៈ មោហៈ យ៉ាងកណ្តាល ឯបញ្ញាឃាត់កិលេសគឺ រាគៈ ទោសៈ មោហៈ យ៉ាងល្អិតដែលឈ្មោះថាអនុសយ (កិលេសដែលត្រាំនៅក្នុងសន្តាន) ។ នេះឯងជាផ្លូវប្រតិបត្តិដើម្បីដល់នូវព្រះនិព្វាន មិនទាស់ចំនងគ្នានឹងព្រះនិព្វានជាផ្លូវសមគួរមិនមូលហូរចូលមកក្នុងទីជាមួយគ្នា ប្រៀបដូចទឹកក្នុងស្ទឹងគង្គា ហូរចុះទៅទីជាមួយគ្នា ចួយអន្លើដោយទឹកក្នុងស្ទឹងយមុនាស្មើគ្នាដោយពណ៌និងរស មិនខុសគ្នាឡើយ ។ ព្រោះហេតុនោះហើយបានជាលោកុត្តរធម៌ ឈ្មោះថាគឺព្រះដ៏មានព្រះភាគសំដែងហើយដោយប្រពៃ ។

បុ. ចុះដូចម្តេចហៅថា « លោកុត្តរធម៌ » ?

ឆ. *លោកំ ឧត្តរន្តី'តិ លោកុត្តរា* ធម៌ស្រង់ឡើងនូវសត្វលោក ហៅថា លោកុត្តរៈ ។ *លោកា ឧត្តរន្តី'តិ >លោកុត្តរា* ធម៌ស្ងួយឡើងនូវសត្វឱ្យឆ្លងចាកលោក ហៅថា លោកុត្តរៈ ។ *លោកេ អតិរេកា'តិ >លោកុត្តរា* ធម៌ប្រសើរឯកក្នុងលោក ហៅថា លោកុត្តរៈ ។

បុ. លោកុត្តរធម៌នោះ បានដល់ធម៌ណាខ្លះ ?

ឆ. បានដល់សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ និងព្រះនិព្វាន ១ ។

បុ. សតិប្បដ្ឋាន ៤ នោះគឺអ្វីខ្លះ ?

វិ. *កាយានុបស្សនា សតិប្បដ្ឋាន* តម្កល់ស្មារតីពិចារណារាងកាយ ១ *វេទនានុបស្សនា សតិប្បដ្ឋាន* តម្កល់ស្មារតីពិចារណាវេទនា ១ *ចិត្តានុបស្សនា សតិប្បដ្ឋាន* តម្កល់ស្មារតីពិចារណាចិត្ត ១ *ធម្មានុបស្សនា សតិប្បដ្ឋាន* តម្កល់ស្មារតីពិចារណាធម៌ ១ ។

បុ. ត្រូវពិចារណារាងកាយ ដូចម្តេច ?

វិ. ត្រូវពិចារណាដូច្នេះថា ឱរ៉ឺ ! បឋវីកាយ[1] ជាដើមនេះ មិនទៀងសោះទេ តែងតែមានទុក្ខ មិនមែនខ្លួន ហើយក៏នឿយណាយប្រាសចាកតម្រេក ស្ងប់រំងាប់ មិនជាប់ចិត្ត ; កាលពិចារណាថាមិនទៀង រមែងលះបង់និច្ចសញ្ញា កាលពិចារណាថាទុក្ខ រមែងលះបង់សុខសញ្ញា កាលពិចារណាថាមិនមែនខ្លួន រមែងលះបង់អត្តសញ្ញា ។ កាលនឿយណាយ រមែងលះបង់សេចក្តីរីករាយ កាលប្រាសចាកតម្រេក រមែងលះបង់រាគៈ កាលដែលស្ងប់រំងាប់ រមែងលះបង់នូវសមុទយៈ កាលមិនជាប់ចិត្ត រមែងលះបង់សេចក្តីប្រកាន់ ។ ត្រូវពិចារណានូវកាយយ៉ាងនេះ ហៅថា កាយានុបស្សនា សតិប្បដ្ឋាន ។

បុ. ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗ នូវវេទនាដូចម្តេច ?

---

(១) រាប់ដោយពិស្តារ : បឋវីកាយ ពួកធាតុដី, អាបោកាយ ពួកធាតុទឹក, តេជោកាយ ពួកធាតុភ្លើង, វាយោកាយ ពួកធាតុខ្យល់, កេសកាយ ពួកសក់, លោមកាយ ពួករោម, នខកាយ ពួកសម្បុរថ្លៃ, ទន្តកាយ ពួកស្បែក, មំសកាយ ពួកសាច់, នហារុកាយ ពួកសរសៃ, អដ្ឋិកាយ ពួកឆ្អឹង, អដ្ឋិមិញ្ជកាយ ពួកខួរក្នុងឆ្អឹង ។

(២)រាប់ដោយពិស្តារ : សុខវេទនា ធម្មជាតិសោយអារម្មណ៍ជាសុខ, ទុក្ខវេទនា ធម្មជាតិសោយអារម្មណ៍ជាទុក្ខ អទុក្ខមសុខវេទនា ធម្មជាតិសោយអារម្មណ៍មិនស្មោះជាទុក្ខជាសុខ, ចក្ខុសម្ផស្សវេទនា វេទនាដែលកើតអំពីចក្ខុពាល់ត្រូវអារម្មណ៍, សោតសម្ផស្សវេទនា វេទនាដែលកើតអំពីត្រចៀកពាល់ត្រូវអារម្មណ៍, ឃានសម្ផស្សវេទនា វេទនាដែលកើតអំពីច្រមុះពាល់ត្រូវអារម្មណ៍ ។

(៣) រាបដោយពិស្តារ សរាគំ ចិត្តំ ចិត្តនៅមានរាគ, វិគតរាគំ ចិត្តំ ចិត្តប្រាសចាករាគៈហើយ, សទោសំ ចិត្តំ ចិត្តនៅមានទោសៈ វិគតទោសំ ចិត្តំ ចិត្តប្រាសចាកទោសហើយ សមោហំ ចិត្តំ ចិត្តនៅមានមោហៈ វិគតមោហំ →

វិ. ពិចារណាដូច្នេះថា ឱហ្ន ! សុខវេទនា[២] ជាដើមនេះ មិនទៀងសោះទេ តែងតែមានទុក្ខមិនមែនខ្លួន ហើយក៏នឿយណាយប្រាសចាកតម្រេក ស្ងប់រំងាប់ មិនជាប់ចិត្ត ; កាលពិចារណាដូច្នេះហើយក៏លះបង់នូវធម៌បានជាលំដាប់ៗ ដូចន័យមុន, ភិក្ខុពិចារណានូវវេទនាយ៉ាងនេះហៅថា វេទនានុបស្សនា សតិប្បដ្ឋាន ។

បុ. ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗនូវចិត្ត ដូចម្តេច ?

វិ. ពិចារណាដូច្នេះថា ឱហ្ន ! ចិត្ត[៣] ដែលប្រកបដោយរាគៈ ជាដើមនេះ មិនទៀងសោះទេ តែងតែនាំមកនូវសេចក្តីទុក្ខ មិនមែនខ្លួន, ហើយក៏នឿយណាយ, ប្រាសចាកតម្រេក ស្ងប់រំងាប់, មិនជាប់ចិត្ត ; កាលពិចារណាដូច្នេះ ក៏លះបង់នូវធម៌បានជាលំដាប់ៗដូចគ្នា ។ ភិក្ខុពិចារណានូវចិត្តយ៉ាងនេះ ហៅថា ចិត្តានុបស្សនា សតិប្បដ្ឋាន ។

បុ. ភិក្ខុក្នុងសាសនានេះ ពិចារណានូវធម៌[១] រឿយៗ ដូចម្តេច ?

វិ. ពិចារណាដូច្នេះថា ឱហ្ន ! ធម៌នេះមិនទៀងសោះទេ នាំមកនូវសេចក្តីទុក្ខ មិនមែនខ្លួន ហើយក៏នឿយណាយប្រាសចាកតម្រេក ស្ងប់រំងាប់ មិនជាប់ចិត្ត ; កាលពិចារណាថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា, កាលពិចារណាថាមិនមែនខ្លួន រមែងលះបង់នូវអត្តសញ្ញា, កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលប្រាសចាកតម្រេក រមែងលះបង់នូវរាគៈ កាលស្ងប់រំងាប់ រមែងលះបង់នូវសមុទយៈ កាលមិនជាប់ចិត្ត រមែងលះបង់នូវសេចក្តីប្រកាន់ ។ ភិក្ខុពិចារណានូវធម៌យ៉ាងនេះ ហៅថា ធម្មានុបស្សនា សតិប្បដ្ឋាន ។

ចិត្តំ ចិត្តប្រាសចាកមោហៈហើយ, សង្ខិត្តំ ចិត្តំ ចិត្តរួញរា, វិក្ខិត្តំ ចិត្តំ ចិត្តរាយរាយ, ...

(១) ធម៌ក្នុងទីនេះ សំដៅយកនីវរណៈ ៥ ឧបាទានក្ខន្ធ ៥ អាយតនៈ ១២ ជាដើម ។

បុ. សម្មប្បធាន គឺសេចក្តីព្យាយាមជាគ្រឿងតាំងទុក្ខទ្ធទៅព្រម មាន ៤ គឺអ្វីខ្លះ ?

វិ. សេចក្តីព្យាយាមដើម្បីនឹងលះបាបធម៌ដែលកើតឡើងហើយ ១ សេចក្តីព្យាយាមដើម្បីញុំាងបាបធម៌ដែលមិនទាន់កើតឡើងមិនឱ្យកើតឡើងបាន ១ សេចក្តីព្យាយាមដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឱ្យកើតឡើង ១ សេចក្តីព្យាយាមញុំាងកុសលធម៌ដែលកើតឡើងហើយ ឱ្យចំរើនឡើងដោយភិយ្យោភាពក្រៃលែងឡើង ១ ; ត្រូវជា ៤ ។

បុ. ឥទ្ធិបាទ ៤ ប្រការនោះ គឺអ្វីខ្លះ ?

វិ. *ឆន្ទិទ្ធិបាទ* សេចក្តីចំណងជាទីតាំងនៃឫទ្ធិ ១ *វីរិយិទ្ធិបាទ* សេចក្តីប្រឹងប្រែងជាទីតាំងនៃឫទ្ធិ ១ *ចិត្តិទ្ធិបាទ* សេចក្តីសន្សំត្រិះរិះជាទីតាំងនៃឫទ្ធិ ១ *វីមំសិទ្ធិបាទ* ប្រាជ្ញាដែលដឹងត្រប់យ៉ាងជាទីតាំងនៃឫទ្ធិ ១ ; ត្រូវជា ៤ ។

បុ. ឥន្ទ្រិយ ៥ ប្រការនោះ តើដូចម្តេចខ្លះ ?

វិ. ឥន្ទ្រិយទាំង ៥ នោះដូច្នេះ គឺ *សទ្ធិន្ទ្រិយំ* សេចក្តីជឿចាត់ជារបស់ធំ ១ *វីរិយិន្ទ្រិយំ* សេចក្តីព្យាយាមចាត់ជារបស់ធំ ១ *សតិន្ទ្រិយំ* សតិចាត់ជារបស់ធំ ១ *សមាធិន្ទ្រិយំ* សមាធិចាត់ជារបស់ធំ ១ *បញ្ញិន្ទ្រិយំ* បញ្ញាចាត់ជារបស់ធំ ១ ។

បុ. ចុះឥន្ទ្រិយទាំង ៥ នោះ បរិសុទ្ធដោយអាការ ប៉ុន្មានយ៉ាង ?

វិ. ឥន្ទ្រិយទាំង ៥ នោះ បរិសុទ្ធដោយអាការៈ ១៥ ; ឥន្ទ្រិយមួយ១ បរិសុទ្ធដោយអាការ បី១ ដូច្នេះ :

- សទ្ធិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ គឺ *អស្សទ្ធេ បុគ្គលេ បរិវជ្ជយតោ* ដោយវៀរបុគ្គលដែលគ្មានសទ្ធា ១ *សទ្ធេ បុគ្គលេ សេវិតោ* ដោយគប់រកបុគ្គលដែលមានសទ្ធា ១ *បសាទនីយេ សុត្តន្តេ បច្ចវេក្ខិតោ* ដោយពិចារណាព្រះសូត្រដែលជាទីញុំាងចិត្តឱ្យជ្រះថ្លា ១ ។

- វីរិយិន្ទ្រីយ បរិសុទ្ធដោយអាការ ៣ គឺ *កុសីតេ បុគ្គលេ បរិវជ្ជយតោ* ដោយចៀសវាងបុគ្គលខ្ជិលច្រអូស ១ *អារទ្ធវីរិយេ បុគ្គលេ បដិសេវិតោ* ដោយគប់រកបុគ្គលដែលមានព្យាយាមប្រឹងប្រែង ១ *សម្មប្បធានេ បច្ចវេក្ខិតោ* ដោយពិចារណាសម្មប្បធានទាំងបួន ១ ។

- សតិន្ទ្រីយ បរិសុទ្ធដោយអាការ ៣ គឺ *មុដ្ឋស្សតិបុគ្គលេ បរិវជ្ជយតោ* ដោយវ្យែរបុគ្គលដែលមានសតិមិនខ្ជាប់ខ្ជួន ១ *ឧបដ្ឋិតស្សតិបុគ្គលេ បដិសេវិតោ* ដោយគប់រកបុគ្គលដែលមានសតិមាំ ១ *សតិប្បដ្ឋានេ បច្ចវេក្ខិតោ* ដោយពិចារណាសតិប្បដ្ឋានទាំងបួន ១ ។

- សមាធិន្ទ្រីយ បរិសុទ្ធដោយអាការ ៣ គឺ *អសមាហិតេ បុគ្គលេ បរិវជ្ជយតោ* ដោយវ្យែរបុគ្គលដែលមានចិត្តសាត់អណ្តែតមិនបានតម្កល់មាំ ១ *សមាហិតេ បុគ្គលេ សេវិតោ* ដោយសេពគប់បុគ្គលដែលមានចិត្តតម្កល់មាំ ១ *ឈានវិមោក្ខេ បច្ចវេក្ខិតោ* ដោយពិចារណានូវឈាន និងវិមោក្ខ ១ ។

- បញ្ញិន្ទ្រីយ បរិសុទ្ធដោយអាការ ៣ គឺ *ទុប្បញ្ញេ បុគ្គលេ បរិវជ្ជយតោ* ដោយវ្យែរបុគ្គលដែលអប្បប្រាជ្ញា ១ *បញ្ញវន្តេ បុគ្គលេ បដិសេវិតោ* ដោយសេពគប់បុគ្គលដែលមានប្រាជ្ញា ១ *គម្ភិរញ្ញាណចរិយំ បច្ចវេក្ខិតោ* ដោយពិចារណានូវញ្ញាណចរិយៈ ដ៏ជ្រាលជ្រៅ ១ ។

ឥន្ទ្រីយទាំង ៥ នេះ បរិសុទ្ធដោយវ្យែរបុគ្គល ៥ ពួក ដោយសេពគប់បុគ្គល ៥ ពួក ដោយពិចារណានូវព្រះសូត្រ ៥ រួមទាំងអស់ត្រូវជាអាការ ១៥ ។

បុ. ចុះឥន្ទ្រីយទាំង ៥ នោះ បើនឹងចំរើនដោយអាការ ប៉ុន្មានយ៉ាង ?

វិ. ដោយអាការ ១០ យ៉ាងគឺ ក្នុងឥន្ទ្រីយមួយ១ ចំរើនឡើងដោយអាការពីរ១ ដូច្នេះ :

. *អស្សទ្ធិន្ទ្រីយំ បជហន្តោ សទ្ធិន្ទ្រិយំ ភាវេតិ* លះបង់នូវអស្សទ្ធិន្ទ្រីយ ចំរើនសទ្ធិន្ទ្រីយ ១

. *សទ្ធិន្ទ្រិយំ ភាវេន្តោ អស្សទ្ធិន្ទ្រិយំ បជហតិ* ចំរើនសទ្ធិន្ទ្រីយ លះបង់អស្សទ្ធិន្ទ្រីយ ១

. *កោសជ្ជំ បជហន្តោ វីរិយិន្ទ្រិយំ ភាវេតិ* លះបង់កោសជ្ជៈ ចំរើនវិរិយិន្ទ្រីយ ១

. *វីរិយិន្ទ្រិយំ ភាវេន្តោ កោសជ្ជំ បជហតិ* ចំរើនវិរិយិន្ទ្រីយ លះបង់កោសជ្ជៈ ១

. *បមាទំ បជហន្តោ សតិន្ទ្រិយំ ភាវេតិ* លះបង់សេចក្តីប្រមាទ ចំរើនសតិន្ទ្រីយ ១

. *សតិន្ទ្រិយំ ភាវេន្តោ បមាទំ បជហតិ* ចំរើនសតិន្ទ្រីយ លះបង់សេចក្តីប្រមាទ ១

. *ឧទ្ធច្ចំ បជហន្តោ សមាធិន្ទ្រិយំ ភាវេតិ* លះបង់ឧទ្ធច្ចៈ ចំរើននូវសមាធិន្ទ្រីយ ១

. *សមាធិន្ទ្រិយំ ភាវេន្តោ ឧទ្ធច្ចំ បជហតិ* ចំរើននូវសមាធិន្ទ្រីយ លះបង់នូវឧទ្ធច្ចៈ ១

. *អវិជ្ជំ បជហន្តោ បញ្ញិន្ទ្រិយំ ភាវេតិ* លះបង់នូវអវិជ្ជា ចំរើននូវបញ្ញិន្ទ្រីយឱ្យកើតឡើង ១

. *បញ្ញិន្ទ្រិយំ ភាវេន្តោ អវិជ្ជំ បជហតិ* ចំរើនបញ្ញិន្ទ្រីយ លះបង់អវិជ្ជា១

ឥន្ទ្រីយទាំង ៥ នោះ បើបុគ្គលបានចំរើនល្អហើយ ឈ្មោះថាធ្វើឱ្យបរិសុទ្ធនូវមគ្គ និងផល ។

បុ. បុគ្គលគួរចំណែនន្ទ្រវឥន្ទ្រិយទាំងនោះ មានប៉ុន្មានពួក ?

វិ. មាន ៨ ពួកគឺ សេក្ខបុគ្គល ៧ មានសោតាបត្តិមគ្គដ្ឋ ជាដើម មានអរហត្តមគ្គដ្ឋ ជាទីបំផុត នឹងរាប់បថុជ្ជនមួយបញ្ចូលផងជា ៨ ។

បុ. ពល (កម្លាំង) ៥ នោះ គឺអ្វីមួយ ?

វិ. សទ្ធា ១ វីរិយ ១ សតិ ១ សមាធិ ១ បញ្ញា ១ ត្រូវជា ៥ ។

បុ. ដូចម្តេចហៅថា សទ្ធាពល ?

វិ. ធម្មជាតិមិនរំភើបក្នុងសភាពដែលមិនគួរជឿ ហៅថា សទ្ធាពល សទ្ធាពលនេះ មានអត្ថថា « ជួយឧបត្ថម្ភសហជាតធម៌ទាំងឡាយ » ថា «សំអាតន្ទ្រវកិច្ចទាំងឡាយ មានកិរិយាត្រាស់ដឹងជាដើម» ថា «ជាគ្រឿងតម្កល់ ឬតាំងចិត្ត » ថា « ជាគ្រឿងផ្ទ្រផង់ចិត្ត » ថា « ជាគ្រឿងត្រាស់ដឹងន្ទ្រវគុណវិសេស » ថា « ជាគ្រឿងត្រាស់ដឹងន្ទ្រវគុណវិសេស » ថា « ជាគ្រឿងត្រាស់ដឹងក្រៃលែង » ថា « ជាគ្រឿងត្រាស់ដឹងន្ទ្រវសច្ចៈ » ថា « ជាធម្មជាតិញ៉ាំងបុគ្គលឱ្យប្រតិស្ឋាននៅក្នុងនិរោធ » ។

បុ. ដូចម្តេចហៅថា វីរិយពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងកោសជ្ជៈ ហៅថា វីរិយពល ដែលហៅថា វីរិយៈ ព្រោះមានអត្ថថា « ជួយឧបត្ថម្ភសហជាតធម៌ទាំងឡាយ » ថា « គ្របសង្កត់ន្ទ្រវកិលេសទាំងឡាយ » ថា « សំអាតន្ទ្រវកិច្ចមានបដិវេធៈជាដើម » ថា « ជាទីតាំងនៃចិត្ត » ថា « ជាគ្រឿងត្រាស់ដឹងន្ទ្រវសច្ចៈ » ថា « ជាធម្មជាតិញ៉ាំងបុគ្គលឱ្យតាំងនៅក្នុងព្រះនិព្វាន » ។

បុ. ដូចម្តេច សតិពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងសេចក្តីប្រមាទ ហៅថា សតិពល ។ សតិពលនេះមានអត្ថថា « ជួយឧបត្ថម្ភន្ទ្រវសហជាតធម៌ទាំងឡាយ » ។ ល ។ ថា « ជាធម្ម-ជាតិញ៉ាំងបុគ្គលឱ្យប្រតិស្ឋានន្ទ្រវក្នុងព្រះនិព្វាន » ។

✓ បុ. ដូចម្តេច សមាធិពល ?

វិ: ធម្មជាតិមិនញាប់ញ័រក្នុងឧទ្ធច្ចៈ ហៅថា សមាធិពល ។ សមាធិពលនេះ មានអត្ថថា « ជួយឧបត្ថម្ភន្ទួរសហជាតធម៌ទាំងឡាយ » . ល . ថា « ជាធម្មជាតិញុំាងបុគ្គលឱ្យប្រតិស្ឋាននៅក្នុងព្រះនិព្វាន » ។

បុ. ដូចម្តេច បញ្ញាពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងអវិជ្ជា ហៅថា បញ្ញ ាពល ។ បញ្ញ ាពលនេះ មានអត្ថថា « ជួយឧបត្ថម្ភន្ទួរសហជាតធម៌ទាំងឡាយ ។ ល ។ »

បុ. ពោជ្ឈង្គ (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ៧ គឺអ្វីខ្លះ ?

វិ. ១. *សតិសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ ។ សតិ ប្រែថា « សេចក្តីរលឹក » ឬថា « សេចក្តីកំណត់បាន » ជាធម៌សំខាន់បំផុតក្នុងការ ញុំាងប្រយោជន៍ឱ្យសម្រេច ព្រោះថា បុគ្គលនឹងធ្វើការងារឯណាដោយកាយ ឬ ដោយវាចា លុះត្រាតែសតិនេះជាទីតាំង ទើបការងារនោះសំរេចបានតាមសេចក្តី ប្រាថ្នា ។ ម្យ៉ាងទៀត សតិជាគ្រឿងគយគន់ ឬរាំងរក្សាន្ទួរទ្វារទាំងឡាង មានចក្ខុទ្វារ ជាដើម មិនឱ្យអភិជ្ឈា និងទោមនស្សជាដើមចូលមកបាន ក្នុងពេលដែលអារម្មណ៍ ទាំងឡាយ មានរូបជាដើមមកខ្ទាំងខ្ទប់ ប្រៀបដូចជាអ្នករក្សាទ្វារព្រះរាជនិវេសន៍ រមែងរាំងមើលមនុស្សដែលគួរឱ្យចូលបាន បើមនុស្សណាគួរឱ្យចូល ក៏បើកឱ្យ ចូលទៅ មនុស្សណាមិនគួរឱ្យចូល ក៏ឃាត់មិនឱ្យចូល ព្រោះហេតុនោះបានជាថា សតិនេះជាធម៌សំខាន់បំផុត តែថាសតិក្នុងទីនេះ សំដៅត្រង់រលឹកត្រូវ មានរលឹកក្នុង សតិបដ្ឋានបួន ជាដើម ។

២. *ធម្មវិចយសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺធម្មវិចយៈ ។ ធម្មវិចយៈ ប្រែថា ប្រាជ្ញាពិចារណាន្ទួរធម៌ លើយប្រតិបត្តិសមគួរតាមធម៌ដោយ

សេចក្តីយល់ត្រូវ ដោយការពិនិត្យ ដែលល្មមជាឧបាយលះកិលេសបាន ។

៣. *វីរិយសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺ វីរិយៈ សេចក្តីព្យាយាមប្រឹងប្រែងត្រូវតាមសម្មប្បធានទាំង ៤ ប្រការ ។

៤. *បីតិសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបីតិ សេចក្តីឆ្អែតចិត្ត ។ បីតិនេះជាហេតុនាំឱ្យបុគ្គលធ្វើកិច្ចទាំងឡាងសម្រេច ពីព្រោះការអ្វី១ ជាអាស្រ័យសេចក្តីត្រេកអរ សេចក្តីពេញចិត្ត ទើបបុគ្គលប្រឹងធ្វើកើត ព្រោះហេតុដែលកាលបើបីតិមានហើយ ជាគុណញ៉ាំងកិច្ចទាំងឡាងឱ្យសម្រេចបាន ។

៥. *បស្សទ្ធិសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបស្សទ្ធិ បានដល់ភាពនៃកាយ និងចិត្តស្ងប់រំងាប់រម្ងាប់រយ ជាគុណនាំឱ្យសម្រេចកិច្ចទាំងឡាង ពីព្រោះបុគ្គលនឹងធ្វើកិច្ចអ្វី១ ដោយកាយក្តី ដោយចិត្តក្តី លុះត្រាតែកាយ និងចិត្តស្ងប់ គ្មានក្រវល់ក្រវាយ ទើបធ្វើបាន ។

៦. *សមាធិសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសមាធិ បានដល់ការតាំងចិត្តឱ្យស្ថិតនៅនឹងក្នុងអារម្មណ៍ ជាគុណនាំឱ្យឃើញត្រៃលក្ខណ៍ជាដើម ។

៧. *ឧបេក្ខាសម្ពោជ្ឈង្គ* អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺឧបេក្ខា សេចក្តីព្រងើយកន្តើយ មិនសោមនស្ស មិនទោមនស្ស ជាគុណឱ្យសម្រេចប្រយោជន៍ទាំងឡាងបាន ។

ឬ. អដ្ឋង្គិកមគ្គទាំង ៨ គឺអ្វីមួយ ?

ឆ. *សម្មាទិដ្ឋិ* បញ្ញាយល់ត្រូវ ១ *សម្មាសង្កប្បោ* តំនិតត្រិះរិះត្រូវ ១ *សម្មាវាចា* សំដីនិយាយត្រូវ ១ *សម្មាកម្មន្តោ* ការងារត្រូវ ១ *សម្មាអាជីវោ* ចិញ្ចឹមជីវិតត្រូវ ១ *សម្មាវាយាមោ* ព្យាយាមត្រូវ ១ *សម្មាសតិ* រលឹកត្រូវ ១ *សម្មាសមាធិ* តម្កល់ចិត្តត្រូវ ១ ។

បុ. *សម្មាទិដ្ឋិ* បញ្ញាយល់ត្រូវ ដូចម្តេច ?

វិ. យល់ត្រូវដូច្នេះគឺ *ទុក្ខេ ញាណំ* យល់ក្នុងកងទុក្ខទាំង ១២ *ទុក្ខ-សមុទយេ ញាណំ* យល់ក្នុងហេតុដែលប្រជុំឱ្យកើតទុក្ខ, *ទុក្ខនិរោធេ ញាណំ* យល់ក្នុងកន្លែងដែលរលត់ទុក្ខ *ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ* យល់ក្នុងសេចក្តីប្រតិបត្តិ ដែលជាដំណើរទៅកាន់កន្លែងរលត់ទុក្ខ, យ៉ាងនេះហៅថា សម្មាទិដ្ឋិ ។

បុ. ចុះសម្មាទិដ្ឋិនុ៎ះ តើមានប៉ុន្មានយ៉ាង ?

វិ. មាន ២ យ៉ាង គឺ *លោកិយសម្មាទិដ្ឋិ* បញ្ញាយល់ត្រូវជាលោកិយៈ គឺយល់ថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ១ *លោកុត្តរសម្មាទិដ្ឋិ* បញ្ញាយល់ត្រូវជាលោកុត្តរៈ គឺយល់ក្នុងសច្ចធម៌ទាំង ៤ មានទុក្ខសច្ចជាដើម ១ ។ បើចែកតាមឈ្មោះបុគ្គលវិញ សម្មាទិដ្ឋិមាន ៣ គឺ *បុថុជ្ជនទិដ្ឋិ* បញ្ញាយល់ត្រូវរបស់បុថុជ្ជន ១ *សេក្ខសម្មាទិដ្ឋិ* បញ្ញាយល់ត្រូវរបស់សេក្ខបុគ្គល ៧ ជំពូក មានសោតាបត្តិមគ្គដ្ឋជាដើម អរហត្តមគ្គដ្ឋ ជាបរិយោសាន ១ *អសេក្ខសម្មាទិដ្ឋិ* បញ្ញាយល់ត្រូវនៃអសេក្ខបុគ្គល គឺព្រះអរហត្តផលដ្ឋ ១ ។

បុ. *សម្មាសង្កប្បោ* គំនិតត្រិះរិះត្រូវ ដូចម្តេច ?

វិ. គំនិតត្រិះរិះត្រូវដូច្នេះគឺ នេក្ខម្មសង្កប្បោ ត្រិះរិះដើម្បីចេញចាកកាម-គុណ, អព្យាបាទសង្កប្បោ ត្រិះរិះដើម្បីមិនព្យាបាទ អវិហឹសាសង្កប្បោ ត្រិះរិះដើម្បីមិនប្បៀតប្បៀន យ៉ាងនេះហៅថា សម្មាសង្កប្បោ ។ ប្រការមួយទៀត សម្មាទិដ្ឋិបញ្ញាយល់ត្រូវយ៉ាងណា ត្រិះរិះតាមយ៉ាងនោះ តាមដំណើរដែលយល់នោះ ដូច្នេះក៏ហៅថា សម្មាសង្កប្បោ ។

បុ. *សម្មាវាចា* សំដីនិយាយត្រូវ ដូចម្តេច ?

វិ. សំដីនិយាយត្រូវតាមដំណើរសម្មាទិដ្ឋិគឺ *មុសាវាទា វេរមណី* វៀរពាក្យកុហក, *បិសុណាយ វាចាយ វេរមណី* វៀរពាក្យញុះញង់ ឬអុជអរាល,

ផរុសាយ វាចាយ វេរមណី វៀរពាក្យទ្រគោះឃ្នើសឃ្នង, *សម្ផប្បលាបា វេរមណី* វៀរពាក្យ ឥតប្រយោជន៍, យ៉ាងនេះហៅថា សម្មាវាចា ។

បុ. *សម្មាកម្មន្តោ* កាងារត្រូវ ដូចម្តេច ?

វិ. ការងារត្រូវគឺ *បាណាតិបាតា វេរមណី* វៀរបាណាតិបាត, *អទិន្នាទានា វេរមណី* វៀរអទិន្នាទាន, *កាមេសុ មិច្ឆាចារា វេរមណី* វៀរការប្រព្រឹត្តខុសក្នុងកាម, ហើយប្រព្រឹត្តធ្វើការកុសលដែលសម្រេចផ្លូវកាយ មានបោសច្រាសទិលានព្រះចេតិយជាដើម យ៉ាងនេះហៅថា សម្មាកម្មន្តោ ។

បុ. *សម្មាអាជីវោ* ចិញ្ចឹមជីវិតត្រូវ ដូចម្តេច ?

វិ. ចិញ្ចឹមជីវិតត្រូវ គឺលះមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុស (បើគ្រហស្ថលះជំនួញ ៥ ប្រការជាដើម បើអ្នកបួសលះអនេសនៈ ២១ និងបាបធមិ ៥) ហើយចិញ្ចឹមជីវិតដោយសម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវយ៉ាងនេះ ហៅថា សម្មាអាជីវោ ។

បុ. *សម្មាវាយាមោ* ព្យាយាមត្រូវដូចម្តេច ?

វិ. ព្យាយាមត្រូវ គឺញ្ចាំងឆន្ទៈឱ្យកើត ប្រារព្ធព្យាយាមផ្តងចិត្តឡើង ដើម្បីមិនឱ្យកើតអកុសលធមិដ៏លាមកដែលមិនទាន់កើតឡើង ដើម្បីលះបង់នូវអកុសលធមិដ៏លាមកដែលកើតឡើងហើយ, ដើម្បីញ្ចាំងកុសលធមិដែលមិនទាន់កើតឱ្យកើតឡើង និងដើម្បីញ្ចាំងកុសលធមិដែលកើតឡើងហើយឱ្យស្ថិតស្ថេរនៅ, ឱ្យចំរើនពេញលេញជាភិយ្យោភាពឡើង, យ៉ាងនេះហៅថា សម្មាវាយាមោ ។

បុ. *សម្មាសតិ* រលឹកត្រូវ ដូចម្តេច ?

វិ. រលឹកក្នុងសតិបដ្ឋានទាំង ៤ កំចាត់បង់អភិជ្ឈាទោមនស្សក្នុងលោក និងរលឹកដល់អនុស្សតិទាំង ១០ យ៉ាង នេះហៅថា សម្មាសតិ ។

បុ. *សម្មាសមាធិ* តម្កល់ចិត្តត្រូវ ដូចម្តេច ?

វិ. ភិក្ខុក្នុងសាសនានេះស្ងាត់ចាកកាម ចាកអកុសលធម៌ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កវិចារ មានបីតិ និងសុខ ដែលកើតអំពីវិវេក។ ដល់រំងាប់នូវវិតក្ក និងវិចារ ចូលកាន់ទុតិយជ្ឈាន ដែលមានសទ្ធាដ៏រងថ្កាផ្ទូរផង់តាំងនៅខាងក្នុង ជាគ្រឿងញ៉ាំងសមាធិចិត្តយ៉ាងឯកឱ្យកើតឡើង មិនមានវិតក្កវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ។ ជាអ្នកព្រងើយកន្តើយ ព្រោះខ្ពើមបីតិ មានស្មារតី មានប្រាជ្ញាដឹងសព្វ និងសោយសុខដោយកាយផង រួចចូលកាន់តតិយជ្ឈាន។ ចូលកាន់ចតុត្ថជ្ឈាន មានស្មារតី ដ៏ស្អាតដែលកើតអំពីឧបេក្ខា ឥតទុក្ខ ឥតសុខ ព្រោះលះបង់នូវទុក្ខ និងសុខផង ព្រោះអស្តង្គតរលត់ទៅនៃសោមនស្ស និងទោមនស្សអំពីមុនផង យ៉ាងនេះហៅថា សម្មាសមាធិ។

ប. អដ្ឋង្គិកមគ្គទាំង ៨ នេះ បើសង្គ្រោះចូលក្នុងកម្មទាំង ៣ គឺ កាយកម្ម វចីកម្ម និងមនោកម្ម **ពើអង្គណាសង្គ្រោះចូលក្នុងកម្មណា ?**

វិ. *សម្មាវាចា* សង្គ្រោះចូលក្នុង**វចីកម្ម**, *សម្មាកម្មន្តោ* ចូលក្នុងកាយកម្ម, *សម្មាអាជីវោ* ចូលក្នុងកាយកម្មផង **វចីកម្ម**ផង, *សម្មាទិដ្ឋិ*, *សម្មាសង្កប្បោ*, *សម្មាវាយាមោ*, *សម្មាសតិ* និង *សម្មាសមាធិ* **សង្គ្រោះចូលក្នុងមនោកម្ម**។

ប. ចុះបើចាត់ចូលក្នុងខន្ធទាំងបី គឺ **សីលក្ខន្ធ** សមាធិក្ខន្ធ និងបញ្ញាខន្ធវិញ **អង្គណាសង្គ្រោះចូលក្នុងខន្ធណា ?**

វិ. *សម្មាទិដ្ឋិ* និង *សម្មាសង្កប្បោ* សង្គ្រោះចូលក្នុងបញ្ញាខន្ធ, *សម្មាវាចា*, *សម្មាកម្មន្តោ* និង *សម្មាអាជីវោ* **សង្គ្រោះចូលក្នុងសីលក្ខន្ធ**, *សម្មាវាយាមោ*, *សម្មាសតិ* និង *សម្មាសមាធិ* **សង្គ្រោះចូលក្នុងសមាធិក្ខន្ធ**។

ប. ក្នុងអដ្ឋង្គិកមគ្គនេះ ហេតុអ្វីបានជាចាត់បញ្ញាទុកខាងដើម សីលនៅកណ្តាល, សមាធិនៅខាងចុង ; រួចក្នុងត្រៃសិក្ខា បែរជាចាត់សីលទុកខាងដើម, សមាធិនៅកណ្តាល, បញ្ញានៅខាងចុងវិញ ?

វិ. ក្នុងអដ្ឋង្គិកមគ្គនេះ បានជាចាត់បញ្ញាទុកជាខាងដើម ព្រោះបញ្ញាក្នុងអដ្ឋង្គិកមគ្គនេះគ្រាន់តែជាបញ្ញាអមផង ព្រោះក្នុងអដ្ឋង្គិកមគ្គ លើកសមាធិជាធំ ធម៌ ៧ ខាងដើមជាបរិក្ខារបស់សមាធិ, ឯក្នុងត្រៃសិក្ខា លោកចាត់សមាធិជាហេតុ បញ្ញាជាផល ។ ហេតុនិងផល រមែងផ្លាស់ប្តូរគ្នាបាន កាលបញ្ញានៅខ្ចី បញ្ញាជាហេតុ សមាធិជាផល ដល់បញ្ញាចាស់ក្លា បញ្ញាជាផល សមាធិជាហេតុវិញ ដូចក្នុងអដ្ឋង្គិកមគ្គ ទុកសម្មាទិដ្ឋិជាខាងដើម ព្រោះឃើញត្រូវហើយទើបរក្សាសីល ទើបធ្វើសមាធិខាងក្រោយ បានជាថាសមាធិជាហេតុ ; លុះដល់ចំណែនសមាធិចិត្តចាស់ក្លា ទើបចំណែនវិបស្សនាជាខាងក្រោយ វិបស្សនាបញ្ញាកើតមកពីសមាធិ សមាធិកើតមកពីសីល សីលកើតមកពីបញ្ញាដែលឃើញត្រូវពីខាងដើម ឧបមាដូចអ្នកដាំដើមឈើ មុនដំបូងយកផ្លែទៅដាំដុះមកបានជាដើម ត្រូវធ្វើរបងព័ទ្ធជុំវិញ ហើយស្រោចទឹក ឈើក៏លូតលាស់ធំឡើង មានផ្លែ បានឈ្មោះថាផ្លែកើតមកពីដើម ។ ដើមកើតមកពីពូជ ។ ក្នុងអដ្ឋង្គិកមគ្គទាំង ៨ នោះ សម្មាទិដ្ឋិ សម្មាសង្កប្បោ ជាពូជ, សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ជារបង, សម្មាវាយាមោ សម្មាសតិ ទាំងពីរជាទឹកសម្រាប់ស្រោច, សម្មាសមាធិ ជាតួដើម, ផ្លែគឺវិបស្សនាបញ្ញា ។ ព្រោះហេតុនេះបានជាថា ហេតុ និងផលផ្លាស់ប្តូរគ្នាទៅវិញទៅមកបាន ។

បុ. មគ្គនោះ ប្រែដូចម្តេច ?

វិ. ប្រែថា ផ្លូវជាទីទៅកាន់ព្រះនិព្វាន ឬថា សភាវៈសម្លាប់កិលេសបណ្តើរទៅបណ្តើរ ដូចវិគ្គហៈថា *កិលេសេ មារេន្តោ គច្ឆតីតិ > មគ្គោ* សភាវៈឯណាសម្លាប់កិលេសបណ្តើរ ទៅបណ្តើរ សភាវៈនោះហៅថាមគ្គ ។

បុ. មគ្គដែលលះកិលេសនោះ តើលះកិលេសជាអតីតៈ ឬអនាគត ឬបច្ចុប្បន្ន ?

វិ. កិលេសអតីតក៏មិនលះ អនាគតក៏មិនលះ ជាបច្ចុប្បន្នក៏មិនលះ ។

បុ. បើកិលេសជាអតីត អនាគត បច្ចុប្បន្នមិនលះទេ បើដូច្នោះ មគ្ត-ភាវនា (ការចំរើនន្ធវមគ្ត) មិនអត់ប្រយោជន៍ទៅហើយឬ ?

វិ. មិនមែនឥតប្រយោជន៍ទេ ព្រោះកិលេសដែលកន្លងទៅហើយក្តី ដែលមិនទាន់មានក្តី ដែលជាបច្ចុប្បន្នក្តី មិត្រូវមគ្តលះទេ ; ដែលមគ្តត្រូវលះនោះ គឺលះតែហេតុនិងបច្ច័យរបស់កិលេសទាំងឡាយនោះទេតើ ឧបមាដូចដើមឈើ ដែលទើបដុះ នៅមិនទាន់មានផ្លែនៅឡើយ បើគេប្រាថ្នានឹងកាប់មិនឱ្យដុះលូតលាស់ តទៅទៀត គេមិនកាប់ពូជផ្លែពីដើម ឬផ្លែដែលមិនទាន់មាន ឬដើមដែលទើបនឹងដុះថ្មីនោះទេ គេតែងជីករំលើងឫសចោល ទើបបានមិនដុះឡើងទៀត ។ មគ្តភាវនា ទុកដូចជាអ្នកកាប់ឈើ ផ្លែដែលជាពូជទុកដូចជាកិលេសជាអតីត ផ្លែដែលមិនទាន់មានមក ទុកដូចជាកិលេសជាអនាគត ដើមឈើដែលទើបនឹងដុះឡើងថ្មីនោះ ទុកដូចជាខន្ធ ៥ ឫសទុកដូចជាហេតុនៃកិលេស បើលះកិលេសដែលជាហេតុបានហើយ កិលេសទាំងអស់នោះ ក៏សាបសូន្យទៅឯង ដូចដើមឈើ ដែលគេគាស់រំលើងនោះដែរ ។

បុ. មគ្តនោះ តើមានប៉ុន្មានយ៉ាង ?

វិ. មាន ៤ យ៉ាងគឺ *សោតាបត្តិមគ្ត ១ សកទាគាមិមគ្ត ១ អនាគាមិមគ្ត ១ អរហត្តមគ្ត ១* ។

បុ. ចុះផល មានប៉ុន្មានយ៉ាង ?

វិ. មាន ៤ យ៉ាងដែរគឺ *សោតាបត្តិផល ១ សកទាគាមិផល ១ អនាគា-មិផល ១ អរហត្តផល ១* ។

បុ. មគ្តសម្រាប់លះកិលេស, ចុះផលសម្រាប់លះអ្វីដែរ ?

. វិ. ផលមិនត្រូវមុខការលះអ្វីទេ គ្រាន់តែសម្រាប់សោយសេចក្តីសុខប៉ុណ្ណោះ ប្រៀបដូចមនុស្សមានរោគ ដល់ពេលដែលជារោគបានសេចក្តីសុខហើយ មិនត្រូវដាក់ថ្នាំទៀតទេ កិលេសទុកដូចរោគ មគ្គទុកដូចថ្នាំ ការដែលជារោគបានសេចក្តីសុខទុកដូចផល ព្រោះហេតុនោះបានជា ផលមិនត្រូវលះកិលេសទៀត សម្រាប់តែសោយសេចក្តីសុខប៉ុណ្ណោះ ។

ប្. លោកុត្តរធម៌ ប្រែថា ធម៌ជាគ្រឿងឆ្លងចាកលោកទាំង ៣ គឺកាម. លោក រូបលោក និងអរូបលោក ; ចុះហេតុអ្វី ដូចជាលោកដែលបានលោកុត្តរធម៌ គឺ សោតា, សកទាគា, អនាគា ហើយក៏នៅកើតក្នុងលោកទៀត ? បើដូច្នោះ ពាក្យដែលថាឆ្លងចាកលោកមិនខុសទៅហើយឬ ?

វិ. មិនខុសទេ ព្រោះលោកុត្តរធម៌នោះជាគ្រឿងឆ្លងចាកលោកពិតមែន ដូចជាមគ្គដែលលះកិលេសឯណាបានហើយ កិលេសនោះមិនដែលត្រឡប់មកនាំសត្វឱ្យកើតទៀតទេ ឯលោកដែលនៅកើតទៀតនោះ កើតដោយអំណាចធម៌ជាលោកិយទេតើ លោកបានលោកុត្តរធម៌មែន ប៉ុន្តែលោកុត្តរធម៌នោះ លះកិលេសមិនទាន់អស់ កិលេសដែលសេសសល់ទាំងអម្បាលម៉ានោះឯង ដែលនាំឱ្យលោកកើតទៀត ។ កុសលាកុសលធម៌ដែលតែងនាំសត្វឱ្យកើត ដូចអកុសលចិត្ត ១២ នាំសត្វឱ្យកើតក្នុងអបាយភូមិ ៤, មហាកុសល ៨ នាំសត្វឱ្យកើតក្នុងស្ថានសួគ៌ ៦ ជាន់ និងមនុស្សលោក, រូបាវចរកុសល ៥ នាំសត្វឱ្យកើតក្នុងរូបព្រហ្ម, អរូបាវចរកុសល ៤ នាំសត្វឱ្យកើតក្នុងអរូបព្រហ្ម ឯលោកុត្តរចិត្ត ៨ មិននាំសត្វឱ្យបដិសន្ធិ ក្នុងស្ថានណានីមួយឡើយ ព្រោះហេតុនោះបានជាថាឆ្លងចាកលោកមិនកើតទៀត ចំពោះព្រះសោតាបន្ន សកទាគាមី អនាគាមី ដែលលោកនៅកើតទៀតនោះ គឺលោកកើតដោយលោកិយធម៌ទេតើ ឯលោកុត្តរធម៌គ្រាន់តែជាកំរែជួយរាំងមិនឱ្យទៅកាន់ទីទាប ប៉ុណ្ណោះទេ ។

បុ. និព្វាន ប្រែដូចម្តេច ?

វិ. ប្រែថា ធម្មជាតិចេញផុតអំពីកិលេសជាគ្រឿងរឹតរុំសត្វ ឬថាធម្មជាតិជាទីរលត់ភ្លើងកិលេស និងភ្លើងទុក្ខ ។

ភ្លើងកិលេសនោះបានដល់រាគៈ ទោសៈ មោហៈ ព្រោះកើតឡើងមួយអន្លើដោយចិត្ត ធ្វើចិត្តឱ្យល្អក់កករ ឱ្យក្តៅក្រហាយអន្ទះអន្ទែង ។ ភ្លើងទុក្ខបានដល់ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ព្រោះជាហេតុនៃសេចក្តីទុក្ខ និងតួទុក្ខ តែងចំពក់សត្វឱ្យក្តៅក្រហាយ ដូចជាគំនរភ្លើង ។

មានតែព្រះនិព្វានម៉្យាងដែលជាគ្រឿងរំលត់ភ្លើងទាំងនេះបាន ព្រោះភ្លើងទាំងនេះមិនមាននៅក្នុងព្រះនិព្វាន ។ ព្រះនិព្វានជាគ្រឿងរំងាប់នូវសង្ខារទាំងពួង មិនមានឧបធិក្កិលេស ជាទីក្សីណាស្អា ។ ព្រះនិព្វានមិនមែនជាដី មិនមែនជាភ្លើង មិនមែនជាខ្យល់ មិនមែនជាអាកាសានញ្ចាយតនៈ មិនមែនជាវិញ្ញាណញ្ចាយតនៈ មិនមែនអាកិញ្ចញ្ញាយតនៈ មិនមែននេវសញ្ញានាសញ្ញាយតនៈ មិនមែនជាលោកនេះ មិនមែនលោកខាងមុខ មិនមែនព្រះអាទិត្យព្រះចន្ទ ។ ព្រះនិព្វានមិនមានដំណើរមកអំពីភូមិនោះដល់ភូមិនេះ មិនមានដំណើរទៅអំពីភូមិនេះដល់ភូមិដទៃ មិនមានកិរិយាឈប់នៅ មិនមានចុតិ មិនមានបដិសន្ធិ មិនមានទីប្រតិស្ឋានតាំងនៅក្នុងតំបន់ណាឡើយ ។

បុ. សភាវៈទាំងពួងដែលបានពោលមកហើយទាំងប៉ុន្មាន ថាសុទ្ធតែមិនមែនព្រះនិព្វានទាំងអស់ បើដូច្នេះមានតែព្រះនិព្វានសូន្យទេដឹង ?

វិ. មិនមែនដូច្នោះទេ ព្រះនិព្វានមានពិត តែជាធម្មជាតិល្អិតសុខុមណាស់ ព្រះអរិយៈទាំងឡាយតែងឃើញច្បាស់ដោយបញ្ញាចក្ខុ គឺអរិយមគ្គញ្ញាណ ព្រោះហេតុនោះបានជាព្រះនិព្វានជាអសាធារណៈមិនទូទៅ គឺមិនប្រាកដដល់បុថុជ្ជនផង ។

បុ. បើព្រះនិព្វានមានមែន តើស្ថិតនៅក្នុងទីណា ? ជិត ឬឆ្ងាយ ?

វិ. ព្រះនិព្វានជារូបធម៌ មិនមែនមានទីកន្លែងសម្រាប់ស្ថិតនៅដូចជារបស់ទាំងពួងដែលមានរូបទេ, ព្រះនិព្វាន ថាស្ថិតនៅជិតក៏ថាបាន ថាឆ្ងាយក៏ថាបាន, ដែលថាជិត គឺសំដៅត្រង់អស់រាគៈ ទោសៈ មោហៈ ត្រង់ណា ព្រះនិព្វាននៅត្រង់នោះ ដែលថាឆ្ងាយ គឺព្រះនិព្វានប្រតិស្ឋាននៅត្រង់ចំពីចំផុតលោកទាំង ៣ គឺ កាមលោក, រូបលោក អរូបលោក ។

បុ. ព្រះនិព្វានជាធម្មជាតិឥតរូបទេ ចុះដែលស្ថិតនៅនោះ តើមានអ្វីទ្រទ្រង់ ?

វិ. មានធម្មាយតនៈជាគ្រឿងទ្រទ្រង់ ព្រោះព្រះនិព្វាន និងធម្មាយតនៈ ជារូបធម៌ដូចគ្នា បានជារាចទ្រទ្រង់បាន ប្រៀបឧបមាដូចជាផ្សែងដែលជារបស់មានរូបល្អិតចាប់ផ្តុំមិនបាន តែគង់ស្ថិតនៅឰដ៏អាកាស ដែលជារបស់មានរូបល្អិតចាប់ផ្តុំមិនបានដូចគ្នាបាន យ៉ាងណា ព្រះនិព្វានក៏ស្ថិតនៅត្រង់នោះដែរ ។

ព្រះនិព្វាននេះប្រាកដជាមានមែន ដូចជាប្រទេសដែលមានផ្លូវដើរ នៅទីចំផុតរបស់ផ្លូវនោះ តែងមានស្រុកភូមិ យ៉ាងណា ព្រះនិព្វានក៏មានអដ្ឋង្គិកមគ្គជាផ្លូវ ឯទីចំផុតផ្លូវគឺព្រះនិព្វាន យ៉ាងនោះដែរ ។

បុ. ចុះព្រះនិព្វាន នៅមានសល់ធម្មជាតិអ្វីដែរឬ ?

វិ. មាននៅសល់ផលញ្ញាណតែម្យ៉ាង ។

បុ. ផលញ្ញាណនោះ តើបានមកពីណា ?

វិ. បានមកពីការពិចារណាខន្ធ ៥ ដោយវិបស្សនាញ្ញាណទាំង ១០ ឧបមាដូចជាតិដូងទុំ បើទុកយូរទៅវាស្អុយ បើយកទៅដាំវាដុះទៀត បើគេមិនចង់ឱ្យស្អុយ មិនចង់ឱ្យដុះឡើងទៀត គេយកទៅចម្រាញ់ធ្វើជាប្រេង ដាំក៏មិនដុះ ទុកក៏មិនស្អុយ យ៉ាងណា ព្រះនិព្វានដែលចម្រាញ់មកពីវិបស្សនាញ្ញាណ ក៏មិនមែនសូន្យទទេ ហើយមិនមានពួជតទៅទៀត យ៉ាងនោះដែរ ។

បុ. ពួកបុថុជ្ជន ហេតុអ្វីបានជាមើលព្រះនិព្វានមិនឃើញ ?

វិ. បានជាមើលមិនឃើញ ព្រោះរាគៈ ទោសៈ មោហៈ បិទបាំង ដូចជាបុគ្គលមានធូលីនៅក្នុងភ្នែក រមែងមើលវត្ថុសខ្មៅជាដើម មិនឃើញ ។

បុ. ព្រះនិព្វានជាសុខតែម្យ៉ាង ឬក៏ច្រឡំដោយទុក្ខដែរ ?

វិ. ជាសុខតែម្យ៉ាង ហៅថា *ឯកន្តបរមសុខ* មិនមែនលាយឡំដោយទុក្ខផងឡើយ ។

បុ. បើព្រះនិព្វានមានពិតហើយ ជាឯកន្តបរមសុខមែន រូបសណ្ឋាន ឬរូបប្រមាណនៃព្រះនិព្វាននោះ គេអាចសំដែងឧបមាដោយហេតុ ដោយបច្ច័យ ឬក៏ដោយន័យឯណាមួយបានដែរឬ ?

វិ. មិនអាចឧបមាដោយហេតុបច្ច័យ ឬក៏ដោយន័យឯណាមួយបានទេ ពិតជាមានមែន ប៉ុន្តែ ល្អិតសុខុមហួសវិស័យនឹងឧបមាកើត ដូចជាមហាសមុទ្រក្នុងលោកនេះមានមែន ប៉ុន្តែគេមិនអាចរាប់ទឹក និងសត្វក្នុងមហាសមុទ្រនោះបាន ព្រោះហួសវិស័យនឹងរាប់ បើពុំនោះ ដូចអរូបកាយិកទេវតា ពិតជាមានមែន ប៉ុន្តែគេមិនអាចនឹងសំដែងប្រៀបធៀបថាមានរូបភាពយ៉ាងនេះយ៉ាងនោះបាន ។

បុ. ព្រះនិព្វានគ្មានអ្នកណាអាចសំដែងរូបជាដើម ដោយសេចក្តីឧបមាបានពិតមែនហើយ ចុះគុណនៃព្រះនិព្វាន បើសំដែងធ្វើបដោយសភាវៈដទៃបានដែរឬ ?

វិ. បើគ្រាន់តែសំដែងធ្វើបបាន តែឱ្យចោះចំពោះចំ។ តាមធម្មតារបស់ខ្លួនមិនបានទេ, មានសេចក្តីប្រៀបធៀបច្រើនអំពីព្រះនិព្វាន មានដើមថា ដំណក់ទឹកដក់នៅលើស្លឹកឈូកមិនបាន យ៉ាងណា កិលេសទាំងឡាយ ក៏តាំងនៅក្នុងព្រះនិព្វានមិនបាន យ៉ាងនោះដែរ, ទឹកជារបស់ត្រជាក់ សម្រាប់រំងាប់បង់នូវសេចក្តីក្រវល់ក្រវាយយ៉ាងណា ព្រះនិព្វានក៏ជាធម្មជាតិរំងាប់បង់នូវសេចក្តីក្រវល់ក្រវាយ គឺកិលេសយ៉ាងនោះដែរ ទឹកជារបស់បំបាត់បង់នូវសេចក្តីលំបាកព្រោះស្រេកទឹកនៃ

មនុស្ស និងសត្វទាំងឡាយ ដែលដើរទៅក្នុងទីមានកំដៅយ៉ាងណា ព្រះនិព្វានក៏បំបាត់ បង់នូវសេចក្តីលំបាក ពោលគឺ កាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា យ៉ាងនោះដែរ ។

បុ. ចុះព្រះនិព្វានមានលក្ខណៈ ដូចម្តេច ?

វិ. *តយិទំ សន្តិលក្ខណំ* ព្រះនិព្វានមានលក្ខណៈរំងាប់បង់នូវលោភៈ ទោសៈ មោហៈ រំងាប់បង់នូវអវិជ្ជា និងតណ្ហា រំងាប់បង់នូវសង្ក្លិលេសធមិទាំងពួង ដែលធ្វើឱ្យសៅហ្មង រិលស្លាប់ រិលកើតក្នុងវដ្តសង្សារ ។

បុ. ព្រះនិព្វានមានកិច្ច ដូចម្តេច ?

វិ. *អចុតិរសំ* មានកិច្ចមិនចុតិ មិនលុះក្នុងអំណាចនៃសង្ខតធមិទាំងឡាយគឺ នាមនិងរូបដែលជាកុសល និងអកុសល ដែលប្រជុំតាក់តែងឱ្យកើត ឱ្យបែកធ្លាយ ព្រះនិព្វាននេះជាធមិទៀង មិនចេះកើត មិនចេះបែកធ្លាយ ព្រោះផុតពីកណ្តាប់ដៃនៃសង្ខតធមិ ហេតុនេះ កិរិយាដែលមិនចេះចុតិនេះ ជាកិច្ចរបស់ព្រះនិព្វាន ។ *អស្សាសករសំវា* ម្យ៉ាងទៀតថា ព្រះនិព្វានមានកិច្ចធ្វើឱ្យព្រះសន្តាននៃព្រះអរិយៈ បុគ្គលរីករាយសោមនស្ស អធិប្បាយតាមពាក្យព្រះដីកាចារ្យថា ព្រះនិព្វាននេះមានអាការហាក់ដូចជានឹងប្រលោមយកចិត្តរបស់ព្រះអរិយៈដែលមានសន្តានន្រឿយ ណាយចាកសង្សារទុក្ខ ឱ្យប្រកបដោយសេចក្តីក្សេមក្សាន្ត ឱ្យប្រាសចាកទុក្ខ ចាកក្តៅក្រហាយ ឱ្យមានសេចក្តីត្រជាក់នៅក្នុងសន្តានចិត្ត ។

បុ. ព្រះនិព្វានមានអ្វីជាផល ?

វិ. *អនិមិត្តប្បច្ចុប្បដ្ឋានំ* ព្រះនិព្វានមានសភាវៈប្រាសចាកសង្ខតនិមិត្ត ជាផល ។ ម្យ៉ាងទៀតថា *និប្បបញ្ចប្បច្ចុប្បដ្ឋានំ* ព្រះនិព្វានមានសភាវៈជាហេតុឱ្យរំងាប់នូវបបញ្ចធមិ មានកាមរាគៈជាដើមជាផល អធិប្បាយថា សង្ខតនិមិត្ត គឺកុសល និងអកុសល ដែលជាហេតុបច្ច័យប្រជុំតាក់តែងនាម និងរូបឱ្យវិលឧបត្តិកើតក្នុងភពទាំង ៣ គឺ កាមភព រូបភព អរូបភព នោះមិនមានក្នុងព្រះនិព្វាន, បបញ្ចធមិទាំងពួង

មានរាគៈបបញ្ចជាដើម ដែលធ្វើឱ្យសត្វទាំងឡាយយឺតយូរវារង់នៅក្នុងវដ្តសង្សារ ក៏មិនមានក្នុងព្រះនិព្វាន ។ ព្រះនិព្វាននេះជាបច្ច័យឱ្យរំលត់បាននូវរាគាទិបបញ្ចធម៌ ហេតុដូច្នោះទើបថាព្រះនិព្វានធម៌នោះ មានសភាវៈប្រាសចាកសង្ខតនិមិត្តជាផល ឬ មានសភាវៈជាហេតុឱ្យស្ងប់រំងាប់នូវបបញ្ចធម៌ មានរាគៈជាដើមជាផល ។

ប. គុណរបស់ព្រះនិព្វានមានប៉ុន្មានយ៉ាង អ្វីខ្លះ ?

ឆ. មាន ៣២ គឺ *អជាតិ* ព្រះនិព្វានមិនមានកំណើត, *អជរំ* ព្រះនិព្វានមិនមានសេចក្តីគ្រាំគ្រា *អព្យាធិ* ព្រះនិព្វានមិនមានព្យាធិ (ជំងឺតម្កាត់) *និព្ភយំ* ព្រះនិព្វានមិនមានភ័យ, *អសង្ខតំ* ព្រះនិព្វានគឺបច្ច័យតាក់តែងមិនបាន, *អវភិន្នំ* ព្រះនិព្វានចម្លាយនូវភព ៣ *សុខំ សីតំ* ព្រះនិព្វានជាសុខដ៏ត្រជាក់, *ខេមំ* ព្រះនិព្វានដ៏ក្សេម, *តាណំ* ព្រះនិព្វានជាទីពឹងដល់ព្រះអរិយៈ, *លេនំ* ព្រះនិព្វានជាទីពួនអំពីមច្ចុរាជ *និដ្ឋំ* ព្រះនិព្វានទៀង គឺមិនបានប្រែប្រួល, *អចលំ* ព្រះនិព្វានមិនបានកម្រើក, *ធុវសស្សតំ* ព្រះនិព្វានទៀងប្រាកដ, *អវដ្ដសារំ* ព្រះនិព្វានមានខ្លឹមសារមិនមានវិលត្រឡប់, *សុខមច្ចន្តំ* ព្រះនិព្វានញ៉ាំញីនូវសុខក្នុងមនុស្ស និងសុខក្នុងស្ថានសួគ៌, *ខុទ្ទមច្ចន្តំ* ព្រះនិព្វានញ៉ាំញីនូវសេចក្តីឃ្លានបាយ, *បិបាសញ្ញាវិនយំ* ព្រះនិព្វានបន្ទោបង់សេចក្តីស្រេកទឹក *អនាលយំ* ព្រះនិព្វានមិនមានអាល័យ, *សមុគ្ឃាដវដ្ដិទដ្ឋេសំ* ព្រះនិព្វានដកនូវទោសដែលជោកនៅក្នុងចិត្ត ដូចជាពិសពស់, *វិសង្ខារំ* ព្រះនិព្វានប្រាសចាកសង្ខារ គឺនាម និងរូប *វិវដ្ដំ* ព្រះនិព្វានប្រាសចាកទោសទាំងឡាយ *តណ្ហក្ខយំ* ព្រះនិព្វានជាទីក្ស័យនៃតណ្ហា *វិភវំ* ព្រះនិព្វានប្រាសចាកភពទាំង ៣, *វិរាគំ* ព្រះនិព្វានប្រាសចាករាគ, *វិតមោហំ* ព្រះនិព្វានប្រាសចាកមោហៈ, *និរោធំ* ព្រះនិព្វានរំលត់ទុក្ខទាំងពួង, *អនិមិត្តំ* ព្រះនិព្វានមិនមាននិមិត្ត, *សន្តភាវំ* ព្រះនិព្វានមានសភាព

រំងាប់កិលេស, *អរសាករំ* ព្រះនិព្វានមិនមានរសគីតណ្ហា, *អប្បសាសញ្ច* ព្រះនិព្វានលះចេញនូវសេចក្តីរីករាយនៃចិត្ត, *អមតំ* ព្រះនិព្វានមិនចេះស្លាប់, រួមទាំងអស់ត្រូវជាគុណនៃព្រះនិព្វាន ៣២ ប្រការ ។

ឯវំ លោកុត្តរធម្មាបិ ស្វាក្ខាតោ លោកុត្តរធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រពៃ, ដូចសេចក្តីដែលសំដែងមកនេះ ។

កែបទ « **សន្ទិដ្ឋិកោ** »

« សន្ទិដ្ឋិកោ » ប្រែដូចម្តេច ? អធិប្បាយយ៉ាងណា ?

ប្រែថា ធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង (បានដល់អរិយមគ្គ និងលោកុត្តរធម៌) ។

អធិប្បាយថា ព្រះអរិយបុគ្គលជាម្ចាស់លោកធ្វើកិលេសទាំងឡាយ មានរាគៈជាដើម ឱ្យអស់ពីសន្តានលោកហើយ ក៏ឃើញនូវអរិយមគ្គជាក់ច្បាស់ ដោយព្រះអង្គលោក គឺឃើញថា « បុគ្គលមានចិត្តដោយរាគៈ មានចិត្តត្រូវរាគៈគ្របសង្កត់ មានចិត្តជាកំណាន់របស់រាគៈ ជួនណាគិតដើម្បីបៀតបៀនខ្លួនឯង ជួនណាគិតដើម្បីបៀតបៀនអ្នកដទៃ ជួនណាគិតដើម្បីបៀតបៀនខ្លួនឯងផង ដើម្បីបៀតបៀនអ្នកដទៃផង រមែងសោយទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត » បើលះបង់រាគៈបានហើយ រមែងមិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ និងមិនគិតដើម្បីបៀតបៀនខ្លួនឯងផង អ្នកដទៃផង រមែងមិនសោយទុក្ខទោមនស្សដែលព្រប្រឹត្តទៅក្នុងចិត្តយ៉ាងនេះឯង ដែលឈ្មោះថាធម៌ីព្រះអរិយបុគ្គលឃើញច្បាស់ដោយព្រះអង្គលោក ។

ឯលោកុត្តរធមិទាំង ៩ ប្រការគឺ មគ្ត ៤ ផល ៤ និព្វាន ១ បើបុគ្តលណា បានត្រាស់ដឹងហើយ បុគ្តលនោះរមែងលះបង់នូវកិរិយាជឿអ្នកដទៃ ព្រោះលោកឃើញច្បាស់ដោយខ្លួនឯង ដោយបច្ចវេក្ខណញ្ញាណ ។

នីយមួយទៀត អរិយមគ្តដែលឈ្នះនូវកិលេសទាំងឡាយបានដោយសេចក្តីយល់ត្រូវ ដែលព្រះជាគ្រូទ្រង់សរសើរ ហៅថា សន្ទិដ្ឋិកោ ពិតដូច្នោះមែន ព្រះអរិយមគ្ត រមែងឈ្នះនូវកិលេសទាំងឡាយដោយសេចក្តីយល់ត្រូវ ដែលសម្បយុត្តដោយអរិយមគ្ត ដែលកើតជាហេតុនៃអរិយផល ដែលកើតជាអារម្មណ៍ នៃព្រះនិព្វាន ។

នីយមួយទៀត លោកុត្តរធមិគួរដល់កិរិយាឃើញ ហៅថា សន្ទិដ្ឋិកោ ព្រោះលោកុត្តរធមិ បុគ្តលតែងបានឃើញដោយភាវនាភិសមីយ និងសច្ឆិកិរិយាភិ-សមីយ ទើបបានឈ្មោះថា សន្ទិដ្ឋិកោ ។

កែបទ « អកាលិកោ »

បុ. បទថា « អកាលិកោ » ប្រែដូចម្តេច អធិប្បាយដូចម្តេច ?

វិ. ប្រែថា « ធមិមិនមានកាលវេលា » អធិប្បាយថា ព្រះធមិ គឺ អរិយ-មគ្តតែកើតឡើងហើយក្នុងសន្តាននៃបុគ្តលណា រមែងឱ្យផលក្នុងលំដាប់បន្ទាប់អំពីខ្លួនប្រព្រឹត្តនោះឯង មិនមានកាលវេលា គឺថា មិនឈប់បង្អង់រារង់នៅអស់ ៥ ថ្ងៃ ៧ ថ្ងៃ ,ឬក៏ត្រឹមតែមួយថ្ងៃ កន្លះថ្ងៃ ទើបឱ្យផលឡើយ ព្រោះជវនវារៈរបស់ចិត្តដែលសម្បយុត្តដោយមគ្តរលត់ហើយ ជវនវារៈនៃចិត្តដែលសម្បយុត្តដោយផលកើតឡើងក្នុងលំដាប់នោះ ឥតមានជវនវារៈនៃចិត្តដទៃកើតស្តាត់ក្នុងចន្លោះបានឡើយ ព្រោះហេតុនោះបានជាអរិយមគ្ត ឈ្មោះថា អកាលិកោ ជាធមិមិនមានកាលវេលា ឬថាជាធមិឱ្យនូវផលមិនរង់ចាំកាលវេលា ។

មិនអាចនឹងហៅអ្នកដទៃមកប្រាប់ថា អ្នកចូរមើលដូច្នេះ ដើម្បីញុំាងចិត្តគេឱ្យជ្រះថ្លា ដោយកិរិយាប្រកាសនូវមនុញ្ញភាពឡើយ ព្រោះមួត្រលាមកនោះ ជារបស់មិនស្អាត ត្រូវតែបិទបាំងដោយស្មៅ និងស្លឹកឈើជាដើម ។ ឯលោកុត្តរធម៌នេះ ជាធម្មជាតិមានពិតដោយសភាវៈ និងជាធម្មជាតិស្អាតបរិសុទ្ធដូចមណ្ឌលនៃព្រះចន្ទដ៏ពេញវង់ក្នុងអាកាសដែលប្រាសចាកមេឃវលាហកៈ ប្រការមួយសោត ស្អាតបរិសុទ្ធ ដូចជាជាតិនៃកែវមណីដែលគេតម្កល់ទុកក្នុងសំពត់កម្ពល ព្រោះហេតុនោះបានជាលោកុត្តរធម៌ឈ្មោះថា « ឯហិបស្សិកោ » គួរនឹងហៅអ្នកដទៃឱ្យចូលមកមើលផងបាន ។

កែបទ « ឱបនយិកោ »

បុ. បទថា « ឱបនយិកោ » ប្រែដូចម្តេច ? អធិប្បាយដូចម្តេច ?

វិ. ប្រែថា ធម៌គឺព្រះអរិយបុគ្គលគប្បីបង្ហោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ។ អធិប្បាយថា លោកុត្តរធម៌នោះ ព្រះអរិយបុគ្គលតែងបង្ហោនមកទុកក្នុងខ្លួន ដោយអំណាចភាវនា បើទុកជាភ្លើងឆេះផ្ទាំងសំពត់ក្តី ឆេះក្បាលក្តី ក៏មិនអើពើ ។ ពាក្យនេះ សំដៅយកលោកុត្តរធម៌ដែលជាសង្ខតៈនៅឡើយ ឯលោកុត្តរធម៌ជាអសង្ខតៈ ព្រះអរិយបុគ្គលបង្ហោនមកទុកក្នុងខ្លួនដោយចិត្ត គឺពាល់ត្រូវដោយអំណាចកិរិយាធ្វើឱ្យជាក់ច្បាស់ ។ ម៉្យាងទៀត ព្រះអរិយមគ្គដែលបង្ហោនទៅរកព្រះនិព្វាន ក៏ឈ្មោះថា « ឱបនយិកោ » ផល និងព្រះនិព្វាន ក៏ឈ្មោះថា « ឱបនយិកោ » ។

កែបទ « **បច្ចក្កំ វេទិតព្វោ វិញ្ញូហិ** »

បុ. បទថា « *បច្ចត្តំ វេទិតព្វោ វិញ្ញូហិ* » ប្រែដូចម្តេច ? អធិប្បាយដូចម្តេច ?

វិ. ប្រែថា ធម៌គឺវិញ្ញូជនទាំងឡាយ មានឧត្តរដិតញ្ញូជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ អធិប្បាយថា លោកុត្តរធម៌គឺព្រះអរិយបុគ្គលជាឧត្តរដិតញ្ញូ និងវិបច្ចិតញ្ញូ និងនេយ្យ ទាំង ៣ ជំពូកនេះ គប្បីឃើញច្បាស់ក្នុងខ្លួនថា មគ្គអញបានចំរើនហើយ ផលអញបានត្រាស់ដឹងហើយ ព្រះនិព្វានជាទីរំលត់ទុក្ខអញបានធ្វើឱ្យជាក់ច្បាស់ហើយ ហើយមគ្គដែលឧបជ្ឈាយ៍ចំរើនបានហើយ នឹងលះបង់នូវកិលេសនៃសទ្ធិវិហារិកដែលជាកូនសិស្សរបស់ខ្លួនផងក៏មិនបាន សទ្ធិវិហារិកសោត ក៏មិនបាននូវសុខសម្រាន្តដោយសារផលសមាបត្តិរបស់ឧបជ្ឈាយ៍នោះ និងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលឧបជ្ឈាយ៍នោះធ្វើឱ្យជាក់ច្បាស់ហើយក៏មិនបាន ព្រោះហេតុនោះ លោកុត្តរធម៌មិនគឺអ្នកដទៃឃើញបានផងឡើយ ដូចគ្រឿងប្រដាប់សិរសារបស់អ្នកដទៃ ជាធម៌គឺ វិញ្ញូជនដែលបាន គប្បីឃើញ គប្បីសោយក្នុងចិត្តរបស់ខ្លួនតែម្យ៉ាង មិនមែនជាវិស័យនៃពាលបុថុជ្ជន ព្រោះហេតុនោះបានជាថា « បច្ចត្តំ វេទិតព្វោ វិញ្ញូ ហិ » ជាធម៌ គឺអ្នកប្រាជ្ញវិសេសទាំងឡាយ គប្បីដឹងចំពោះខ្លួន ។

ឯគុណនៃព្រះធម៌មាន « សន្ទិដ្ឋិកោ » ជាដើម ដូចបានពណ៌នាមកនេះ សុទ្ធតែជាគុណនៃលោកុត្តរធម៌ជារបស់ខ្ពស់ ជាវិស័យនៃព្រះអរិយៈតែម្យ៉ាង មិនមែនជាវិស័យនៃបុថុជ្ជនឡើយ ។

ពណ៌នាមកអំពីធម្មរតនៈ ចប់ដោយសង្ខេប

ពណ៌នាអំពីសង្ឃរតនៈ

បន្ទាប់អំពីធម្មរតនៈមក នឹងពណ៌នានូវសង្ឃរតនៈ តទៅទៀត

បុ. ពាក្យថា « សង្ឃ » ប្រែដូចម្តេច ? មានប៉ុន្មាន ? មានគុណ ដូចម្តេច ?

វិ. ប្រែថា « ពួក » ចែកចេញទៅមាន ២ គឺ :

១. *សម្មតិសង្ឃ*[1] ពួកភិក្ខុដែលសន្មតពីបួនរូបឡើងទៅ ដើម្បីធ្វើនូវ កម្មណាមួយ ។

២. *អរិយសង្ឃ* ពួកលោកដែលជាព្រះអរិយៈ បានតាំងនៅក្នុងមគ្ត និង ផល ។

សង្ឃ បើប្រែថា « ជិតគ្នា » ក៏បាន ព្រោះថា អរិយសង្ឃទាំងអម្បាល នោះ ទោះបីនៅឆ្ងាយពីគ្នា មួយអង្គប្រទេស ១ មួយអង្គប្រទេស ១ ផ្សេង១ពីគ្នា ឬ ខុសគ្នា ដោយជាតិ ក៏ឈ្មោះថា « ជិតគ្នា » គឺជិតដោយហេតុចុះរបៀបបែបផែន ដូចគ្នាត្រូវគ្នាដោយគុណ គឺសីល និងទិដ្ឋិ សេចក្តីយល់ឃើញបែប១គ្នា ។

ន័យមួយទៀត សង្ឃ ប្រែថា « អ្នកជីកកិលេស » ព្រោះលោកទាំង នោះ ជាអ្នកព្យាយាមជីករំលើងគាស់កកាយកិលេសទាំងឡាយ មានរាគៈជាដើមឱ្យ ផុតចេញពីខន្ធសន្តាន ។

ម្យ៉ាងទៀត ព្រះសង្ឃជាសាវ័កចែកជា ២ គឺ *បុថុជ្ជនសាវ័ក ១ អរិយ-សាវ័ក ១* ។ ពួកលោកដែលបានស្តាប់ឱវាទផ្ទាល់ អំពីព្រះឱស្ឋចំពោះព្រះភក្ត្រព្រះជា គ្រូ ឬក៏ស្តាប់អំពីសំណាក់សាវ័កដទៃនៃព្រះអង្គក្តី មិនបានត្រាស់ដឹងមគ្តផលទេ បាន

---

១. គុណសង្ឃនេះមានពិស្តារក្នុងវិនយបិដក ។

ត្រឹមតែសទ្ធាជឿគុណព្រះរតនត្រ័យ ស្ថិតនៅក្នុងសរណគមន៍ប៉ុណ្ណោះ បុគ្គលពួកនេះ ឈ្មោះថា « បុថុជ្ជនសាវ័ក » ។ ពួកលោកដែលស្តាប់ធម្មានុសាសនៈ ដែលព្រះជាគ្រូ ទ្រង់ប្រោសប្រទានសំដែងដោយព្រះអង្គឯងក្តី ឬ សាវ័កព្រះអង្គសំដែងក្តី ហើយបានលុះលោកុត្តរាភិសម័យ (មគ្គផល) ក្នុងខណៈដែលកំពុងតែស្តាប់នោះក្តី ឬប្រតិបត្តិតាមពាក្យប្រដៅនោះ ហើយបានលុះមគ្គផលក្នុងពេលមកខាងក្រោយក្តី បុគ្គលពួកនេះ ឈ្មោះថា « អរិយសាវ័ក » ។

ក៏ព្រះសង្ឃជាសាវ័កទាំងនោះលោកមានគុណច្រើន មានសុបដិបន្នោ ជាដើម ដូចសេចក្តីដែលមានសំដែងក្នុងខាងមុខនេះ ។

កែបទ « សុបដិបន្ថោ ភគវកោ សាវកសង្ឃោ »

បទនេះប្រែថា ពួកសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយ ប្រពៃ ។

បុ. លោកប្រតិបត្តិដូចម្តេច ទើបឈ្មោះថា « ប្រតិបត្តិដោយប្រពៃ » ?

វិ. លោកប្រតិបត្តិតាម សម្មាបដិបទា អនិវត្តិប្បដិបទា អនុលោមប្បដិ-បទា អបច្ចនីកប្បដិបទា និងធម្មានុធម្មប្បដិបទា ។

បុ. សេចក្តីប្រតិបត្តិដូចម្តេចដែលហៅថា « សម្មាបដិបទា » ?

វិ. សេចក្តីប្រតិបត្តិត្រូវល្អតាមគន្លងដំណើរព្រះនពលោកុត្តរធម៌ និងអដ្ឋង្គិកមគ្គ ដែលសង្ត្រោះដោយខន្ធ ៣ គឺ សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ ហៅថា « សម្មាបដិបទា » ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា « អនិវត្តិប្បដិបទា » ?

វិ. សេចក្តីប្រតិបត្តិមិនវិលត្រឡប់ គឺបុគ្គលអ្នកប្រតិបត្តិដល់ទីអរិយៈ ហើយ មិនវិលត្រឡប់មកជាបថុជ្ជនវិញ ហៅថា « អនិវត្តិប្បដិបទា » ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា « អនុលោមប្បដិបទា » ?

វិ. សេចក្តីប្រតិបត្តិជាអនុលោមដល់ព្រះនិព្វាន ហៅថា « អនុលោម-ប្បដិបទា » ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា « អបច្ចនីកប្បដិបទា » ?

វិ. សេចក្តីប្រតិបត្តិមិនជាសត្រូវ គឺមិនទំនាស់ដល់ព្រះនិព្វាន ហៅថា « អបច្ចនីកប្បដិបទា » ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា « ធម្មានុធម្មប្បដិបទា » ?

វិ. សេចក្តីប្រតិបត្តិតាមធម៌ ដ៏សមគួរដល់ធម៌ គឺប្រតិបត្តិសមគួរដល់ព្រះនិព្វាន ហៅថា « ធម្មានុធម្មប្បដិបទា » ។

ព្រះសង្ឃជាសាវ័ក លោកធ្វើដំណើរតាមសម្មាបដិបទា ដូចសំដែងមក នេះ ទើបឈ្មោះថា « សុបដិបន្នោ » ប្រតិបត្តិដោយប្រពៃ ។ បណ្ឌិតគប្បីជ្រាបថា លោកដែលតាំងនៅក្នុងមគ្គ ឈ្មោះថា « សុបដិបន្នោ » ប្រតិបត្តិដោយប្រពៃ ព្រោះលោកដល់ព្រមដោយសម្មាបដិបទា គឺមគ្គ, លោកដែលតាំងនៅក្នុងផល ក៏ឈ្មោះថា « សុបដិបន្នោ » ប្រតិបត្តិដោយប្រពៃដែរ, ដោយអាស្រ័យផ្លូវប្រតិបត្តិជាអតីត ព្រោះធម៌ដែលលោកគប្បីដល់ដោយសម្មាបដិបទានោះ លោកបានដល់ហើយ ។

ម្យ៉ាងទៀត ព្រះសង្ឃជាសាវ័កអ្នកប្រតិបត្តិតាមឱវាទដែលព្រះពុទ្ធជាម្ចាស់ប្រៀនប្រដៅ គឺធម៌វិន័យ ហើយនិងប្រតិបត្តិតាមអបណ្ណកប្បដិបទា គឺដំណើរសេចក្តីប្រតិបត្តិមិនខុស ឈ្មោះថា « សុបដិបន្នោ » ។ ម្យ៉ាងទៀត ដែលឈ្មោះថា

« សុបដិបន្នោ » ប្រតិបត្តិល្អនោះ គឺលោកតាំងទុកន្ទវសីលដូចជារបង ឬកំផែង សំរាប់ការពារសីកសត្រូវ គឺទុច្ចរិតកិលេសដែលជាអកុសលដ៏អាក្រក់ តែងកើតក្នុងកាយទ្វារ វចីទ្វារ លោកធ្វើសមាធិ បីដូចជាផែនសិលាដ៏ធំបិទបាំងន្ទវសត្រូវខាងក្នុង គឺ បរិយុដ្ឋានសំកិលេស ដែលជាអកុសលកើតឡើងគ្របសង្កត់ចិត្ត លោកធ្វើបញ្ញាដូចជាប្រទីបបំភ្លឺក្នុងសង្ខារទាំងពួងដោយចំណែក។ មានខន្ធជាដើម ឃើញច្បាស់ថាជាទុក្ខមិនមែនខ្លួន ហើយលោកធ្វើបញ្ញា ដូចជាសស្ត្រាវុធមានមុខដ៏មុតថ្លា ពិឃាតសម្លាប់អនុសយកិលេស ដែលជាចំណែកដ៏ល្អិតយ៉ាងទាបបំផុត បានត្រឹមសោតា. បន្នបុគ្គល អស់សក្កាយទិដ្ឋិ ដោយឃើញច្បាស់ថា បញ្ចក្ខន្ធមិនមែនខ្លួន អស់វិចិកិច្ឆាដោយឃើញគុណព្រះពុទ្ធជាក់ច្បាស់ ហើយលោកុត្តរធម៌ ក៏កើតឡើងប្រាកដក្នុងសន្តាន លុះលោកសំរេចជាព្រះអរិយៈហើយ ទើបរស់សីលពត្តបរាមាសៈ ព្រោះឃើញច្បាស់ថាខ្លួនបរិសុទ្ធដោយត្រៃសិក្ខា ដែលជាសម្មាបដិបទា ផ្លូវប្រតិបត្តិប្រពៃយ៉ាងនេះទើបឈ្មោះថា « សុបដិបន្នោ » ។

កែបទ « **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** »

បទនេះប្រែថា ពួកសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ។

បុ. លោកប្រតិបត្តដូចម្តេច ទើបឈ្មោះថា ប្រតិបត្តិត្រង់ ?

វិ. លោកប្រតិបត្តិត្រង់ មិនវៀច មិនកោង មិនល្បែង មិនឃ្វាង គឺជាដំណើរឆ្ពោះត្រង់ទៅរកព្រះនិព្វាន មិនពានពារទៅលើផ្លូវលាមក ២ ប្រការគឺ *កាម.សុខល្លិកានុយោគ* និង*អត្តកិលមថានុយោគ* ដែលជាផ្លូវប្រតិបត្តិខុស ជាដំណើរ

ឃ្វាងមិនចំព្រះនិព្វាន លោកតែងធ្វើដំណើរតាមមជ្ឈិមប្បដិបទា ដែលជាផ្លូវប្រតិបត្តិ យ៉ាងកណ្តាល ។ ម្យ៉ាងទៀត លោកប្រតិបត្តិត្រង់ដើម្បីលះបង់នូវទោស គឺសេចក្តីកោង ឃ្មើសឃ្មង ឆ្គងកាយ វាចា ចិត្ត ដូច្នេះទើបឈ្មោះថា « ឧជុបដិបន្នោ » ។

កែបទ « **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** »

បទនេះប្រែថា ពួកសាវ៉កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ។

បុ. លោកប្រតិបត្តិដូចម្តេច ឈ្មោះថាប្រតិបត្តិដើម្បីត្រាសដឹងនូវព្រះនិព្វាន ?

វិ. លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវសម្មាបដិបទា ដែលជាផ្លូវប្រតិបត្តិសំរាប់ដឹងច្បាស់ ចាក់ធ្លុះនូវព្រះនិព្វាន ដែលជាគន្លងតម្រាយរបស់ព្រះអរិយៈជាម្ចាស់ទាំងឡាយ លោកតែងយាត្រាទៅកាន់ព្រះនិព្វាន យ៉ាងនេះទើបឈ្មោះថា « ញាយ-បដិបន្នោ » ។ ម្យ៉ាងទៀត លោកប្រតិបត្តិដើម្បីចេញចាកសង្សារវដ្ត មិនប្រតិបត្តិដើម្បីលាភ និងយស និងសេចក្តីសរសើរក្នុងបច្ចុប្បន្ន ឬដើម្បីស្ថានសួគិឡើយ លោកប្រតិបត្តិដើម្បីចេញចាកសង្សារតែម្យ៉ាង យ៉ាងនេះទើបឈ្មោះថា « ញាយ-វដ្តសបដិបន្នោ » ។

កែបទ « សាមីចិបដិបន្នោ ភគវកោ សាវកសង្ឃោ »

បទនេះប្រែថា ពួកសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម ។

បុ. លោកប្រតិបត្តិដូចម្តេចទើបឈ្មោះថា « សមគួរដល់សាមីចិកម្ម » ?

វិ. លោកប្រតិបត្តិតាមសម្មាបដិបទា ដែលជាផ្លូវគួរដល់ព្រះនិព្វាន បានពត់កាយ វាចា ចិត្ត ដោយត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា សមរម្យគួរគេថ្វាយបង្គំនមស្សការ យ៉ាងនេះទើបឈ្មោះថា « សាមីចិបដិបន្នោ » ។

កែបទ « យធិធំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា »

បទនេះប្រែថា ព្រះសង្ឃដែលរាប់ជាគូនៃបុរសបុគ្គលមាន ៤ បើរាប់រាយរៀងជាបុគ្គលមាន ៨ ។

បុ. ដែលរាប់ជាគូ១ នោះតើរាប់ដូចម្តេច ? ដែលរាប់រាយរៀងតួនោះដូចម្តេច ?

វិ. រាប់ជាគូនោះដូច្នេះ គឺលោកដែលបានសម្រេចនូវសោតាបត្តិមគ្ត និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្ត និងសកទាគាមិផលជាគូ ១ អនាគាមិមគ្ត និងអនាមិផលជាគូ ១ អរហត្តមគ្ត និងអរហត្តផលជាគូ ១ ត្រូវជា ៤ គូ ។ រាប់រាយដូច្នេះ គឺ លោកដែលបានសម្រេចនូវសោតាបត្តិមគ្ត ១ សោតាបត្តិផល ១ សកទាគាមិមគ្ត ១ សកទាគាមិផល ១ អនាគាមិមគ្ត ១ អនាគាមិផល ១ អរហត្តមគ្ត ១ អរហត្តផល ១ ត្រូវជា ៨ ។

បុ. សោតាបន្នបុគ្គលដែលបានសម្រេចសោតាហើយ តើលះបានអកុសលចិត្តណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត ៤ វិចិកិច្ឆាសម្បយុត្ត ១ ជា ៥, លះបានសំយោជនៈ ៣ គឺសក្កាយទិដ្ឋិសំយោជនៈ ១ វិចិកិច្ឆាសំយោជនៈ ១ សីលពត្ត-បរាមាសសំយោជនៈ ១ ជា ៣, លះបានអនុស្សយ ២ គឺ ទិដ្ឋានុស្សយ ១ វិចិកិច្ឆា-នុស្សយ ១ ជា ២, លះបានកាមឆន្ទៈ និងព្យាបាទៈ ជាចំណែកគ្រោតគ្រាតដែលឱ្យកើតទុច្ចរិត ៣ ដែលជាអបាយគាមិ ។

បុ. បច្ចវេក្ខណៈ (ការពិចារណា) របស់សោតាបន្នបុគ្គល មានប៉ុន្មានយ៉ាង ?

វិ. មាន ៥ យ៉ាងគឺ *មគ្គំ បច្ចវេក្ខតិ* ព្រះសោតាបន្នបុគ្គលរមែងពិចារណានូវមគ្ត ១ *ផលំ បច្ចវេក្ខតិ* ពិចារណានូវផល ១ *បហីនក្កិលេសេ បច្ចវេក្ខតិ* ពិចារណានូវកិលេសដែលលោកលះបានហើយ ១ *អវសិដ្ឋកិលេសេ បច្ចវេក្ខតិ* ពិចារណានូវកិលេសដែលនៅសេសសល់ ១ *និព្វានំ បច្ចវេក្ខតិ* ពិចារណាមូវអមតមហានិព្វាន ១ រួមជាបច្ចវេក្ខណៈរបស់សោតាបន្នបុគ្គលមាន ៥ ។

បុ. សោតាបន្នបុគ្គលនោះ ចែកចេញជាប៉ុន្មានពួក ?

វិ. ចែកចេញជា ៣ ពួក[(១)] គឺ *ឯកពិជី ១ កោលំកោលៈ ១ សត្តក្ខត្តុំ-បរមៈ ១* ។ *ឯកពិជី* លោកដែលមានពួជគឺភពតែ ១ គឺនៅកើតក្នុងមនុស្សលោកតែ ១ ជាតិទៀត ហើយធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល លែងមានកំណើតទៅខាងមុខ

(១) ដែលសំដែងថា មាន ៣ ពួកនេះ សំដៅយកតែព្រះសោតាបន្នបុគ្គលដែលជាមិស្សកភាព គឺភាពច្រឡូកច្រឡំអន្ទោលទៅអន្ទោលមកក្នុងស្ថានមនុស្ស និងស្ថានទេព្តាប៉ុណ្ណោះទេ ឯសោតាបន្នបុគ្គលក្រៅពីនេះ ច្រើនពេកណាស់រាប់មិនអស់ឡើយ (បាលីអដ្ឋកថាអភិធម្ម) ។

ទៀត ។ *កោលំកោលៈ* លោកដែលទៅពីត្រកូល ១ ទៅកាន់ត្រកូល ១ ទៀត គឺ លោកដែលនៅកើត ២ ជាតិ ឬ ៣ ជាតិទៀត ទើបបានធ្វើឱ្យជាក់ច្បាស់នូវអរហត្ត-ផល ។ *សត្តក្ខត្តុំបរមៈ* លោកដែលត្រាច់រង្គាត់ទៅកើតក្នុងមនុស្សលោក និងទេវ-លោកយ៉ាងច្រើនបំផុតត្រឹម ៧ ជាតិទៀត ទើបបានធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល ដោយខន្ធបរិនិព្វានក្នុងជាតិជាគំរប់ ៧ ពិតប្រាកដ ។

បុ. ហេតុអ្វីបានជាសោតាបន្នបុគ្គលមានប្រភេទផ្សេងគ្នា អង្គខ្លះជា ឯកពិជី អង្គខ្លះជាសត្តក្ខត្តុំបរមៈ ?

ឆ. បានជាមានប្រភេទផ្សេងគ្នា ពីព្រោះមានវិបស្សនាផ្សេងគ្នា គឺ *ឯកពិជី* មានវិបស្សនាក្លៀវក្លាបំផុត, *កោលំកោលៈ* មានវិបស្សនាក្លៀវក្លាយ៉ាងកណ្តាល, *សត្តក្ខត្តុំបរមៈ* មានវិបស្សនាទន់បំផុត ។

បុ. សោតាបន្នបុគ្គលលោកចរិច្ចណិដោយធម៌អ្វី ?

ឆ. ចរិច្ចណិដោយសីល ។

បុ. សោតាបន្នបុគ្គលនោះ នៅមានចែកចេញទៅទៀតឬ ?

ឆ. មានចែកចេញទៀត បើចែកតាមឈ្មោះដើមមានតែ ៣ ដូចពោលមក ហើយ តែបើចែកតាមខណចិត្តដែលលះកិលេសបានផ្សេងគ្នាមាន ២៤ ដូច្នេះគឺ យក បដិបទា ៤ និងធុរៈ ២ មកគុណ, ឯកពិជី មានបដិបទា ៤ កោលំកោលៈ មានបដិបទា ៤ សត្តក្ខត្តុំបរមៈ មានបដិបទា ៤ រួមត្រូវជា ១២, ចែកជាសទ្ធាធុរៈ ១២ បញ្ញាធុរៈ ១២ បានជា ២៤ ។

បុ. សកទាគាមីបុគ្គល លះបានអកុសលចិត្តណាខ្លះ ?

ឆ. លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត ៤ ទោមនស្សសហគតចិត្ត ២ ជា ៦, លះបានសំយោជនៈ ២ គឺ កាមរាគសំយោជនៈ ១ ព្យាបាទសំយោជនៈ ១ ជា

២, លះបានអនុស័យ ២ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ ជា ២, លះរាគៈ ទោសៈ មោហៈ បានដោយស្រាលស្តើង ។ សកទាគាមិបុគ្គលនេះ រមែងមកកើតក្នុងកាមភពនេះម្តងទៀត ទើបធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលជាទីបំផុតនៃទុក្ខ ហើយទើបបានរំលត់ខន្ធចូលកាន់និព្វាន ។

ឯបច្ចវេក្ខណៈរបស់សកទាគាមិបុគ្គលក៏មាន ៥ ដូចសោតាបន្នបុគ្គលដែរ ហើយបរិបូណ៌ដោយសីលដូចគ្នា ។

បុ. សកទាគាមិបុគ្គល បើចែកតាមខណចិត្តដែលលះកិលេសបាន មានប៉ុន្មាន ?

វិ. មាន ១២ គឺ ក្នុងសកទាគាមិបុគ្គលមួយ១ មានវិមោក្ខ ៣ ក្នុងវិមោក្ខមួយ១ មានបដិបទា ៤, រួមត្រូវជា ១២ ។

បុ. អនាគាមិបុគ្គល លះបានអកុសលណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត ៤, ទោមនស្សសហគតចិត្ត ២ លះបានសំយោជនៈ ២ គឺ កាមរាគ ១ ព្យាបាទ ១ និងអនុស័យ ២ គឺកាមរាគានុស័យ ១ បដិឃានុស័យ ១ ដោយដាច់ស្រឡះ ។ ឯបច្ចវេក្ខណៈរបស់អនាគាមិបុគ្គលនេះ ក៏មាន ៥ ដូចសោតាបន្នបុគ្គលដែរ ។

បុ. អនាគាមិបុគ្គល ចែកជាប៉ុន្មានពួក ?

វិ. ចែកចេញជា ៥ ពួកគឺ *អន្តរបរិនិព្វាយី ១ ឧបហច្চបរិនិព្វាយី ១ អសង្ខារបរិនិព្វាយី ១ សសង្ខារបរិនិព្វាយី ១ ឧទ្ធំសោតោអកនិដ្ឋគាមី ១* ។

អន្តរបរិនិព្វាយី លោករំលត់ក្នុងចន្លោះ គឺលោកដែលកើតក្នុងសុទ្ធាវាស-ព្រហ្មលោក ហើយនៅមិនទាន់ដល់ពាក់កណ្តាលអាយុ ក៏ញុំាងអរហត្តមគ្គឱ្យកើតឡើង លះសំយោជនៈខាងលើបាន ។

ឧបហច្ចបរិនិព្វាយី លោកកន្លងពីថ្នាក់នោះបន្តិចទៅទៀត គឺលោកដែលមានអាយុជាងពាក់កណ្តាលឡើងទៅ ដល់កាលទៀបនឹងអស់អាយុ ទើបញុំាងអរហត្តមគ្គឱ្យកើតឡើង ដើម្បីលះសំយោជនៈខាងលើទាំង ៥ ។

អសង្ខារបរិនិព្វាយី រំលត់ដោយអសង្ខារ គឺលោកដែលញុំាងអរហត្តមគ្គឱ្យកើតឡើង លះសំយោជនៈទាំង ៥ ខាងលើបានងាយ មិនជាច់ប្រកបព្យាយាមតឹងតែងពេក ។

សសង្ខារបរិនិព្វាយី លោកជាអ្នករលត់ដោយសសង្ខារ គឺលោកដែលញុំាងអរហត្តមគ្គឱ្យកើតឡើងបានដោយកម្រ ទាល់តែប្រកបសេចក្តីព្យាយាមយ៉ាងធំ ។

ឧទ្ធំសោតោ អកនិដ្ឋគាមី លោកជាអ្នកមានខ្សែព្រួដ៏ខាងលើ ទៅកាន់ភព អកនិដ្ឋ គឺចុតិចាកព្រហ្មលោក ឈ្មោះអវិហា ហើយទៅកាន់អតប្បាព្រហ្មលោកទៀត លុះចុតិចាកអតប្បាព្រហ្មលោកហើយ ទៅកាន់សុទស្សាព្រហ្មលោកទៀត លុះចុតិចាកសុទស្សាព្រហ្មលោកហើយ ទៅកាន់សុទស្សីព្រហ្មលោកទៀត លុះចុតិចាកសុទស្សីព្រហ្មលោកហើយ ទៅកាន់អកនិដ្ឋព្រហ្មលោកទៀត ទើបញុំាងអរហត្តមគ្គឱ្យកើតឡើង លះសំយោជនៈខាងលើក្នុងព្រហ្មលោកនោះ រួមផងគ្នា ត្រូវជាអនាគាមិបុគ្គល ៥ ពួក ។ ក្នុងស្ថានអវិហា ៥ អតប្បា ៥ សុទស្សា ៥ សុទស្សី ៥ អកនិដ្ឋ ៤ លើកឧទ្ធំសោតៈមួយចេញ រួមជាអនាគាមិបុគ្គលមាន ២៤, គុណទៅទៀតជាសទ្ធាធុរៈ ២៤ បញ្ញាធុរៈ ២៤ ទើបបានជាអនាគាមិបុគ្គល ៤៨ ។

បុ. ព្រះអនាគាមិបុគ្គល លោកបរិបូណ៌ដោយធម៌អ្វី ?

វិ. លោកបរិបូណ៌ដោយសមាធិ ។

បុ. ព្រះអរហត្ត លះបានអកុសលចិត្តណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត ៤ ឧទ្ធច្ចសហគតចិត្ត ១ ជា ៥ លះបានសំយោជនៈគឺ រូបរាគ អរូបរាគ មានៈ ឧទ្ធច្ចៈ អវិជ្ជា និងមានានុស័យ រាគានុស័យ អវិជ្ជានុស័យ ដាច់ស្រឡះពីខន្ធសន្តាន ។

បុ. បច្ចវេក្ខណៈ (ការពិចារណា) របស់ព្រះអរហន្ត មានប៉ុន្មានយ៉ាង

វិ. មាន ៤ យ៉ាង គឺ *មគ្គំ បច្ចវេក្ខតិ* លោកពិចារណាន្ទវមគ្គ ១ *ផលំ បច្ចវេក្ខតិ* ពិចារណាន្ទវផល ១ *បហីនកិលេសេ បច្ចវេក្ខតិ* ពិចារណាន្ទវកិលេសដែលលោកលះបានហើយ ១ *និព្វានំ បច្ចវេក្ខតិ* ពិចារណាន្ទវព្រះនិព្វាន ១ រួមផងគ្នាត្រូវជា ៤ ។

បុ. អរហន្តនោះ ចែកជាប៉ុន្មានពួក ?

វិ. ចែកជា ៤ ពួកគឺ *សុក្ខវិបស្សកោ* លោកអ្នកមានវិបស្សនាដ៏រឹងស្ងួត ព្រោះមិនមានជ័រគឺសមថភាវនា បានចំរើនវិបស្សនាលុះដល់ព្រះអរហត្ត មិនប្រកបដោយឫទ្ធិវិសេសឯណាឡើយ មួយពួក, *តេវិជ្ជោ* លោកដែលបានវិជ្ជា ៣ មួយពួក , *ឆឡភិញ្ញោ* លោកដែលបានអភិញ្ញា ៦ មួយពួក, *បដិសម្ភិទប្បត្តោ* លោកដែលដល់បដិសម្ភិទា ៤ មួយពួក, ត្រូវជាព្រះអរហន្តមាន ៤ ពួក ។ ព្រះអរហន្តទាំង ៤ ពួកនេះ រួមមកជា ២ គឺ សុក្ខវិបស្សកៈ ១ ហើយនិងខាងចុង ៣ រួមមក ហៅថា សមថយានកៈ តែម្យ៉ាង ១ ។ ចាត់ទៅតាមវិមោក្ខ ៣ គឺក្នុងវិមោក្ខមួយ១ មានបដិបទាបួន១ រួមត្រូវជា ១២, ជាសុក្ខវិបស្សកៈ ១២ សមថយានកៈ ១២ ជាព្រះអរហន្ត ២៤ ។

បុ. ព្រះអរហន្ត លោកបរិបូណ៌ដោយធម៌អ្វីខ្លះ ?

វិ. លោកបរិបូណ៌ដោយបញ្ញា ។

រួមព្រះអរិយបុគ្គលទាំងអស់ត្រូវជា ១០៨ គឺ សោតាបន្នបុគ្គល ២៤, សកទាគាមី ១២, អនាគាមី ៤៨, អរហន្ត ២៤, សមនឹងពុទ្ធដីកា ព្រមទាំងអដ្ឋកថាថា *យេ បុគ្គលា អដ្ឋសតំ បសំដ្ឋាតិ ឥមិស្សា គាថាយ វណ្ណនាយំ អដ្ឋុត្តរសតំ*

អរិយា វុត្តា ។ ក៏ព្រះអរិយបុគ្គលទាំង ១០៨ នេះ ចែកជាមគ្គ ៥៤ ផល ៥៤ ត្រូវជា ព្រះអរិយបុគ្គល ១០៨ ដដែល ។

បុ. បដិបទាទាំង ៤ យ៉ាងនោះ គឺអ្វីខ្លះ ?

វិ. គឺ *ទុក្ខាបដិបទាទន្ធាភិញ្ញា* កាលប្រតិបត្តិលំបាក ដល់បានត្រាស់ដឹងក៏លំបាក ១ *សុខាបដិបទាទន្ធាភិញ្ញា* កាលប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរវិញ ១ *ទុក្ខាបដិបទាខិប្បាភិញ្ញា* កាលប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ១ *សុខាបដិបទា-ខិប្បាភិញ្ញា* កាលប្រតិបត្តិងាយ ត្រាស់ដឹងឆាបវិញ ១ ។

បុ. បដិបទាផ្សេងគ្នាដោយយឺតយូរ និងឆាប់រហ័សយ៉ាងនេះ ព្រោះហេតុអ្វី ?

វិ. ព្រោះបុគ្គលដែលប្រតិបត្តិនោះ មានឥន្ទ្រីយ និងកិលេសផ្សេងគ្នា គឺ :

១. បុគ្គលដែលប្រតិបត្តិយឺតយូរ ព្រោះកិលេសក្លៀវក្លាបានត្រាស់ដឹងយឺតយូរ ព្រោះឥន្ទ្រិយទន់ ប្រៀបឧបមាដូចជា អ្នកមានជំងឺជាទម្ងន់ដើរទៅផ្ទះគ្រូពេទ្យ ដំណើរដែលដើរទៅនោះ រមែងយឺតយូរ ព្រោះខ្លួនឈឺធ្ងន់ បានដល់ផ្ទះពេទ្យហើយ ទៅរកថ្នាំ ថ្នាំនោះក៏បានតិច ម្ជ៉ោះហើយជំងឺនោះក៏ទៅជាជាសះស្បើយបានដោយយឺតយូរ យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

២. ប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរ ព្រោះកិលេសតិច ឥន្ទ្រិយក៏ទន់ ឧបមាដូចអ្នកមានជំងឺស្រាល ដើរទៅរកផ្ទះពេទ្យឆាប់ដល់ តែព្យាបាលរោគយូរ ព្រោះមានថ្នាំតិច យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៣. ប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ព្រោះកិលេសក្លៀវក្លា ឥន្ទ្រីយក៏ក្លៀវក្លាដែរ ឧបមាដូចអ្នកមានជំងឺធ្ងន់ ដើរទៅរកផ្ទះពេទ្យយឺតយូរ តែបានសះជា

រោគឆាប់រហ័ស ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៤. ប្រតិបត្តិងាយ ត្រាស់ដឹងឆាប់ ព្រោះកិលេសទន់ ឥន្ទ្រិយក្លៀវក្លា ឧបមាដូចជាអ្នកមានជំងឺស្រាល ដើរទៅរកផ្ទះពេទ្យឆាប់ដល់ រក្សារោគក៏ឆាប់សះជា ព្រោះមានថ្នាំយ៉ាងច្រើន យ៉ាងណាមិញ សុខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

តួកិលេស ទុកដូចជារោគ ឥន្ទ្រិយទាំង ៥ ទុកដូចជាថ្នាំសម្រាប់កែរោគ ។ ម្យ៉ាងទៀត ឧបមាដូចបុរស ៤ នាក់ ស្វែងរកគោ, បុរសទី ១ ដើរទៅក្នុងព្រៃ ដល់វេលាឃើញគោ ក៏ឃើញក្នុងព្រៃ យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី ២ ដើរទៅរកគោតាមផ្លូវធ្លាស្រួល ដល់ឃើញគោ បែរជាឃើញក្នុងព្រៃវិញ យ៉ាងណាមិញ សុខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី ៣ ស្វែងរកគោដើរកាត់ព្រៃ ដល់ឃើញគោ បែរជាទៅឃើញក្នុងទីវាលវិញ យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី ៤ ដើរទៅរកគោតាមផ្លូវធ្លា ដល់ឃើញគោ ក៏ឃើញក្នុងទីវាល យ៉ាងណាមិញ សុខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

បុរស គឺយោគាវចរកុលបុត្រដែលស្វែងរកអរិយមគ្គ, គោ គឺអរិយមគ្គ, ព្រៃ គឺកិលេស ផ្លូវធ្លា គឺកិលេសដ៏ស្តើង ។ បុគ្គលដែលបានមគ្គផលផ្សេងគ្នា ព្រោះប្រតិបត្តិខុសគ្នា ដូចសំដែងមកនេះ ។

ប្រែបទ « **ឯស ភគវតោ សាវកសង្ឃោ** »

បទនេះប្រែថា ព្រះសង្ឃដែលបានពណ៌នាមកទាំងអម្បាលនេះនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ។

កែបទ « **អាហុណេយ្យោ** »

បទថា « អាហុណេយ្យោ » ប្រែថា លោកគួរទទួលន្ទវចតុប្បច្ច័យដែលបុគ្គលនាំមកបូជា ។

អធិប្បាយថា បច្ច័យទាំង ៤ ប្រការ មានចីវរប្បច្ច័យជាដើម ដែលបុគ្គលនាំមកអំពីចិដចីឆ្ងាយ ដើម្បីបូជាដល់បុគ្គលមានសីលទាំងឡាយ ។ បច្ច័យទាំងនោះ ព្រះសង្ឃជាសាវ័ក លោកគួរទទួលបាន ព្រោះលោកអាចធ្វើបច្ច័យទាំងនោះ ឱ្យមានផលច្រើនដោយគុណរបស់លោក បានជាឈ្មោះថា « អាហុណេយ្យោ » ។

កែបទ « បាហុណេយ្យោ »

បទថា « បាហុណេយ្យោ » ប្រែថា លោកគួរទទួលនូវអាគន្តុកទាន ។

អធិប្បាយថា ទានដែលបុគ្គលចាត់ចែងដោយគ្រឿងសក្ការៈ ដើម្បីទទួលញាតិមិត្តជាទីស្រឡាញ់ពេញចិត្ត ដែលមកអំពីទិសានុទិស ហៅថា « អាគន្តុកទាន » ។ អាគន្តុកទាននោះឯង គួរនឹងវ៉ៃរនូវញាតិ និងមិត្ត និងមនុស្សដែលមកជាភ្ញៀវនោះ ហើយថ្វាយដល់សង្ឃតែម្យ៉ាង ។ ព្រះសង្ឃគួរនឹងទទួលនូវអាគន្តុកទាននោះ មែនពិត មនុស្សដែលមកជាភ្ញៀវនោះ មិនប្រាកដដូចព្រះសង្ឃទេ ព្រោះព្រះសង្ឃដែលអញ្ជើញមកជាភ្ញៀវនោះ រមែងមានតែក្នុងកាលដែលមានព្រះពុទ្ធត្រាស់ប៉ុណ្ណោះ មិនដែលមានក្នុងកាលដទៃឡើយ ហើយលោករមែងប្រកបដោយធមិ ជាគ្រឿងធ្វើនូវសក្ការៈនៃខ្លួន មុខគួរឱ្យអ្នកផងស្រឡាញ់ គួរឱ្យគេចាប់ចិត្ត មានសីលគុណជាដើម ព្រោះហេតុនោះ របស់ដែលសម្រាប់ទទួលភ្ញៀវនោះ គួរតែលើកមកថ្វាយដល់ព្រះសង្ឃន៉ុះមែនពិត ដូច្នេះទើបឈ្មោះថា « បាហុណេយ្យោ » ។

កែបទ « ទក្ខិណេយ្យោ »

បទថា «ទក្ខិណេយ្យោ» ប្រែថា « លោកគួរទទួលនូវទក្ខិណាទាន » ។

អធិប្បាយថា ទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយធ្វើ ហៅថា « ទក្ខិណាទាន » ព្រះសង្ឃជាសាវ័កលោកគួរទទួលទក្ខិណាទាននោះ ព្រោះរមែងជម្រះទានរបស់ទាយកឱ្យបរិសុទ្ធបាន ឱ្យមានផលច្រើន ទើបបានឈ្មោះថា « ទក្ខិណេយ្យោ » ។

កែបទ « អញ្ជលិករណីយោ »

បទនេះប្រែថា លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ។

អធិប្បាយថា ព្រះសង្ឃជាសាវ័ក លោកគួរដល់អញ្ជលិកម្ម គឺគួរសត្វថ្វាយបង្គំ បើនិយាយដោយហោចទៅ សូម្បីសត្វលោកគ្រាន់តែរមិលមើលព្រះសង្ឃដោយចក្ខុ ប្រកបដោយមេត្តាប៉ុណ្ណោះ ចក្ខុនោះរមែងប្រាសចាកទោសមានឡើងបាយជាដើម ក្នុងអនេកជាតិនេះបាន ។

កែបទ « អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស »

បទនេះ ប្រែថា លោកជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

អធិប្បាយថា ព្រះសង្ឃជាសាវ័ក ជាស្រែកើតបុណ្យនៃសត្វលោក មិនមានស្រែដទៃប្រសើរស្មើ ឬជាងឡើយ ទីសាបព្រោះបណ្តុះពូជស្រូវសាលី ស្រូវដំណើបនៃស្តេច ឬអាមាត្យ ឈ្មោះថាស្រែស្រូវសាលី ស្រែស្រូវដំណើបនៃស្តេច ឬអាមាត្យយ៉ាងណា, ព្រះសង្ឃដែលជាទីដុះចំរើនបុណ្យនៃសត្វសត្វ ក៏ដូច្នោះដែរ, បានជាថាព្រះសង្ឃជាទីកើតបុណ្យនៃសត្វលោក ព្រោះបុណ្យកុសលដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខមានប្រការផ្សេងៗ របស់សត្វលោក រមែងមានពន្លកល្អល្អតលាស់ចំរើនឡើងបាន ព្រោះតែអាស្រ័យនឹងព្រះសង្ឃ ដ្បិតព្រះសង្ឃជាស្រែបរិសុទ្ធ ប្រាសចាកទោស គឺកិលេសដែលជាគ្រឿងប្រទូស្តក្នុងសន្តានៃខ្លួន និង

ប្រទូស្តចំពោះទាន និងការបូជានៃសត្វលោក ជាស្រែបរិសុទ្ធប្រាសចាកទោស គឺស្មៅ និងក្រូសខ្សាច់ជាដើម ដែលជារបស់ប្រទូស្តដល់សន្ធូង ទើបបានឈ្មោះថាស្រែ បុណ្យដ៏ឧត្តមនៃសត្វលោក ។

ន័យមួយទៀតថា ពូជដែលបុគ្គលព្រោះសាប ឬដាំបណ្តុះក្នុងស្រែប្រកបដោយអង្ត ៨ ប្រការ ទើបមានផលច្រើន, អង្ត ៨ ប្រការនោះ ដូច្នេះ គឺ :

១. *អនុន្នមិនិន្នាមិ ច ហោតិ*	មិនទូលពេក មិនទាបពេក
២. *អបាសាណសក្ខរិញ្ញ ហោតិ*	មិនមានថ្ម និងក្រូស
៣. *អនូសរញ្ញ ហោតិ*	មិនប្រកបដោយដីប្រៃ
៤. *គម្ភីរសិតំ ហោតិ*	មានជម្រៅ និងត្រជាក់
៥. *អាយសម្បន្នំ ហោតិ*	បរិបូណិដោយសេចក្តីចំរើន គឺមានជីវជាតិច្រើន
៦. *អបាយសម្បន្នំ ហោតិ*	មិនមានសេចក្តីវិនាស
៧. *មាតិកាសម្បន្នំ ហោតិ*	មានប្រឡាយ
៨. *មរិយាទសម្បន្នំ ហោតិ*	មានភ្លឺ

ពូជដែលបុគ្គលសាបព្រោះក្នុងស្រែប្រកបដោយអង្ត ៨ នេះ រមែងមានផលច្រើនយ៉ាងណា ទានដែលបុគ្គលឱ្យដល់ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ប្រកបដោយអង្ត ៨ នេះ ក៏មានផលច្រើនដូច្នោះដែរ ។

អង្ត ៨ ប្រការនោះ ដូច្នេះ គឺ :

១. *សម្មាទិដ្ឋិកា*	ជាអ្នកយល់ត្រូវ
២. *សម្មាសង្កប្បា*	មានតម្រិះត្រូវ
៣. *សម្មាវាចា*	មានវាចាត្រូវ

๔. *สมฺมากมฺมนฺตา* មានការងារត្រូវ

๕. *สมฺมาอาชีวา* មានការចិញ្ចឹមជីវិតត្រូវ

๖. *สมฺมาวายามา* មានព្យាយាមត្រូវ

๗. *สมฺมาสติโน* មានសេចក្តីរលឹកត្រូវ

๘. *สมฺมาสมาธิ* មានចិត្តឥម្ពល់ត្រូវ

ទានដែលបុគ្គលឱ្យដល់ព្រះសង្ឃ ដែលជាបុញ្ញក្ខេត្តប្រកបដោយអង្គ ๘ ដូចរាប់មកនេះ រមែងមានផលានិសង្សច្រើន, សមដូចព្រះពុទ្ធភាសិតថា :

តิณโทสานิ ขตฺตานิ *ราคโทสา อยํ ปชา*
ตสฺมา หิ วีตราคेสุ *ทินฺนํ โหติ มหปฺผลํ ฯ*
តិณโทสานิ ขตฺตานิ *โทสโทสา อยํ ปชา*
ตสฺมา หิ วีตโทเสสุ *ทินฺนํ โหติ มหปฺผลํ ฯ*
តិณโทสานิ ขตฺตานิ *โมหโทสา อยํ ปชา*
ตสฺมา หิ วีตโมเหสุ *ทินฺนํ โหติ มหปฺผลํ ฯ*
តិณโทสานิ ขตฺตานิ *ឥจฺฉาโทสา อยํ ปชา*
ตสฺมา หิ วีตឥจฺเฉสุ *ทินฺนํ โหติ มหปฺผลํ ฯ*

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានរាគៈជាទោស ហេតុនេះ ទានដែលបុគ្គលឱ្យដល់លោកដែលមិនមានរាគៈ រមែងមានផលច្រើន ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានទោសៈជាទោស ហេតុនេះ ទានដែលបុគ្គលឱ្យដល់លោកដែលអស់ទោស រមែងមានផលច្រើន ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានមោហៈជាទោស ហេតុនេះ ទានដែលបុគ្គលឱ្យដល់លោកដែលអស់មោហៈ រមែងមានផលច្រើន ។

ស្រៃទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានឥច្ឆា គឺសេចក្តីច្រណែនជាទោស ហេតុនេះ ទានដែលបុគ្គលឱ្យដល់លោកអស់ឥច្ឆាហើយ រមែងមានផលច្រើន ។

ក៏ព្រះសង្ឃសាវ័កដែលមាននាមតាំងពី អាហុណេយ្យោ រហូតដល់បុ ក្ខេត្តំ លោកស្ស នេះ លោករមែងប្រកបដោយអង្គ ៥ យ៉ាងដទៃទៀត ប្រៀបដោយ អង្គនៃដំរីជាព្រះរាជទីនាំង ។

ដំរីនោះប្រកបដោយអង្គ ៥

១. សោតា ជាសត្វស្តាប់បង្គាប់ហ្ម

២. ហន្តា ជាសត្វតែងសម្លាប់នូវខ្មាំងសត្រូវដែលមកតទល់គ្នា ក្នុងពេលចូលកាន់សង្ត្រាម

៣. រក្ខិតា ជាសត្វចេះរក្សាអវៈយវៈតូចធំរបស់ខ្លួន ក្នុងពេលចូលកាន់សង្ត្រាម

៤. ខន្តា ជាសត្វអត់ទ្រាំនឹងលំពែងជាដើមបាន ក្នុងពេលចូលកាន់សង្ត្រាម

៥. គន្តា ជាសត្វចេះតែទៅតាមបំណងហ្ម ។

ដំរីដែលគួរដល់មហាក្សត្រិយ៍ស្តេចប្រើប្រាស់ រមែងប្រកបដោយអង្គ ៥ ប្រការនេះ យ៉ាងណាមិញ ព្រះសង្ឃសាវ័កដែលមាននាមថា អាហុណេយ្យោ ជាដើម ក៏ប្រកបដោយអង្គ ៥ ដូច្នោះដែរ គឺ :

១. សោតា ជាអ្នកស្តាប់នូវធមិដែលព្រះតថាគតសំដែង

២. ហន្តា ជាអ្នកសម្លាប់នូវអកុសលវិត្តកទាំង ៣

៣. វត្តិតា ជាអ្នករក្សាទ្វារឥន្ទ្រិយទាំង ៦

៤. ខន្តា ជាអ្នកអត់ធ្មត់នឹងក្តៅត្រជាក់ជាដើមបាន

៥. គន្តា ជាអ្នកទៅកាន់ទិសដៃលគេមិនដៃលទៅ គឺព្រះនិព្វាន ។

ព្រះសង្ឃជាសាវ័កប្រកបដោយអង្គ ៥ យ៉ាងនេះឯង ទើបឈ្មោះថា អាហុណេយ្យោ ។ ល ។ បុញ្ញក្ខេត្តំ លោកស្ស ។

ម្យ៉ាងទៀត គុណព្រះសង្ឃទាំងអម្បាលនេះ បើចំប្រព្រឹត្តចុះមក នៅត្រឹម ២ យ៉ាងគឺ អត្តហិតគុណ ១ បរហិតគុណ ១ ។

ត្រង់បទថា *សុបដិបន្នោ ឧជុបដិបន្នោ ញាយបដិបន្នោ សាមីចិបដិបន្នោ* ទាំងអស់នេះឈ្មោះថា « អត្តហិតគុណ » ព្រោះជាគុណចំនុកបម្រុងដល់ខ្លួន ។ *អាហុណេយ្យោ បាហុណេយ្យោ ទក្ខិណេយ្យោ អញ្ជលីករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស* ទាំងអម្បាលនេះឈ្មោះថា « បរហិតគុណ » ព្រោះគុណចំនុកបម្រុងដល់អ្នកដទៃ ។

ពណ៌នាអំពីសង្ឃរតនៈ ចប់ដោយសង្ខេបប៉ុណ្ណេះ

ត្រៃគុណកថា និដ្ឋិតា